## *ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨*

## នាំនាងទៅឱ្យបុរសម្នាក់ប្រើថ្នាំសម្រើបនេះនោះសម្រេច៤ដងក្នុង១យប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៨ ម៉ោង ០៩:២៧ ឈើន ជា

ខេត្តកណ្តាល ៖ នគរបាលក្រុងតាខ្មៅ បានឃាត់ខ្លួនស្ត្រីម្នាក់កាលពីថ្ងៃទី២៩ ខែកញ្ញា បន្ទាប់ពីមានពាក្យបណ្តឹងថា បានលួងលោមក្មេងស្រីម្នាក់ អាយុ១៤ឆ្នាំ នាំទៅឲ្យបុរសម្នាក់ប្រើថ្នាំសម្រើបរំលោភនាងនៅផ្ទះសំណាក់បានសម្រេចចំនួន៤លើក ។

មន្ត្រីនគរបាលក្រុងតាខ្មៅបានឱ្យដឹងថា ស្ត្រីដែលត្រូវបានឃាត់ខ្លួននេះឈ្មោះ ម៉ាន រ៉េត អាយុ៤៩ឆ្នាំ ទីលំនៅក្នុងសង្កាត់ដើមមៀន ក្រុងតាខ្មៅ មានមុខរបរជាអ្នកលាងចានតាមរោងការ ។ ប្រភពដដែលឱ្យដឹងទៀតថា តាមការរៀបរាប់របស់ក្មេងស្រី កាលពីល្ងាចថ្ងៃទី២៦ ខែកញ្ញា រូបនាងនិងមិត្តភក្តិម្នាក់ បាននាំគ្នាទៅដើរលេងនៅសួនច្បារមាត់ទន្លេតាខ្មៅ ។ ពេលនាងកំពុងអង្គុយហូបប្រហិត ស្រាប់តែឃើញស្ត្រីចំណាស់រូបនោះដើរមករកនាង ក៏ហៅហូបប្រហិតជាមួយ តែស្ត្រីរូបនេះមិនហូបទេគ្រាន់តែចូលអង្គុយមើល ។ ពេលហូបរួច ស្ត្រីចំណាស់រូបនេះក៏បបួលនាងដើរចេញមក ដោយហៅម៉ូតូឌុបជិះទៅ៣នាក់ គឺមានរូបនាង ជនល្មើស ព្រមទាំងកូនស្រីរបស់ជនល្មើស ។ ពេលឌុបដល់រាជធានីភ្នំពេញជិតបេងសាលារៀនមួយ ចម្ងាយប្រហែល២០០ម៉ែត្រពីរង្វង់មូលដែលនាងមិនស្គាល់ ស្ត្រីរូបនេះបានឲ្យម៉ូតូឌុបឈប់ ហើយទូរស័ព្ទហៅបុរសម្នាក់មិនស្គាល់ឈ្មោះ ជិះរថយន្ត១គ្រឿងមិនស្គាល់ម៉ាកមកដល់ ។ ពេលនោះស្ត្រីរូបនេះបានចូលទៅក្នុងរថយន្តបុរសនោះ និយាយគ្នាបានមួយសន្ទុះក៏ចេញមកវិញ រួចហុចលុយឲ្យថ្លៃម៉ូតូឌុបហើយក៏នាំនាងជិះរថយន្តបុរសនោះទៅផ្ទះសំណាក់មួយមិនស្គាល់ឃ្លាំងក្នុងរាជធានីភ្នំពេញ ដោយជនល្មើសឲ្យនាងនៅអង្គុយលេងក្នុងបន្ទប់ជាមួយបុរសម្នាក់នោះ ។ ចំណែកជនល្មើសប្រាប់ថា ចុះទៅក្រោមមួយភ្លែតក៏ទៅបាត់រហូត ។

ក្រោយមកនាងត្រូវបុរសនោះលួងលោម និងប្រើថ្នាំសម្រើបរួមភេទជាមួយនាងបានសម្រេច៤ដងក្នុងមួយយប់ ។ លុះដល់ព្រឹកថ្ងៃទី២៧ ខែកញ្ញា បុរសម្នាក់នោះបានប្រាប់ថា ចេញទៅធ្វើការហើយ និងប្រាប់នាងថា ចាំនៅក្នុងបន្ទប់ចុះ បន្តិចទៀតអ្នកជូនមកយកទៅវិញហើយ ។ ពេលនាងរង់ចាំមិនឃើញជនល្មើសមកយកក៏ទូរស័ព្ទទៅជនល្មើស ពេលនោះជនល្មើសប្រាប់ឲ្យជិះម៉ូតូមកចាំខ្លួនចេញលុយឲ្យ ហើយនាងបានជិះម៉ូតូឌុបមកផ្ទះជនល្មើសវិញ ។ រហូតមកដល់ថ្ងៃទី២៩ ខែកញ្ញា ទើបក្រុមគ្រួសាររបស់នាងតាមរកនាងឃើញនៅផ្ទះជនល្មើស ក៏ប្តឹងសមត្ថកិច្ចឲ្យជួញអន្តរាគមន៍ឃាត់ខ្លួនជនល្មើសយកទៅសាកសួរនៅអធិការដ្ឋាននគរបាលក្រុងតាខ្មៅតែម្តង ។ នគរបាលឲ្យដឹងទៀតថា នៅចំពោះមុខសមត្ថកិច្ច ជនល្មើសពុំព្រមឆ្លើយសារភាពទៅតាមការចោទប្រកាន់ខាងលើទេ តែករណីនេះនៅតែបន្តនីតិវិធី ៕

## ពលរដ្ឋចោទលោកឧត្តមសេនីយ៍ត្រី ប៉ុក សុផល ឃុបឃិតជាមួយឈ្មួញឈើ ពាក់ព័ន្ធនឹងកៀរគរពលករទៅកាប់គ្រញូងក្នុងទឹកដីថៃ

http://chnchannel.com/chnnewws/ ថ្ងៃទី 1 ខែ តុលា ឆ្នាំ 2018 279

ឧត្តរមានជ័យ៖ ពលរដ្ឋរិះគន់លោកឧត្តមសេនីយ៍ត្រី ប៉ុក សុផល មេបញ្ជាការរងការពារព្រំដែន៤០២ នៃយោធភូមិភាគទី៤ រឿងឃុបឃិតជាមួយឈ្មួញឈើ គាងគរពលករទៅកាប់គ្រញូងក្នុងទឹកដីថៃ។

តាមប្រភពព័ត៌មានពីពលរដ្ឋនៅសង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យបានអោយដឹងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ នេះមកថា លោក ឧត្តមសេនីយ៍ត្រី ប៉ុក សុផល មេបញ្ជាការរងការពារព្រំដែន៤០២នៃយោធភូមិភាគទី៤ បានត្រូវរ៉ូវគ្នា ជាមួយមេឧក្រិដ្ឋជនឈើក្រញូងឆ្លងដែន ចំនួនពីររូបនៅសង្កាត់អូរស្មាច់ ទី១ឈ្មោះដុស ទី

២ឈ្មោះ សាក់ គឺជាមុខសញ្ញាធំជាងគេក្នុងការគោងគរ ពលករឆ្លងដែនទៅកាប់ឈើក្រញូង នៅបង្គោលសីមាលេខ ១៣ក្នុងសង្កាត់អូស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ជាក់ស្តែងកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ កន្លងទៅថ្មីៗនេះ ពលករម្នាក់ឈ្មោះ រឿន សិលា ភេទប្រុស អាយុ ៣៥ឆ្នាំ រស់នៅ ភូមិអូខ្លាឃ្មុំ សង្កាត់អូស្មាច់ ក្រុងសំរោងក្នុងចំណោម ពលករមួយក្រុម ត្រូវបានយោធាថៃចាប់ខ្លួន រួមទាំងវត្ថុតាងឈើក្រញូងមួយរទេះតូច ស្ថិតនៅក្នុងស្រុកកាប់ជើង ខេត្តសុរិនប្រទេថៃ ជាប់ព្រំប្រទល់ សង្កាត់អូស្មាច់ក្រុងសំរោង ខេត្តឧត្តរមានជ័យ នោះត្រូវបានគេដឹងថា ដោយសារតែលោកឧត្តមសេនីយ៍ត្រី ប៉ុក សុផល មេបញ្ជាការវរៈការពារព្រំដែន៤០២នៃយោធភូមិភាគទី៤ រឿងគុបគិតជាមួយឈ្មួញឈើ ឈ្មោះ សាក់ និងឈ្មោះ ដុស នេះឯង។

ពលរដ្ឋបានសំណូមពរសុំអោយ ឯកឧត្តម ស ថាវី អភិបាលខេត្ត ខេត្តឧត្តរមានជ័យសើបអង្កេតរឿង លោកឧត្តមសេនីយ៍ត្រី ប៉ុក សុផល មេបញ្ជាការវរៈការពារព្រំដែន៤០២នៃយោធភូមិភាគទី៤ រឿងឃុបឃិតជាមួយឈ្មួញឈើ ឈ្មោះ សាក់ និងឈ្មោះ ដុស នេះផង ដើម្បីអោយដឹងការពិត។

ជុំវិញករណីខាងលើ ក្រុមការងារយើងមិនអាចស្វែងរកសុំការបំភ្លឺពីលោកឧត្តមសេនីយ៍ត្រី ប៉ុក សុផល បានទេ ព្រោះស្វែងរកលេខទំនាក់ទំនងមិនទាន់បាន ៕ BRT

## *ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨*

## ឃើញទេ! ខ្មែរ២៤នាក់ទៅនៅវៀតណាមខុសច្បាប់គេចាប់មកវិញហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៨ ម៉ោង ១៤:១៥ ប៊ុន លីនណា

ខេត្តក្រចេះ ៖ ពលរដ្ឋជនជាតិខ្មែរប្រុសស្រីក្មេងចាស់ចំនួន២៤នាក់ សុទ្ធសឹងតែរស់នៅ ក្បែរតំបន់ព្រំដែនវៀតណាមត្រូវបានអាជ្ញាធរវៀតណាមចាត់បញ្ជូនមកទឹកដីកម្ពុជាវិញ ក្រោយពីអាជ្ញាធរវៀតណាមរកឃើញថា ពលរដ្ឋទាំងនោះបានរំលោភបទបញ្ញត្តិព្រំដែនដោយ លួចចូលក្នុងទឹកដីវៀតណាមដោយខុសច្បាប់ ។

នគរបាលវរៈការពារព្រំដែនបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង២៤នាក់ គឺសុទ្ធសឹងតែរស់នៅ តាមភូមិមួយចំនួនក្នុងឃុំ២ ធ្នូ ក្បែរ និងតំបន់ព្រំដែនប្រទេសវៀតណាម ។ ហើយពលរដ្ឋទាំងនេះត្រូវបានខាងភាគីវៀតណាមចាត់បញ្ជូនមកវិញ តាមច្រកព្រំដែនអន្តរជាតិនៅថ្ងៃទី០២ តុលា បន្ទាប់ពីពួកគាត់បាននាំគ្នាលួចឆ្លងដែនចូលទៅក្នុងព្រះវិហារយាស៊ូគ្រឹះក្នុងទឹកដីវៀតណាម ចម្ងាយជាង៦គីឡូម៉ែត្រពីព្រំដែនកម្ពុជា ដើម្បីទៅទទួលអំណោយនៅ ព្រះវិហារគ្រឹះសាសនាមួយនោះ ។

នាយប៉ុស្តិ៍នគរបាលការពារព្រំដែនត្រពាំងស្រែលោកអនុសេនីយ៍ឯក យុន ម៉ន បាន ប្រាប់ឲ្យដឹងថា ក្រោយពីមានការលួចចូលដោយខុសច្បាប់ ពលរដ្ឋខ្មែរទាំងនោះត្រូវបានអាជ្ញា ធរវៀតណាមចាត់បញ្ជូនមកវិញភ្លាមៗ ។ លោកថា កន្លងមកពលរដ្ឋដែលរស់នៅតាមភូមិក្បែរ ព្រំដែនក្នុងឃុំ២ធ្នូ គឺតែងតែមានការទំនាក់ទំនងជាមួយពលរដ្ឋក្បែរព្រំដែនខាងភាគីវៀតណាម និងបានចេញចូលតាមច្រករបៀងផ្សេងៗ ។ លោកអនុសេនីយ៍ឯក យុន ម៉ន បាន ឲ្យដឹងទៀតថា ពលរដ្ឋទាំងនេះត្រូវបានអាជ្ញាធរ វៀតណាមបានចាត់បញ្ជូនពីរលើកមកហើយ ក្រោយពីពួកគាត់បានព្យាយាមនាំគ្នាលួចចូល ទៅព្រះវិហារយាស៊ូគ្រឹះក្នុងទឹកដីប្រទេសវៀតណាម ។ លោកអះអាងថា នគរបាល និងរៀបចំបើកវេទិកាសាធារណៈមួយអញ្ជើញពលរដ្ឋនៅ តាមព្រំដែនមកចូលរួម ដើម្បីផ្សព្វផ្សាយបទបញ្ញត្តិព្រំដែន ដើម្បីកុំឲ្យពួកគាត់ចូលក្នុងទឹកដី ប្រទេសគេដោយខុសច្បាប់បែបនេះទៀត ៕

# ពលករខ្មែរដែលមិនបានមកស្រុកវិញ ប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌនៅថៃ

http://kleykley.sabay.com.kh/article/ ថ្ងៃទី ០១ តុលា ២០១៨ ម៉ោង 16:32

ពលករខ្មែរធ្វើការនៅប្រទេសថៃរាប់រយនាក់ ដែលមិនបានត្រឡប់ទៅលេងស្រុកកំណើត បានសាមគ្គីគ្នាប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ នៅវត្តមួយក្នុងខេត្តសាមុទប្រាកាណ ជាប់ទីក្រុងបាងកក។ ពិធីបុណ្យនេះចាប់ផ្ដើមធ្វើឡើងកាលពីរសៀលថ្ងៃទី២៩ ហើយបញ្ចប់នៅព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨។

ក្រុមពលករធ្វើការនៅប្រទេសថៃលើកឡើងថា គោលបំណងសំខាន់ក្នុងការធ្វើបុណ្យនេះ ដើម្បីឧទ្ទិសកុសលបុណ្យដល់ជីដូនជីតា និងរក្សាទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ និងជាឱកាសដើម្បីឲ្យពួកគេបានជួបជុំផ្លាស់ប្ដូរយោបល់គ្នានៅឯក្រៅប្រទេសផងដែរ។ តំណាងពលករខ្មែរនៅប្រទេសថៃម្នាក់លោក សុន សីហា ឲ្យដឹងកាលពីថ្ងៃទី២៩ កញ្ញាថា ក្នុងពិធីនេះ ពួកគេបាននិមន្តព្រះសង្ឃខ្មែរចំនួន ១២អង្គ និងព្រះសង្ឃថៃចំនួន ៩អង្គ។ នៅរសៀលថ្ងៃដំបូងមាននិមន្តព្រះសង្ឃសូត្រមន្ត និងមានពលករខ្មែរចូលរួមប្រមាណ ១០០នាក់។ ចំណែកនៅព្រឹកថ្ងៃទី៣០ កញ្ញា ជាថ្ងៃជួបជុំគ្នាធំដោយមានការដាក់បាត និងស្ដាប់ព្រះសង្ឃសម្ដែងធម៌ទេសនា។

លោកបានឱ្យដឹងយ៉ាងដូច្នេះថា៖ «**ចំពោះពលករនៅខេត្តរ៉ាក់យ៉ង និងនៅខេត្តសាមុតប្រាកាណគាត់បានវិច នំអន្សមយកមកដែរ ហើយឥឡូវគាត់បានយកមកដល់ហើយ ដើម្បីប្រគេនព្រះសង្ឃ និងសម្រាប់ចែកពលករដែលមកចូលរួមបុណ្យបានហូបនំអន្សមខ្មែរដែលនៅក្នុងប្រទេសគាត់តែងនាំគ្នាវិចនំអន្សមជារៀងរាល់ឆ្នាំនោះ**»។

ចំណែកពលករដែលបានចូលរួមក្នុងពិធីបុណ្យនេះលោក សុខ ឃាង ថ្លែងថា នេះជាលើកទីមួយដែលរូបគេបានចូលរួមធ្វើបុណ្យភ្ជុំបិណ្ឌនៅក្រៅប្រទេសនោះ។ លោកអះអាងទៀតថា លោកបានមកធ្វើការនៅប្រទេសថៃជាង៥ឆ្នាំហើយ គឺកម្រមានឱកាសបានទៅធ្វើបុណ្យភ្ជុំបិណ្ឌនៅឯស្រុកកំណើតណាស់ ព្រោះរវល់ធ្វើការងារហើយថៅកែជនជាតិថៃ មិនអនុញ្ញាតឲ្យខ្លួនឈប់សម្រាកទៅមកស្រុកខ្មែរ ក្នុងឱកាសពិធីបុណ្យនេះបានទេ។

ព្រះចៅអធិការវត្តប្រាសាទស្រះកណ្ដាលខ្វាស់ ព្រះតេជព្រះគុណ ចាន់ សុជន មានថេរដីកាថា ចំពោះពលរដ្ឋដែលមិនមានឱកាសមកធ្វើបុណ្យនៅស្រុកកំណើត នាំគ្នាធ្វើបុណ្យភ្ជុំបិណ្ឌនៅក្រៅប្រទេសបាន ដោយមិនមានការឆ្គងនោះទេ ហើយអ្នកធ្វើបុណ្យនេះបានបុណ្យដូចពលរដ្ឋនៅខាងក្នុងប្រទេសដែរ។ «**នេះជារឿងល្អមែនទែន អាត្មានៅតែកោតសរសើរ ខ្មែរយើងដែលនៅក្រៅប្រទេសស្ទើរគ្រប់ទីកន្លែង ដែលតែងរក្សាប្រពៃណីធ្វើបុណ្យភ្ជុំបិណ្ឌដូចពលរដ្ឋខ្មែរនៅក្នុងស្រុកដែរ ដូច្នេះអាត្មាគិតថាពលរដ្ឋខ្មែរនៅទីណាក៏ដោយ គឺមិនបោះបង់ប្រពៃណីទំនៀមទម្លាប់ខ្មែរដែរ ហើយប្រពៃណីទាំងនេះនឹងធ្វើឲ្យមានបន្តទៅដល់ក្មេងជំនាន់ក្រោយទៀត**»។

ក្រុមពលកររំពឹងថា អ្នកដែលចូលរួមក្នុងពិធីបុណ្យនៅព្រឹកថ្ងៃទី៣០ កញ្ញា អាចនឹងមានជាង១ពាន់នាក់ ព្រោះបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ ពលករភាគច្រើនមិនបានទៅលេងស្រុកកំណើតនោះទេ ដោយសារថៅកែមិនអនុញ្ញាត ក្នុងនោះពលករមួយចំនួននឹងនាំគ្នាទៅធ្វើបុណ្យជាមួយព្រះសង្ឃខ្មែរ នៅតំបន់ដែលពួកគេរស់នៅក្នុងប្រទេសថៃ ព្រោះមានរៀបចំពិធីបុណ្យភ្ជុំបិណ្ឌជាច្រើនកន្លែង ដូចជានៅខេត្តនគររាជសីមា ទីក្រុងបាងកក និងខេត្តសាមុតខនជាដើម៕

# ថៃ ចាប់ពលរដ្ឋខ្មែរ ចូលកាប់ឈើបញ្ជូនទៅតុលាការ

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 02 October 2018 | 09:24 ICT

**ឧត្តរមានជ័យ:** ពលរដ្ឋខ្មែរម្នាក់ក្នុងចំណោមគ្នា ៦ នាក់ត្រូវបានទាហានឈុតប៉ារ៉ាថៃចាប់ខ្លួនបញ្ជូនទៅតុលាការកាលពីយប់ថ្ងៃអាទិត្យក្រោមការចោទប្រកាន់ពីបទលួចឆ្លងដែនដោយខុសច្បាប់ចូលទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ។

លោក ៣ា ភេង អនុប្រធានក្រុមការងារនគរបាលទំនាក់ទំនងកិច្ចការព្រំដែនកម្ពុជា-ថៃប្រចាំច្រកអន្តរជាតិអូរស្មាច់បានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីម្សិលមិញថា ពលរដ្ឋខ្មែរដែលត្រូវបានទាហានថៃចាប់ខ្លួននោះឈ្មោះ រឿន សិលា អាយុ ៣៥ ឆ្នាំជាប្រជាកសិករនៅក្នុងភូមិអូរខ្លាឃុំ សង្កាត់អូរស្មាច់ ក្រុងសំរោង។ លោកថ្លែងថា៖ «សមត្ថកិច្ចយើងបានព្យាយាមជួយសម្របសម្រួល ដើម្បីស្នើសុំឲ្យភាគីថៃដោះលែងគាត់ត្រឡប់មកវិញ ប៉ុន្តែភាគីថៃបានបដិសេធដោយអះអាងថាគាត់ត្រូវបានចាប់ខ្លួនក្នុងបទល្មើសដាក់ស្តែងដែលចាំបាច់ត្រូវបញ្ជូនទៅឲ្យតុលាការធ្វើការផ្តន្ទាទោសទៅតាមផ្លូវច្បាប់»។ លោក ភេង បានបន្តថាយោងតាមរបាយការណ៍ស៊ើបសួរដោយសង្ខេបរបស់ភាគីថៃលោក រឿន សិលា បានសារភាពថាគាត់ និងអ្នកភូមិ ៥ នាក់ផ្សេងទៀតបានលួចចូលទៅក្នុងទឹកដីថៃកាលពីយប់ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១៨ ដើម្បីកាប់ឈើគ្រញូងយកមកលក់ឲ្យឈ្មួញឈើល្បីឈ្មោះម្នាក់ឈ្មោះ សាក់ តាមរយៈមន្ត្រីយោធាម្នាក់ឈ្មោះ ដុស។

ក្រោយពីកាប់បានសម្រេចហើយនោះ នៅព្រលប់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៨ ពួកគាត់បាននាំគ្នាលើកឈើទាំងនោះដាក់លើរទេះ ហើយអូសមកកាន់ព្រំដែនក្បែរច្រកទ្វារអន្តរជាតិអូរស្មាច់ ដើម្បីឆ្លងចូលមកកាន់ទឹកដីកម្ពុជាវិញ ប៉ុន្តែត្រូវបានក្រុមទាហានព្រំដែនថៃ ដែលចុះល្បាតតាមជួរបន្ទាត់ព្រំដែនប្រទះឃើញនាំគ្នាព័ទ្ធចាប់បានតែគាត់ម្នាក់ ចំណែកអ្នកផ្សេងបានរត់រួច។ លោកបានបញ្ជាក់ថា៖ «ក្នុងរបាយការណ៍នោះអាជ្ញាធរថៃបានចាប់រឹបអូសវត្ថុតាងរួមមានរណារយក្សមួយដើម រទេះ ២ គ្រឿងដែលផ្ទុកពេញដោយកំណាត់ឈើ និងគល់ឈើគ្រញូង។ នៅពេលនេះជនសង្ស័យ និងវត្ថុតាងត្រូវបានអាជ្ញាធរថៃកសាងសំណុំរឿងបញ្ជូនទៅតុលាការខេត្តសុរិន្ទ ដើម្បីចាត់ការបន្តតាមផ្លូវច្បាប់»។

ម្តាយក្មេករបស់លោក រឿន សិលា គឺអ្នកស្រី សិ ៣ា បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃម្សិលមិញថា កូនប្រសារប្រុសរបស់អ្នកស្រីគឺជាកសិករមិនធ្លាប់រកស៊ីកាប់ឈើគ្រញូងនោះទេកាលពីមុនមក ប៉ុន្តែកាលពី ១ សប្តាហ៍មុននេះមានអ្នកភូមិ ៤-៥ នាក់បានបបួលគាត់ទៅដោយប្រាប់ថា មានមន្ត្រីយោធាម្នាក់ឈ្មោះ ដុស ចាំនាំផ្លូវ និងប្រមូលទិញឈើពីពួកគាត់នៅក្បែរច្រកព្រំដែនដើម្បីទុកលក់បន្តឲ្យឈ្មួញឈើឈ្មោះ សាក់។ អ្នកស្រី ៣ា បានបញ្ជាក់ថា៖ «ខ្ញុំមិនដឹងថា មន្ត្រីយោធាឈ្មោះ ដុស នោះនៅអង្គភាពណានោះទេ ប៉ុន្តែមានគេប្រាប់ខ្ញុំថានៅក្នុងតំបន់នេះមានអង្គភាពយោធាវរៈការពារព្រំដែនលេខ ៤០២ និង អង្គភាពនគរបាលវរៈការពារព្រំដែនលេខ ៧០២»។

ប៉ុន្តែលោក ប៉ុក សុផល មេបញ្ជាការ វរៈការពារព្រំដែន ៤០២ បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃម្សិលមិញដោយបដិសេធថា គ្មានមន្ត្រីយោធាណាម្នាក់នៅក្នុងអង្គភាពរបស់លោកប្រព្រឹត្តអំពើល្មើសបែបនេះនោះទេ ហើយករណីដែលបានកើតឡើងនាពេលថ្មីៗនេះទៀតសោតក៏មិនស្ថិតនៅក្នុងតំបន់ដែលគ្រប់គ្រងដោយអង្គភាពយោធាវរៈការពារព្រំដែនលេខ ៤០២ នោះដែរ។ លោកថ្លែងថា៖ «យ៉ាងណាក៏ដោយករណីនេះអង្គភាពយើងខ្ញុំនឹងធ្វើការស្រាវជ្រាវ ហើយបើសិនជារកឃើញថាមានមន្ត្រីយោធាណាម្នាក់នៅក្នុងអង្គភាពយើងប្រព្រឹត្តអំពើល្មើសច្បាប់ដោយកាងពលករឆ្លងដែនខុសច្បាប់ទៅកាប់ឈើគ្រញូងនៅក្នុងទឹកដីខ្មែរ ឬទៅក្នុងទឹកដីថៃក្តី យើងនឹងចាត់វិធានការទៅតាមផ្លូវច្បាប់ដោយគ្មានការលើកលែងនោះឡើយ»។

បើតាមលោក សុផល ចំណុចដែលពលករខ្មែរត្រូវទាហានព្រំដែនថៃចាប់ខ្លួននោះមានចម្ងាយប្រមាណជាង ១០០ ម៉ែត្រពីតំបន់កាស៊ីណូ និងវីសែតអូរស្មាច់ ដែលទីតាំងនេះស្ថិតក្រោមការទទួលខុសត្រូវរបស់អង្គភាពនគរបាលអន្តោប្រវេសន៍ច្រកអូរស្មាច់ និង នគរបាលវរៈការពារព្រំដែនលេខ ៧០២។

ប៉ុន្តែលោក គង់ សុខាន់ មេបញ្ជាការអង្គភាពនគរបាលវរៈការពារព្រំដែនលេខ ៧០២ បានអះអាងថា តំបន់នោះគឺស្ថិតក្រោមការគ្រប់គ្រងរបស់នគរបាលអន្តោប្រវេសន៍ ព្រោះនគរបាលអន្តោប្រវេសន៍មានសិទ្ធិគ្រប់គ្រងក្នុងចន្លោះ ១ គីឡូម៉ែត្រពីច្រកព្រំដែនអន្តរជាតិអូរស្មាច់៕

*ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨*

## ជប៉ុនសន្យាបណ្តុះបណ្តាលពលរដ្ឋ និងបញ្ជូនកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅជប៉ុនបន្ថែម

http://mlvt.gov.kh/index.php Wednesday, 03 October 2018 15:24

ទីស្តីការក្រសួង៖ តាមរយៈការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន (JCIA) បានព្រមព្រៀងទទួលបណ្តុះបណ្តាលពលរដ្ឋ កម្ពុជាឱ្យទទួលបានជំនាញវិជ្ជាជីវៈមួយចំនួន ដែលទីផ្សារការងារនៅជប៉ុនកំពុងមានតម្រូវការខ្ពស់ ដើម្បីត្រៀមបញ្ជូនពួកគេទៅសិក្សា និងធ្វើការនៅប្រទេសជប៉ុនបន្ថែមទៀត។ អនុស្សរណៈនេះ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក Fumio Yamada ប្រធានអង្គការសមាគមសហប្រតិបត្តិការកម្ពុជា-ជប៉ុន (JCIA) នៅទីស្តីការក្រសួងការងារ នាថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨។

ឯកឧត្តម អ៊ិត សំហេង មានប្រសាសន៍ថា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងលើ ត្រូវធ្វើឡើងនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពោធិ៍សែនជ័យ ហើយអង្គការ JCIA ក៏បានជួយបណ្តុះបណ្តាល និងបញ្ជូនកម្មសិក្សាការីកម្ពុជាទៅសិក្សា និងធ្វើការនៅប្រទេសជប៉ុន មានរយៈពេលជាច្រើនឆ្នាំមកហើយ។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា ឆ្នាំនេះ និងឆ្នាំក្រោយ កម្ពុជានៅតែបន្តបញ្ជូនកម្មសិក្សាការីរបស់ខ្លួនទៅធ្វើការ និងសិក្សានៅប្រទេសជប៉ុនថែមទៀត ប៉ុន្តែមិនទាន់កំណត់ចំនួនច្បាស់លាស់នៅឡើយទេ ពេលប្រសិនបើបណ្តុះបណ្តាលបានច្រើន គឺកម្ពុជានឹងបញ្ជូនកាន់តែច្រើនទៅតាមដំណាក់កាលនីមួយៗ។ ឯកឧត្តម បានបញ្ជាក់ថា អនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា និងអង្គការ JCIA នេះ មានរយៈពេល៥ឆ្នាំ ក្នុងនោះអង្គការមានផ្តល់ការបណ្តុះបណ្តាលដល់ជនពិការឱ្យចេះភាសាជប៉ុន ចេះជំនាញជួសជុលម៉ូតូ កាត់ដេរ។ ក្រៅពីនោះ មានជំនាញថែទាំមនុស្សចាស់ សំណង់ស្ថាបត្យកម្មទេសចរណ៍ ជួសជុលគ្រឿងយន្តជាដើម។

បន្ទាប់នឹងបញ្ជូនកម្មសិក្សាការីដែលមានកាយសម្បទាគ្រប់គ្រាន់ ទៅធ្វើកម្មសិក្សានៅប្រទេសជប៉ុន រយៈពេល៣ឆ្នាំ។ សូមជម្រាបថា ចាប់ពីឆ្នាំ២០០៧-២០១៨ កម្ពុជាបានបញ្ជូនកម្មសិក្សាការីរបស់ខ្លួនចំនួន ៨,០៦៥ នាក់ (ស្រីចំនួន ៤,៤៣៥នាក់) ហើយក្នុងរយៈពេលជាងកន្លះឆ្នាំ២០១៨ មានកម្មសិក្សាការីកម្ពុជាចំនួន ១,៨៨៨ នាក់ ត្រូវបានបញ្ជូនទៅបម្រើការងារនៅប្រទេសជប៉ុន។ ការងារនៅប្រទេសជប៉ុនសម្រាប់កម្មសិក្សាការី រួមមាន៖ កសិកម្ម នេសាទ សំណង់ កែច្នៃចំណីអាហារ កាត់ដេរ គ្រឿងយន្ត លោហធាតុ ថែមទាំមនុស្សចាស់ និងវិស័យមួយចំនួនទៀត។ ចំពោះប្រាក់ឈ្នួលដែលកម្មសិក្សាការីកម្ពុជា ទទួលបានពីការងារនៅប្រទេសជប៉ុន ដោយគណនាតាមប្រាក់ម៉ោងនោះ មានពី៧៦២យ៉េន-៩៨៥យ៉េន ឬប្រហែលពី ៦.៨ដុល្លារ-៨.៧ដុល្លារ គិតចាប់ពីខែតុលា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ ហើយខុសគ្នាទៅតាមខេត្តនីមួយៗ៕

## ឃាត់ខ្លួនមនុស្សប្រុសស្រី២នាក់ ពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនមិនស្របច្បាប់

http://nokorwatnews.com/ ថ្ងៃទី ០៣ តុលា ២០១៨

ភ្នំពេញ៖ កាលពីវេលាម៉ោង៥និង៣០នាទីល្ងាច ថ្ងៃច័ន្ទ ៧រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ កម្លាំងនគរបាលនាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន នៃក្រសួងមហាផ្ទៃ សហការជាមួយសមត្ថកិច្ច នគរបាលខណ្ឌច្បារអំពៅ ដឹកនាំដោយលោក ឧត្តមសេនីយ៍ត្រី ញ៉ែម សៅណុល អនុប្រធាននាយកដ្ឋាន ចាប់ខ្លួនជនល្មើស ០២នាក់ នៅចំណុចផ្ទះលេខ៣៧ ផ្លូវ P១០E ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ ។

លោក ឧត្តមសេនីយ៍ត្រី ញ៉ែម សៅណុល បានឲ្យដឹងថា ការចាប់ខ្លួនជនសង្ស័យទាំង២នាក់ខាងលើនេះ យោងតាមដីកាបញ្ជាឲ្យចូលខ្លួនចំនួន ២ ៖ ទី១មានឈ្មោះ ឈិន លាង ភេទប្រុស អាយុ៣២ឆ្នាំ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៣៧ ផ្លូវ P១0E ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ តាមដីកាបញ្ជាឲ្យចូលខ្លួនលេខ២៥៩ អ.យ .ថ ចុះថ្ងៃទី២៥-០៩-២០១៨ ចេញដោយលោកសៀង សុខព្រះរាជអាជ្ញា រង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីបទ ៖ ការនាំមនុស្សយកចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន កាលពីអំឡុងខែមករា និងខែកុម្ភៈឆ្នាំ២០១៨។ និងទី២ មានឈ្មោះ អ៊ុក ចាន់ធូ ភេទស្រី អាយុ៣២ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៣៧ ផ្លូវP១0E ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ តាមដីកាបញ្ជាឲ្យចូលខ្លួនលេខ២៦០ អ.យ.ថ ចុះថ្ងៃទី២៥-០៩-២០១៨ ចេញដោយលោកសៀង សុខ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានី ភ្នំពេញ ពីបទ ៖ ការនាំមនុស្សយកចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន កាលពីអំឡុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១៨។

បច្ចុប្បន្ន ជនសង្ស័យទាំង ២នាក់ ត្រូវបានកម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ ដើម្បីបន្តនីតិវិធី ៕ ស តារា

## អភិបាលខេត្តស្វាយរៀង អរគុណចំពោះអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់នៃខេត្តតៃនិញ ខេត្តឡុងអាន និងក្រុងហូជីមិញ (វៀតណាម) ដែលបានការគាំពារ និងសម្របសម្រួលការបញ្ជូនត្រឡប់មកវិញនូវកុមារកម្ពុជា ដែលបានឆ្លងដែនទៅប្រកបរបរផ្សេងៗ

http://www.cen.com.kh/archives/ October 3, 2018

ខេត្តស្វាយរៀង ៖ លោក ម៉ែន វិបុល អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តស្វាយរៀងនាព្រឹកថ្ងៃពុធ ០៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨នេះ បាន អញ្ជើញជាអធិបតីនៅក្នុងកិច្ចប្រជុំទ្វេភាគីស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការការពារកុមារឆ្លងដែនរវាងខេត្តស្វាយរៀង (កម្ពុជា) ជាមួយខេត្តឡុងអាន ខេត្តតៃនិញ និងទីក្រុងហូជីមិញ (វៀតណាម) ។

នៅក្នុងកិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីលោក អ៊ឹម ហេន អគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ លោក ជិន វ៉ាន់ចៀន អនុប្រធានគណៈកម្មាធិការប្រជាជនខេត្តតៃនិញ និងលោកស្រី ង្វៀន ធីបាច់ហ្វេ នាយិការងមន្ទីរពលកម្ម យុទ្ធជនពិការ និងសង្គមកិច្ចខេត្តឡុងអាន ព្រមទាំងអាជ្ញាធរជាប់ព្រំដែន សមត្ថកិច្ច និងមន្រ្តីជំនាញពាក់ព័ន្ធរបស់ភាគីទាំងពីរកម្ពុជា-វៀតណាម ប្រមាណជិត ១០០រូប ។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនេះ លោកអភិបាលខេត្តស្វាយរៀងក៏ បានថ្លែងនូវការអរគុណចំពោះអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់នៃខេត្តតៃនិញ ខេត្តឡុងអាន និងក្រុងហូជីមិញ (វៀតណាម) ក៏ដូចជាស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ដែលបានសហការយ៉ាងល្អប្រសើរជាមួយនឹងខេត្តស្វាយរៀង នៅក្នុងការគាំពារ និងសម្របសម្រួលការបញ្ជូនត្រឡប់មកវិញនូវកុមារកម្ពុជា ដែលបានឆ្លងដែនទៅប្រកបរបរផ្សេងៗនៅប្រទេសវៀតណាម ប្រកបដោយសន្តិសុខសុវត្ថិភាព ស្របទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសពីរកម្ពុជា-វៀតណាម ។ ជាមួយនេះលោក ម៉ែន វិបុល ក៏បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះការសហការរៀបចំកិច្ចប្រជុំនៅថ្ងៃនេះ ដែលនឹងចូល រួមចំណែកយ៉ាងសំខាន់ដល់កិច្ចខិតខំប្រឹងប្រែង ពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើរាល់បណ្តាសកម្មភាព ចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមដែលភាគីពាក់ព័ន្ធទាំងពីរបានអនុវត្តនាពេលកន្លងមក ក្នុងកិច្ចគាំពារកុមារឆ្លងដែន ដើម្បីឈានទៅលើការដោះស្រាយបញ្ហានេះ ប្រកបដោយប្រសិទ្ធភាព ហើយតាមរយៈការចូលរួមមតិយោបល់របស់កិច្ចប្រជុំ នឹងផ្តល់ជាធាតុចូលដ៏សំខាន់ នៅក្នុងការរៀបចំផែនការសកម្មភាពមួយជាក់លាក់ សម្រាប់ជំរុញកិច្ចការពារ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្មកុមារឆ្លងដែនលើគ្រប់ទម្រង់ បានកាន់តែមានប្រសិទ្ធភាពថែមទៀត ៕ ដោយ ៖ រ៉ែកូ

# លោក ឈាន វុន ជំរុញឲ្យភាគីថៃបន្តកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់

http://freshnewsasia.com/ 2018-10-02

**(ប៉ៃលិន)៖** លោក ឈាង វុន ប្រធានគណៈកម្មការការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មានរដ្ឋសភាកម្ពុជា បានសំណូមមពរដល់ភាគីថៃ ឲ្យបន្តកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ដើម្បីដោះស្រាយបញ្ហាពលករខ្មែរ ឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ។

ការសំណូមពររបស់លោក ឈាង វុន បានធ្វើឡើងថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ នៅខេត្តប៉ៃលិន ក្នុងឱកាសលោក និងលោកស្រី បាន ស្រីមុំ អនុប្រធានគណៈកម្មការទី៥ បានដឹកនាំគណៈប្រតិភូជួបប្រជុំពិភាក្សាការងារជាមួយប្រតិភូថៃដែលដឹកនាំដោយ លោកស្រី Bilaibhan Sampatisari ប្រធានគណៈកម្មការការបរទេស នៃរដ្ឋសភាថៃ ដើម្បីរឹតចំណងមិត្តភាព និងបង្កើនកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែល្អប្រសើរឡើង រវាងស្ថាប័ននីតិបញ្ញត្តិ នៃប្រទេសទាំងពីរ។ លោក ឈាង វុន បានថ្លែងថា ប្រទេសទាំង២ ត្រូវបង្កើនកិច្ចសហប្រតិបត្តិការ ប្រកបដោយមិត្តភាព រវាងសមាជិកសភា និងនៅតាមបណ្តោយព្រំដែនឱ្យកាន់តែល្អប្រសើរឡើង ដើម្បីបម្រើឱ្យផលប្រយោជន៍ប្រជាជន និងប្រទេសជាតិដោយស្មោះត្រង់ និងស្មើភាព។ លោកបានបញ្ជាក់យ៉ាងដូច្នេះថា **«ខ្ញុំសូមឲ្យភាគីថៃ មេត្តាបន្តសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហាមួយចំនួនដូចជា៖ ការប្រើប្រាស់បណ្ណឆ្លងព្រំដែនថ្មី** (Border Pass) **បញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់ ព្រមទាំងបទល្មើសឆ្លងដែននានា និងការនាំចេញកសិផល ព្រមទាំងការធ្វើពាណិជ្ជកម្មឆ្លងដែន រវាងប្រទេសទាំងពីរផងដែរ»**។

ជាមួយគ្នានេះ លោកស្រី បាន ស្រីមុំ ក៏បានស្នើដល់ភាគីថៃជួយបង្កលក្ខណៈងាយស្រួល សម្រាប់ប្រជាពលរដ្ឋកម្ពុជា ឆ្លងដែនចេញទៅព្យាបាលជំងឺ ឬទៅទេសចរណ៍នៅក្នុងប្រទេសថៃ ជាពិសេស ពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ និងធ្វើដំណើរឆ្លងដែនចេញចូល មកលេងស្រុកកំណើតក្នុងឱកាសបុណ្យទាននានា ឬមកចូលរួមការបោះឆ្នោតជាដើម។ ជាការឆ្លើយតបលោកស្រី Bilaibhan Sampatisari បានសន្យាខិតខំសហប្រតិបត្តិការ និងដោះស្រាយនូវរាល់សំណូមពរ របស់ភាគីកម្ពុជា ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ចំណែកបញ្ហា១ចំនួនទៀត។ លោកស្រីក៏បានសន្យាថានឹងពិភាក្សា ជាមួយមន្ត្រីជំនាញពាក់ព័ន្ធ និងថ្នាក់ដឹកនាំ ព្រមទាំងរាជរដ្ឋាភិបាលថៃ ដើម្បីរកលទ្ធភាព និងដំណោះស្រាយ ដើម្បីធ្វើការបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ ឱ្យបានកាន់តែល្អប្រសើរឡើង។ លោកស្រី Bilaibhan Sampatisari បានកោតសសើរដល់គណៈកម្មការទី៥ នៃរដ្ឋសភាកម្ពុជា និងអាជ្ញាធរនៅតាមព្រំដែន ដែលកន្លងមកបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការ រវាងខេត្តនៅតាមបណ្តោយព្រំដែននៃប្រទេសទាំង២ ដើម្បីរក្សាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងបម្រើឱ្យផលប្រយោជន៍របស់ប្រជាជន និងប្រទេសទាំង២ ដោយស្មើភាពនិងស្មោះត្រង់កន្លងមក។

សូមបញ្ជាក់ថា នេះជាលើកទី១ហើយ ដែលគណៈកម្មការជាន់ខ្ពស់សភាជាតិ នៃប្រទេសទាំង២ កម្ពុជា និងថៃ បានមកជួបប្រជុំពិភាក្សា នៅលើទឹកដីខេត្តប៉ៃលិន ដើម្បីរឹតចំណងមិត្តភាព និងបង្កើនកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែល្អប្រសើរឡើង រវាងស្ថាប័ននីតិបញ្ញត្តិ នៃប្រទេសទាំង២៕

# កូរ៉េខាងត្បូងឲ្យពលករបរទេសខុសច្បាប់ចាកចេញពីប្រទេសខ្លួនក្នុងរយៈពេល៦ខែ

https://vodhotnews.com/ លោក ស៊ុន សុខេន OCTOBER 3, 2018 1:14 PM

អាជ្ញាធរកូរ៉េខាងត្បូង បានចេញសេចក្តីសម្រេចមួយដោយទុកពេល៦ខែឲ្យពលករបរទេសដែលកំពុងធ្វើការដោយខុសច្បាប់ចាកចេញពីប្រទេសខ្លួន បើពុំដូច្នេះទេពួកគេទាំងនោះនឹងត្រូវដាក់ចូលក្នុងបញ្ជីខ្មៅនិងហាមមិនឲ្យជាន់ទឹកដីប្រទេសនេះក្នុងរយៈពេល១០ឆ្នាំ។

តាមការចុះផ្សាយលើគេហទំព័រនាយកដ្ឋានអន្តោប្រវេសន៍កូរ៉េខាងត្បូងដែលចេញផ្សាយកាលពីម្សិលមិញ កូរ៉េខាងត្បូងបានអនុញ្ញាតឲ្យជនបរទេសដែលកំពុងធ្វើការដោយខុសច្បាប់អាចចាកចេញពីប្រទេសនេះចាប់ពីថ្ងៃទី១ ខែតុលាឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ដោយមិនយកទោសពៃរ៍អ្វីនោះទេ ។ ប៉ុន្តែតាមប្រភពដដែល ប្រសិនបើជនបរទេសណាមួយដែលធ្វើខុសច្បាប់នៅតែរឹងទទឹងដោយបន្តធ្វើការក្រោយរយៈពេលដែលបានកំណត់ខាងលើ ហើយត្រូវអាជ្ញាធរកូរ៉េចាប់ខ្លួនបាន ឈ្មោះរបស់ពួកគេនឹងត្រូវដាក់ចូលក្នុងបញ្ជីខ្មៅ និងហាមមិនឲ្យចូលប្រទេសនេះក្នុងរយៈពេល១០ឆ្នាំ។

ប្រភពខាងលើ ក៏បានបញ្ជាក់ផងដែរថាសម្រាប់និស្សិតបរទេស និងសមាជិកគ្រួសារជនបរទេសដែលបានរៀបការជាមួយជនជាតិកូរ៉េខាងត្បូង ហើយធ្វើការដោយខុសច្បាប់ក្នុងវិស័យសំណង់និងសេវាកម្សាន្តនានា ក៏នឹងត្រូវបណ្តេញចេញភ្លាមៗ បើទោះបីជាទិដ្ឋាការរបស់ពួកគេមិនទាន់ផុតកំណត់យ៉ាងណាក្តី។ ដោយឡែកភ្នាក់ងារឬក្រុមហ៊ុនជ្រើសរើសពលករកូរ៉េខាងត្បូងណាដែលជួយឲ្យពលករបរទេសខុសច្បាប់បានធ្វើការក្នុងប្រទេសកូរ៉េខាងត្បូងនឹងត្រូវទទួលទណ្ឌកម្មនានាដូចជាការផ្អាកមិនឲ្យធ្វើអាជីវកម្មជាដើម។

ជនបរទេសដែលកំពុងធ្វើការដោយខុសច្បាប់ក្នុងប្រទេសកូរ៉េខាងត្បូងមានប្រហែល៣០ម៉ឺននាក់។ នេះបើតាមតួរលេខដែលមន្ត្រីកូរ៉េខាងត្បូងផ្តល់ឲ្យសារព័ត៌មានបាងកកប៉ុស្តិ៍របស់ថៃ។ ប្រភពដដែលក៏បានឲ្យដឹងថាក្នុងចំណោមអ្នកដែលធ្វើការខុសច្បាប់ទាំងនោះ មានជនជាតិថៃរហូតដល់៤០ភាគរយ ឬស្មើនឹង១២ម៉ឺននាក់។ តាមបាងកកប៉ុស្តិ៍ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជនជាតិថៃរាប់ពាន់នាក់ បានទៅប្រទេសកូរ៉េខាងត្បូងក្នុងនាមជាភ្ញៀវទេសចរ។ ប៉ុន្តែនៅពេលដែលទិដ្ឋាការរបស់ពួកគេផុតកំណត់ ពួកគេមិនបានត្រលប់មកវិញទេ បែរជានាំគ្នាបន្តធ្វើជាពលករដោយខុសច្បាប់ទៅវិញ។

បើតាមបាងកកប៉ុស្តិ៍ ប្រសិនបើពលករដែលធ្វើការដោយខុសច្បាប់ទាំងនោះចាកចេញពីកូរ៉េខាងត្បូងដោយស្ម័គ្រចិត្តក្នុងរយៈពេលដែលអាជ្ញាកូរ៉េខាងត្បូងបានកំណត់ ពួកគេអាចដាក់ពាក្យទៅធ្វើការនៅប្រទេសនេះវិញបានតាមរយៈប្រព័ន្ធអនុញ្ញាតមុខរបរនិងការងារ។

ប្រទេសកូរ៉េខាងត្បូងអនុញ្ញាតឱ្យពលករមកពីប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីកណ្តាលចំនួន១៦ធ្វើការនៅក្នុងប្រទេសនេះក្រោមប្រព័ន្ធអនុញ្ញាតមុខរបរនិងការងារ។ ប្រទេសទាំងនេះរួមមាន កម្ពុជា ថៃ ឡាវ វៀតណាម ឥណ្ឌូនេស៊ី ហ្វីលីពីន មីយ៉ាន់ម៉ា ទីម័រ ចិន ម៉ុងហ្គោលី ប៉ាគីស្ថាន បង់ក្លាដេស នេប៉ាល់ អ៊ុបេគីស្ថាន ស្រីលង្កា និងគីជីស្ថាន៕

## *ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨*

### ពេលភ្ជុំបិណ្ឌពលករខ្មែរនៅថៃត្រឡប់មកស្រុកកំណើតតិចជាងពេលចូលឆ្នាំខ្មែរ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 4 October, 2018

បាត់ដំបង ៖ ឱកាសបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ ពលករខ្មែរធ្វើការនៅថៃ បានវិលត្រឡប់មកស្រុក កំណើតតិចជាងកាលពីចូលឆ្នាំខ្មែរ តាមច្រកទ្វារអន្តរជាតិដូង និងតាមច្រកផ្សេងៗនៅក្នុង ខេត្ត បាត់ដំបង។

លោក លាក់ រមនា អនុប្រធានប៉ុស្តិ៍ច្រកទ្វារអន្តរជាតិដូង បានឲ្យដឹងថា ក្នុងឱកាសបុណ្យ ភ្ជុំបិណ្ឌឆ្នាំ២០១៨ នេះ មានប្រជាពលរដ្ឋខ្មែរឆ្លងកាត់ ច្រកទ្វារអន្តរជាតិដូង ក្នុងមួយថ្ងៃៗជាមធ្យម ប្រហែល ៣ពាន់ ទៅ ៤ពាន់នាក់។ លោកថា កាលពីពិធីបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ២០១៨ មានពលករ ខ្មែរប្រមាណ ៥ពាន់ទៅ ៦ពាន់នាក់ ក្នុង១ថ្ងៃ បានចេញមកលេងស្រុកកំណើត។ ការធ្លាក់ចុះនេះ ដោយសារបញ្ហាមួយចំនួន មានទាំងបញ្ហារបស់ពលករផ្ទាល់ខ្លួនឯង និង បញ្ហារបស់អាជ្ញាធរថៃ ក្នុងការជួយសម្រួលបែបបទឯកសារ ដល់ពលករខ្មែរពេលចេញមកប្រទេស កម្ពុជាវិញ។ ការចេញ ចូល របស់ពលរដ្ឋខ្មែរតាមច្រកនេះ មិនមានបញ្ហាអ្វីនោះទេ ដោយខាង អាជ្ញាធរបានជួយសម្រប សម្រួលជូនពួកគាត់បានយ៉ាងរលូន៕

# ជីវិតអ្នកក្រពលករស្រុកថៃ បងប្អូនអើយជួយស៊ែរម្នាក់មួយមកបើអាណិតអោយពលករខ្មែរយើងបានឃើញផង

https://khmernews.news/article/ ដារ៉ា ថ្ងៃទី ០៥ តុលា ២០១៨

ពលករខ្មែរដែលធ្វើចំណាក់ស្រុក ទៅរកការងារធ្វើនៅប្រទេសថៃ ត្រូវប្រថុយប្រថានគ្រោះថ្នាក់ ជារៀងរាល់ថ្ងៃ។ អ្នកខ្លះរងគ្រោះរហូតដល់បាត់បង់ជីវិតថែមទៀតផង។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ មានសពកម្មករខ្មែររាប់រយនាក់ ត្រូវបានសមត្ថកិច្ចថៃបញ្ជូនមកខ្មែរវិញ។ ដោយឡែកកាលពីពេលថ្មីៗនេះពលករខ្មែរម្នាក់ ត្រូវបានស្លាប់ពេលកំពុងធ្វើការ ដោយធ្លាក់ពីលើអាគារ ។ ក្រោយពីកើតហេតុហើយភាគីថៃ បានដឹកសពតាមរថយន្តបញ្ជូនមកកម្ពុជា តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីប្រគល់សពឲ្យសាច់ញាតិ កាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨នេះ។ ខាងក្រោមនេះជាការរៀបរាបរបស់ប្អូនប្រុសជនរងគ្រោះ " បងប្រុសខ្ញុំគាត់បានទៅ ទៅលើកនេះមិនអាចមកវិញទេទៅរហូត សូមអោយបងទៅបានក្តីសុខ ជាតិក្រោយមានពិតសូមជួបបងម្តងទៀត ជីវិតអ្នកក្រពលកស្រុកថៃ បងប្អូនអើយជួយស៊ែម្នាក់មួយមកបើអារណិតអោយពលកខ្មែរយើងបានឃើញផង ស្លាប់ថ្ងៃទី2 ខែតុលា ឆ្នាំ2018 វេលាប្រហែលជាម៉ោង10ព្រឹក" ៕

## *ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨*

# បញ្ជូនប្តីប្រពន្ធ២នាក់ទៅតុលាការ ពាក់ព័ន្ធករណី នាំមនុស្សទៅលក់នៅប្រទេសចិន

https://www.yobminh.com/ អ៊ី បញ្ញា | October 6, 2018

ភ្នំពេញ៖ ក្រោយពីស្រាវជ្រាវឃាត់ខ្លួន បុរសជនជាតិចិន ជាប្តី និងនារីខ្មែរ ជាប្រពន្ធ ត្រូវបានកម្លាំងនគរបាល នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារនីតិជនក្រសួងមហាផ្ទៃ បញ្ជូនខ្លួនទៅតុលាការ ពាក់ព័ន្ធករណី ជួញដូរមនុស្សទៅកាន់ប្រទេសចិន។ បើតាមសមត្ថកិច្ច ជនសង្ស័យទី១ឈ្មោះ ឈិន លាង ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិចិន ជាប្តី និងទី២ ឈ្មោះ អ៊ុក ចាន់ធូ ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ជាប្រពន្ធ មានទីលំនៅផ្ទះលេខ ៣៧ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានី ភ្នំពេញ។

សមត្ថកិច្ច បានឃាត់ខ្លួនក្រុមជនសង្ស័យ បន្ទាប់ពីទទួលបានពាក្យបណ្តឹង របស់ជនរងគ្រោះម្នាក់ ក្នុងចំណោម ៧នាក់ ដែលរងគ្រោះដោយសារ ក្រុមជនសង្ស័យ បានត្រលប់មកប្រទេសកម្ពុជាវិញ។ យោងតាមសមត្ថកិច្ច បច្ចុប្បន្នមានជនរងគ្រោះ ចំនួន ៦នាក់ទៀត ដែលកំពុងត្រូវបានឃុំខ្លួន នៅប្រទេសចិន។ នៅអំឡុងចុងឆ្នាំ ២០១៧ ក្រុមជនសង្ស័យ ទាំង ២នាក់ ប្តីប្រពន្ធ បានទទួលការងារប្រមូល កម្មករ ចំនួន ៧នាក់ (ប្រុស ៤នាក់ ស្ត្រី ៣នាក់) ពីប្រទេសខ្មែរ ឲ្យទៅធ្វើការងារក្នុងកាស៊ីណូ របស់ជនជាតិចិនឈ្មោះ អ៊ូ នៅសង្កាត់ យុនសាន ក្រុង ស៊ូចូវ ខេត្តជាំងស៊ូ ប្រទេសចិន ដោយសន្យាថា នឹងផ្តល់ប្រាក់ខែ ចំនួន ១២០០ដុល្លារក្នុង ១ខែ។ នៅពេលបញ្ជូនទៅដល់ប្រទេសចិន ក្រុមជនសង្ស័យ បាននាំយក ពលករខ្មែរ ទាំង ៧នាក់ទៅ ធ្វើការងារខុសការសន្យា និងបានលក់ជនរងគ្រោះ ជាស្ត្រីខ្មែរ ឲ្យទៅផ្ទះបនស្រី ។ ប្រភពពីមន្ត្រីសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា សំណុំរឿងនេះ ស្ថិតក្រោមចំណាត់ការ របស់លោក សៀង សុខ ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ៕

# ឯកឧត្តមបណ្ឌិត អ៊ិត សំហេង អញ្ជើញសំណេះសំណាល និងរៀបចំពិធីបុណ្យភ្ជុំបិណ្ឌ ជូន ពលករកម្ពុជានៅថៃ

http://mlvt.gov.kh/index.php Sunday, 07 October 2018 13:48

នាព្រឹកថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៨នេះ ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈប្រតិភូ រួមជាមួយនិង មន្ត្រីស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសថៃ និងអាជ្ញាធរដែនដីរបស់ប្រទេសថៃ បានរៀបចំពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ ជូនដល់ បងប្អូនពលករ ពាណិជ្ជករ និស្សិតកម្ពុជា ប្រមាណជាង៧ពាន់នាក់ ដែលប្រព្រឹត្តទៅ នៅវត្តស៊ីសុជារាម សង្កាត់បាយុននន្ទ ខណ្ឌបាងកក ប្រទេសថៃ។

ក្នុងឱកាសនេះ ឯកឧត្តមរដ្ឋមន្ត្រី បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ព្រមទាំងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលជានិច្ចកាលបានគិតគូរចំពោះសុខទុក្ខ និងការរស់នៅរបស់បងប្អូនពលករ ពាណិជ្ជករ និងនិស្សិតដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃទាំងអស់ជាដារាបរៀងមក។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានមានប្រសាសន៍ ថ្លែងអំណរអរព្រះគុណ និងអរគុណ គណៈកម្មការវត្ត សមាគមខេមរៈនិស្សិត សមាគមមិត្តភាពកម្ពុជា ថៃ អាជ្ញាធរថៃ ដែលបានបង្កលក្ខណៈជូនបងប្អូនខ្មែរ រៀបចំពិធីបុណ្យភ្ជុំបិណ្ឌតាមគន្លងប្រពៃណី ហើយដែលពិធីបុណ្យនេះ ជាបុណ្យប្រពៃណីខ្មែរដែល តែងតែជួបជុំគ្រួសារ ធ្វើពិធីដាក់បិណ្ឌ ឧទ្ទិសកុសលជូនដល់ បុព្វការីជនដែលបានចែកឋាន ទៅកាន់សុគតិភព។ ឯកឧត្តមរដ្ឋមន្ត្រី មានប្រសាសន៍ បញ្ជាក់ដល់បងប្អូន ជាពលករ ពាណិជ្ជករ និងនិសិស្សិតដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃថា ពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរឆ្នាំនេះប្រព្រឹត្តទៅក្នុងបរិយាកាសល្អ ដោយរាជរដ្ឋាភិបាល បានសម្រួលដល់ បងប្អូនប្រជាពលរដ្ឋទៅធ្វើបុណ្យ បានឈប់បីថ្ងៃ បើកប្រាក់ខែមុនពិធីបុណ្យ និងផ្តល់ឡានក្រុង រថភ្លើង ជិះមិនបង់ប្រាក់ ក្នុងឱកាសទៅលេងស្រុកកំណើតផង។ ឯកឧត្តមរដ្ឋមន្ត្រី បានមានប្រសាសន៍ បញ្ជាក់ជូនដល់ ពលករ ពាណិជ្ជករ និងនិស្សិតថា បន្តថា បច្ចុប្បន្ននេះ ប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពភាព តាមរយៈ ការបោះឆ្នោត ថ្ងៃ ២៩កក្កដា កន្លងទៅ ដោយគណបក្សប្រជាជនកម្ពុជា ទទួលជោគជ័យ ១០០% ប្រជាជនជាង៨៣% បានទៅបោះឆ្នោត។ ថ្ងៃទី៦កញ្ញា រាជរដ្ឋាភិបាល អាណត្តិថ្មីទី៦ បានបង្កើតឡើង ដោយជោគជ័យ ដោយសម្តេចតេជោ ហ៊ុនសែន បានបន្តជានាយករដ្ឋមន្ត្រី អណត្តិទី៦ បន្តទៀត ហើយសម្តេចបានដាក់ចេញ កម្មវិធីនយោបាយនានាជាច្រើនដើម្បី ការពារ កសាងប្រទេស និងលើកកំពស់ ជីវភាពរបស់ប្រជាជន។

រាជរដ្ឋាភិបាលបានបន្តអនុវត្ត គោលនយោបាយ ផ្តល់ឱកាសជូនបងប្អូន ប្រជាពលរដ្ឋរកការងារដែលពេញចិត្តនៅក្រៅប្រទេស ជាពិសេសបងប្អូនពលករខ្មែរនៅថៃ ដែលបានរកបានការងារស្របច្បាប់ តស៊ូរកចំណូលផ្តល់ជូនគ្រួសារ ជាពលរដ្ឋខ្មែរដ៏ឆ្នើមដែលមានទឹកចិត្តស្នេហាជាតិមាតុភូមិ តាមរយៈការងារបងប្អូនបានផ្ញើប្រាក់ គ្រួសារវិញសរុប ប្រមាណជា២ពាន់លានដុល្លារក្នុងមួយឆ្នាំ ដែលនេះក៏បានរួមចំនែកមួយយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។ ឯកឧត្តម បានបញ្ជាក់បន្តថា ដើម្បីការពារ រក្សាការងារ និងប្រាក់ចំណូលរបស់បងប្អូន កម្ពុជាយើង នឹង បន្តកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងពលកម្មរវាងប្រទេសទាំងពីរ គឺ ៤ឆ្នាំកន្លងទៅ កម្ពុជា-ថៃ បានសម្រេចជោគជ័យ ក្នុងការដោះស្រាយបញ្ហាពលករពិសេស ការផ្តល់ភាពស្របច្បាប់ជូនបងប្អូន ជាងកន្លះលាននាក់ មកទល់ពេលនេះ បងប្អូន នៅថៃមាន១លាន ៨ម៉ឺននាក់ សុទ្ធតែស្របច្បាប់ទាំងអស់ ។ រដ្ឋាភិបាល កម្ពុជា បានចាត់តាំងទីប្រឹក្សាទទួលបន្ទុកពលករអមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ មន្ត្រីនៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងក្រុមហ៊ុនហាយសឺលូសិន

ហ្វូលឌឹង ខូអិលធីឌី ជាមន្ត្រីបង្គោល ដើម្បីចាំសម្របសម្រួល និងជួយដល់ពលករក្នុងពេលមានបញ្ហា និងតម្រូវការចាំបាច់នានា។

ពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម បងប្អូនពលករយើងនឹងទទួលបានអត្ថប្រយោជន៍ចំនួន៧ រួមមាន៖ ព្យាបាលជំងឺ មាតុភាព ពិការភាព បាត់បង់ជីវិត សោធននិវត្ត ភាពអត់ការងារធ្វើ និងការថែទាំកុមារ តែពលករត្រូវបង់វិភាគទាន ៥% នៃប្រាក់ខែ ដើម្បីជូនដល់រដ្ឋាភិបាលថៃ ហើយរបបនេះបងប្អូននឹងទទួលបានជារៀងរហូតទោះបីចប់ការងារនៅថៃ វិលត្រឡប់ទៅកម្ពុជាវិញក៏ដោយ។ នៅក្នុងឱកាសនេះដែរ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានអំពាវនាវដល់បងប្អូនរស់នៅ និងធ្វើការដោយគោរពច្បាប់ រក្សាសាមគ្គីភាព រវាងខ្មែរ និងខ្មែរ រវាងខ្មែរ និងថៃ រស់នៅក្នុងភាពសប្បាយរីករាយក្នុងសហគមន៍ និងតាមកន្លែងធ្វើការ គិតគូរពីបញ្ហា សុខភាព ជាចម្បង និងឆ្លៀតពេលទៅលេងស្រុកកំណើតនៅក្នុងឱកាសបុណ្យទាន និងថ្ងៃឈប់សម្រាកផងដែរ។ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានជូនពរដល់បងប្អូនពលករខ្មែរទាំងអស់នៅគ្រប់ទិសទី ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ប្រពៃណីជាតិខ្មែរ សូមទទួលបាននូវពុទ្ធពរ និងពរជ័យទាំង៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ៕

## *ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨*

## ពលករខ្មែរនៅកូរ៉េ សុំឲ្យសម្តេចតេជោ មកទស្សនកិច្ចនៅកូរ៉េ ជួបសំណេះសំណាល និងផ្តល់ភាពកក់ក្តៅ

https://www.dap-news.com/ ByID:111 Posted on 12 October 2018 | 11:29

ភ្នំពេញ៖ តំណាងពលករមកពីតំបន់ផាំងវ៉ុន នៃសាធារណរដ្ឋកូរ៉េ បានស្នើសុំទៅកាន់រដ្ឋមន្ត្រី ក្រសួង បរិស្ថាន លោក សាយ សំអាល់ សូមឲ្យជួយនាំសំណូមពររបស់ពួកគាត់ ដើម្បីស្នើសុំសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដើម្បីមកបំពេញទស្សនៈកិច្ចនៅកូរ៉េខាងត្បូង។ ការស្នើសុំនេះបានធ្វើឡើង នាទីក្រុងសេអ៊ូល នៅថ្ងៃអង្គារ៍ ទី០៩ ខែតុលា ឆ្នាំ២០១៨ ត្រូវជាថ្ងៃភ្ជុំធំ ខណៈស្ថានឯកអគ្គរាជទូតកម្ពុជា បានរៀបចំកម្មវិធីសំណេះសំណាល និងពិសារអាហារសាមគ្គី ជាមួយបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ ធ្វើការងារ និងសិក្សា នៅសាធារណរដ្ឋកូរ៉េ ចំនួន ប្រមាណជាង២០០នាក់ ក្រោមអធិបតីភាព លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជា អនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា នៅមជ្ឈមណ្ឌលគាំពារពលករបរទេស។

ក្នុងវេទិកាសំណេះសំណាល លោក មាជ ចាន់ដារ៉ាវ័ត្ន តំណាងពលករមកពីទីក្រុងផាំងវ៉ុន បានស្នើសុំ ទៅកាន់រដ្ឋមន្ត្រីក្រសួងបរិស្ថាន សូមឱ្យជួយនាំសំណូមពររបស់ខ្លួន ដើម្បីស្នើសុំសម្តេចតេជោ នាយករដ្ឋមន្ត្រី ដើម្បីមកបំពេញទស្សនៈកិច្ចនៅកូរ៉េខាងត្បូង តាមពេលវេលាសមស្របណាមួយ ដើម្បីបានជួបសួរសុខទុក្ខ សំណេះសំណាល និងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ ខ្មែរដែលកំពុងរស់នៅ ធ្វើការងារ និងសិក្សា ក្នុងជីវភាពល្អប្រសើរនៅសាធារណរដ្ឋកូរ៉េ ដែលមានប្រមាណជិត ៦ម៉ឺននាក់។

ឆ្លើយតបនឹងសំណូមពរនេះ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា លោក សាយ សំអាល់ សន្យានឹងនាំយកសំណូមពរនេះទៅជម្រាបជូនសម្តេចតេជោ។ បន្ថែមពីលើនេះលោករដ្ឋមន្ត្រីបានផ្តាំផ្ញើដល់អ្នកចូលរួមទាំងអស់ សូមបន្តយកចិត្តទុកដាក់លើកិច្ច ការងារ ប្រឹងប្រែងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ និងរៀនបន្ថែមនូវភាសាបរទេស ដោយហេតុតែកម្ពុជា បច្ចុប្បន្នកំពុងមានតម្រូវការលើធនធានមនុស្ស ផ្នែកបច្ចេកទេសជាច្រើនក្នុងការចូលរួម អភិវឌ្ឍន៍ប្រទេស។

គួរបញ្ជាក់ដែរថា ក្នុងឱកាសនោះដែរ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ក៏បានជំរាបជូនលោករដ្ឋមន្ត្រី សាយ សំអាល់ អំពីសភាពការណ៍មួយចំនួន ជុំវិញស្ថានភាពរស់នៅរបស់ បងប្អូនប្រជា

ពលរដ្ឋខ្មែរនៅកូរ៉េ ទាំងអ្នកមានការងារធ្វើ អ្នកដែលរៀបការប្តីប្រពន្ធនៅកូរ៉េ និង សិស្ស និស្សិត កំពុងសិក្សារស់នៅកូរ៉េ ក៏ដូចបង្ហាញពីវឌ្ឍនភាពនៃទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការ ដ៏ល្អរវាងប្រទេសទាំងពីរកម្ពុជា-កូរ៉េ៕ ដោយ ៖ ស៊ាន កុសល

## *ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨*

### ក្រសួងការងារ រំលឹកម្ចាស់សិប្បកម្ម ផលិតផល មិនត្រូវប្រើប្រាស់ កំលាំងពលកម្មកុមារ

https://www.dap-news.com/ ByID:112 Posted on 12 October 2018 | 14:40

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង រំលឹកដល់ ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានា ឲ្យបន្តអនុវត្តឲ្យ បានម៉ឺងម៉ាត់ តាមច្បាប់ស្តីពីការងារ និងប្រកាស ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ និង ពលកម្មកុមារ ទោះបីកន្លងមកក្រសួង ចុះធ្វើអធិការកិច្ចការងារនៅតាមរោងចក្រ និងសិប្បកម្ម ផលិតផល នានាមិនមានសកម្មភាព ប្រើប្រាស់កំលាំង ពលកម្មកុមារក៏ដោយ។

យោងតាមសេចក្តីជូនដំណឹង របស់ក្រសួងការងារ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ដែលចុះ ហត្ថលេខាដោយរដ្ឋមន្ត្រី បានឲ្យដឹងថា "ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រំលឹកដល់ ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានា ឲ្យបាន ជ្រាបថា ទោះបីកន្លងមកការចុះធ្វើអធិការកិច្ចការងារ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និងអាជីវកម្មនានា មិនទាន់រកឃើញការប្រើប្រាស់ ការងារដោយបង្ខំ និង ពលកម្មកុមារក្តី ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្មផលិតផល និង អាជីវកម្មនានា ត្រូវបន្តអនុវត្តឲ្យបានម៉ឺងម៉ាត់តាមច្បាប់ស្តីពីការងារ និងប្រកាសដែលពាក់ព័ន្ធ នឹងលក្ខខណ្ឌការងារ និងពលកម្មកុមារ" ។

ក្រសួងការងារបានអះអាងថា នឹងបន្តប្រឆាំងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចពលកម្ម និងហាម ឃាត់ដាច់ខាតការប្រើប្រាស់បំណុល នៃទំនាក់ទំនងបុគ្គល និងបំណុលនៃគ្រឹះស្ថាន ហិរញ្ញវត្ថុ មកដាក់បន្ទុកសេរីភាពការងារ របស់កម្មករ និយោជិត ទោះបីក្នុងលក្ខណៈម៉ៅការ ឬកិច្ចសន្យា បន្តក្តី។ ប្រភពដដែលបន្តថា គ្រប់អាជីវកម្ម សិប្បកម្ម និងសេវាកម្មទាំងអស់ មិនត្រូវប្រើប្រាស់កុមារ ក្រោមអាយុ១៥ឆ្នាំ ។ ដោយឡែកមណ្ឌលកំសាន្តមនុស្សពេញវ័យ ហាមឃាត់ដាច់ខាតការ ប្រើប្រាស់អនីតិជន (កុមារអាយុក្រោម១៨ឆ្នាំ) និងការជួញដូរកម្លាំងពលកម្ម។ ក្នុងករណីក្រុមអធិការកិច្ចការងារ របស់ក្រសួង រកឃើញនូវកំហុសទាំងនេះ ក្រសួងនឹងធ្វើការ ផាកពិន័យ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមានផងដែរ។ ជាមួយគ្នានេះដែរ ក្រសួងការងារ សង្ឃឹមថា គ្រប់មន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត អង្គភាពពាក់ព័ន្ធ អាជ្ញាធរដែនដី ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស គ្រឹះស្ថាន សិប្បកម្ម ផលិតផល និងអាជីវកម្មនានា ខិតខំសហការផ្សព្វផ្សាយ និងអនុវត្តឲ្យបានត្រឹម ត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព៕ ដោយ ៖ អេង ប៊ូឆេង

### ប្រទេសសមាជិកអាស៊ានទាំង១០ គ្រោងចុះកិច្ចព្រមព្រៀងរួមគ្នាលើការធ្វើបត្យាប័ននិងផ្ទេរទណ្ឌិត

http://km.rfi.fr/cambodia/cambodia ដោយ អេង គីមហុង15/10/2018

ប្រទេសសមាជិកអាស៊ានទាំង១០ បានឯកភាពនឹងបង្កើតកិច្ចព្រមព្រៀងធ្វើបត្យាប័ននិងផ្ទេរទណ្ឌិត។ សម្រាប់បរិបទប្រទេសកម្ពុជា ក្រសួងយុត្តិធម៌ឲ្យដឹងថា កិច្ចព្រមព្រៀងនេះមានសារៈសំខាន់ចំពោះកម្ពុជា និងសន្តិសុខក្នុងតំបន់ទាំងមូល។ តាមរយៈកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាស៊ាននៅប្រទេសឡាវ កាលពីពេលថ្មីៗនេះ កិច្ចព្រមព្រៀងស្តីពីការធ្វើបត្យាប័ន និងផ្ទេរទណ្ឌិតនេះ ក៏គ្រោងនឹងអនុវត្តឆាប់ៗនេះដែរ។

លោក ជិន ម៉ាលីន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅចន្ទទី១៥តុលានេះថា ការណ៍ដែលប្រទេសសមាជិកអាស៊ានទាំង១០បានឯកភាពនឹងបង្កើតកិច្ចព្រមព្រៀងធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិត គឺក្នុងគោលបំណងដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនមួយចំនួន។ ហើយដំណើរការរៀបចំកិច្ចព្រមព្រៀងស្តីពីការធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិតនេះ ធ្វើឡើងដោយយកបទពិសោធន៍កន្លងមកតាមកិច្ចព្រមព្រៀងទ្វេភាគី រវាងប្រទេស និងប្រទេស ក្នុងការធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិត។ បើតាមលោក ជិន ម៉ាលីន កិច្ចព្រមព្រៀងនេះ នឹងលេចចេញជារូបរាងក្នុងពេលឆាប់ៗនេះ។ បន្ទាប់ពីទទួលបានភាពស្របច្បាប់ក្នុងការអនុវត្តកិច្ចព្រមព្រៀងរួមគ្នានេះ ហើយបណ្តាប្រទេសសមាជិកអាស៊ាន អាចសហការគ្នាបានក្នុងការបញ្ជូនជនល្មើស ឬជនដែលសមត្ថកិច្ចតាមចាប់ខ្លួន។

សូមបញ្ជាក់ថា ការមូលមាត់គ្នារវាងប្រទេសសមាជិកអាស៊ានទាំង១០ ក្នុងការរៀបចំកិច្ចព្រមព្រៀងស្តីពីការធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិតនេះ បានធ្វើឡើងនៅក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីច្បាប់អាស៊ានលើកទី១០ ដែលប្រទេសឡាវ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកាលពីថ្ងៃទី១២ ខែតុលា។

លោក អំ សំអាត មន្ត្រីស៊ើបអង្កេតផ្នែកសិទ្ធិមនុស្សនៃអង្គការលីកាដូ មើលឃើញថា ជារឿងមួយល្អ ដែលប្រទេសអាស៊ានបានចងក្រងកិច្ចព្រមព្រៀងស្តីពីការធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិត។ ល្អព្រោះថា សម្រាប់បរិបទប្រទេសកម្ពុជា លោក អំ សំអាត ថា ការផ្ទេរទណ្ឌិតមកឃុំខ្លួននៅក្នុងប្រទេសបង្ហាញថា ពួកគេមិនឯកា។ ប៉ុន្តែ លោក អំ សំអាត នៅតែមានក្តីព្រួយបារម្ភថា ការធ្វើបច្ចាប័ន អាចបង្កផលវិបាក និងជះឥទ្ធិពលដល់ពលករចំណាកស្រុក ខណៈពលរដ្ឋកម្ពុជាបានចេញចូលជាប់មិនដាច់នៅក្នុងដំណើរស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ ដែលជាប្រទេសសមាជិកអាស៊ានមួយដែរនោះ។ ហើយក្តីព្រួយបារម្ភម្យ៉ាងទៀត គឺភាពកាន់តែចង្អៀតណែននៅក្នុងពន្ធនាគារនាពេលអនាគត។ នេះបើតាមលោក អំ សំអាត ។

## វីដេអូឯកសារ៖ «ម្តាយរបស់ខ្ញុំលក់ខ្ញុំ» នៅកម្ពុជាព្រហ្មចារីលក់ដូចទំនិញ?

https://jongruk.com/archives/ By jongruk21 October 15, 2018

ឯកសារភាពយន្តមួយរបស់សារព័ត៌មាន RT បានបង្ហាញថា ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់រស់នៅក្នុងភាពក្រីក្រខ្លាំង ពឹងផ្អែកលើប្រាក់ពីការងារបុរស ឬកម្លាំងរបស់បុរស ប៉ុន្តែនៅពេលដែលការចំណាយនៅក្នុងគ្រួសារច្រើនហួសប្រមាណពេក ធ្វើអោយក្រុមគ្រួសារក្រីក្រមួយចំនួនគ្មានជម្រើសអ្វី ក្រៅពីយកទុនតែមួយគត់របស់កូនស្រីគឺព្រហ្មចារី លក់ធ្វើទ្រព្យសម្បត្តិ ។ បុរសជាច្រើនចង់ចំណាយប្រាក់ ដើម្បីរួមភេទជាមួយនារីព្រហ្មចារី ដោយសារតែរឿងព្រេងនិទានក្នុងស្រុកនិយាយថា វានឹងផ្តល់ឱ្យពួកគេនូវកម្លាំង និងជីវិតយូរអង្វែង ។ ក្រុមគ្រួសារក្រីក្របានលះបង់ព្រហ្មចារីកូនរបស់ពួកគេ ដោយលក់តម្លៃយ៉ាងតិចជាង៤០០ដុល្លារអាមេរិក ។

នៅពេលភាពក្រមុំព្រហ្មចារីយ៍របស់ពួកគេ ត្រូវបានបាត់បង់ ក្មេងស្រីទាំងនោះតែងតែត្រូវបានគេធ្វើបាប គេរំលោភបំពាន គេមើលងាយជាដើម ។ នៅក្នុងក្លឹបរាត្រី និងខារ៉ាអូខេ កុមារីវ័យជំទង់ត្រូវផឹកគ្រឿងស្រវឹង អាចនឹងឈានដល់ការលក់ផ្លូវភេទ ពេលខ្លះបម្រើអតិថិជនបួនឬប្រាំនាក់ ក្នុងមួយថ្ងៃ ។ RT សារព័ត៌មានធំមួយរបស់រុស្ស៊ីបានធ្វើដំណើរមកប្រទេសកម្ពុជា ដោយសហការជាមួយ អង្គភាពការពារកុមារកម្ពុជា ហៅកាត់ថា (CPU) ដើម្បីជួបក្មេងស្រីរងគ្រោះ និងម្តាយ ដែលបានបញ្ជូនពួកគេ(ក្មេងស្រីរងគ្រោះ) ទៅក្នុងឧស្សាហកម្មផ្លូវភេទ ។ ទាំងនេះគឺជារឿងដែលគួរឱ្យព្រួយបារម្ភ អំពីភាពក្រីក្រខ្លាំង ដែលកុមារកម្ពុជាត្រូវស្តាប់បង្គាប់មាតាបិតា ដែលបង្ខំពួកគេឱ្យដេកជាមួយអ្នកដទៃ ។ ទោះជាយ៉ាងណា អង្គភាពការពារកុមារ កំពុងធ្វើការលើរឿងនេះ ដើម្បីជួយសង្គ្រោះកុមារកម្ពុជាទាំងនោះ ផងដែរ ។

## ពលករខ្មែរម្នាក់ មាននាទីជា កម្មករអគ្គីសនី ត្រូវបានចរន្តអគ្គីសនីឆក់ស្លាប់ យ៉ាងអាណោចអាធ័ម នៅលើបង្គោលភ្លើង

http://khmer.peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី16 ខែ10 ឆ្នាំ2018 ម៉ោង 12:22 PM

ប្រទេសថៃ ៖ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ កន្លងទៅ ពលករខ្មែរម្នាក់ដែលមាននាទីជា កម្មករអគ្គីសនី ក្នុងខេត្តឈុនបុរី ត្រូវបានចរន្តឆក់ស្លាប់ យ៉ាងអាណោចអាធ័មនៅលើបង្គោលភ្លើងដោយមានអណ្តាតភ្លើងឆេះលើខ្លួនប្រាណផងដែរខណៈ ដែលក្រុមការងារមានទាំងខ្មែរនិងមានទាំងកម្មករថៃ បានចុះត្រួតពិនិត្យខ្សែជាប្រចាំហើយក៏បាន កាត់ផ្តាច់ចរន្តយ៉ាងមានសុវត្ថិភាពផងដែរ។

ហេតុការណ៍ដែលធ្វើអោយមានការភ្ញាក់ផ្អើលនេះបានកើតឡើងនៅលើកំណាត់ផ្លូវលេខ៣៣១ក្បែរជើងភ្នំកាប៊ីនបុរីស្ថិតក្នុងភូមិ ១០ឃុំណងព្រឺស្រុកផាណាត់និគម ខេត្តឈុនបុរីប្រទេសថៃ ដោយនៅទីនោះគេសង្កេតឃើញមានភ្នាក់ងារអគ្គីសនីឯកជនម្នាក់កំពុងជាប់នៅលើបង្គោលភ្លើងដោយលើ ខ្លួនប្រាណមានអណ្តាតភ្លើងឆេះពេលវាលផងដែរដែលបញ្ហានេះគឺបណ្តាលមកពីការការឆក់ខ្សែភ្លើង ។ នៅទីនោះដែរក៏មានអាជ្ញាធរមូលដ្ឋានក៏ដូចជាក្រុមការងារនៃអង្គភាពអគ្គីសនីបានយករថយន្តស្ទូចមកឡើងដោះយកជនរងគ្រោះចុះពីលើបង្គោលដើម្បីប្រគល់ទៅអោយសមត្ថកិច្ចពិនិត្យនិងធ្វើកោសល្យវិច្ច័យដោយចង់ដឹងថា តើការឆក់ស្លាប់នេះបណ្តាលមកពីមូលហេតុអ្វីព្រោះមុននឹងឡើងទៅលើបង្គោលគឺក្រុមការងារ មានការកាត់ផ្តាច់ចរន្តរួចជាស្រេចដើម្បីសុវត្ថិភាពរបស់ពួកគេចុះហេតុអ្វីបានជាត្រូវភ្លើងឆក់?

បើតាមការលើកឡើងពីសាក្សីម្នាក់ឈ្មោះ ផៃសាល កែវសុខជាកម្មករអគ្គីសនីរបស់ក្រុមហ៊ុនឯកជនមួយជាមួយនិងជនរងគ្រោះដែរនោះបាននិយាយថានៅមុនពេលកើតហេតុគឺពួកគេបានទទួលបញ្ជាពីប្រធានក្រុមហ៊ុនអោយ ចុះត្រួតពិនិត្យទៅលើខ្សែ ដោយសារតែក្រុមហ៊ុននេះជអ្នកម៉ៅការផ្តាច់មុខពីអង្គភាពអគ្គីសនីនៅក្នុងតំបន់នេះទើបពួកគេបានធ្វើការកាត់ផ្តាច់ចរន្តនៅខ្សែដើមទីរួចជាស្រេចទើបនាំគ្នាឡើ ងទៅលើបង្គោលចំនួន ៣ នាក់ក្នុងនោះក៏មានជនរងគ្រោះម្នាក់ដែរ ។ ភ្លាមៗនោះដែរក៏ស្រាប់តែជនរងគ្រោះដែលជាពលករខ្មែរឈ្មោះ សឿ ជំនោរត្រូវបានចរន្តអគ្គីសនីឆក់យ៉ាង សាហាវជាទីបំផុតដោយមិនអាចមានវិធីណាមួយជួយជនរងគ្រោះបានឡើយឯកម្មរថៃ ២ នាក់ទៀតបានរួចផុត ពីសេចក្តីស្លាប់ដោយសារតែពួកគេនៅលើបង្គោលតែនៅខាងក្រោមខ្សែ ។ ដោយបច្ចុប្បន្ននេះក្រុមតម្រួតថៃបានបញ្ជូនសពទៅកាន់កន្លែងត្រួតពិនិត្យ ដោយឡែកកម្មករនិងមនុស្សដែលពក់ព័ន្ធគឺតម្រួតនឹងនាំខ្លួនយកទៅសាកសួរ ដើម្បីចង់ដឹងអំពីមូលហេតុនៃការឆក់ស្លាប់នេះ ៕

## វិបត្តិខ្វះកម្លាំងពលកម្មបង្ខំឲ្យជប៉ុនព្យាយាមទាក់ទាញពលករបរទេសរាប់ម៉ឺននាក់បន្ថែម

https://thmeythmey.com/ 12, Oct 2018 , 5:45 pm ដោយ: អ៊ឹម ម៉េងស៊ាង

រដ្ឋាភិបាលក្រុងតូក្យូនៅថ្ងៃទី១២ ខែតុលា បានបង្ហាញគម្រោងមួយដើម្បីទាក់ទាញពលករបរទេសឲ្យមកធ្វើការក្នុងប្រទេសខ្លួន ខណៈមហាអំណាចសេដ្ឋកិច្ចលំដាប់ទីបីនេះ កំពុងខ្វះខាតកម្លាំងពលកម្ម។ បញ្ហានេះបង្កឡើងដោយកំណើនមនុស្សចាស់ និងការថយចុះនៃកំណើនប្រជាជនក្នុងប្រទេស។ ផែនការថ្មីនេះមានគោលបំណងបំពេញនូវចន្លោះខ្វះខាតកម្លាំងពលកម្មនៅក្នុងវិស័យសំខាន់ៗមួយចំនួនរួមមាន កសិកម្ម, សុខាភិបាល, សំណង់, សណ្ឋាគារ និងការសាងសង់នាវាជាដើម។ នេះបើតាមទីភ្នាក់ងារព័ត៌មាន AFP ។ ក្នុងសេចក្តីព្រាងច្បាប់ថ្មីដែលមានគោលដៅទាក់ទាញពលករបរទេសនោះ ជប៉ុនតម្រូវឲ្យពលករមានជំនាញស្របតាមវិស័យដែលខ្លួនកំពុងខ្វះខាតខាងលើនេះ ហើយពួកគេនឹងអាចទទួលបានទិដ្ឋាការពិសេសមួយ ដែលអនុញ្ញាតឲ្យពួកគេអាចធ្វើការនៅប្រទេសជប៉ុន រយៈពេល៥ឆ្នាំតែម្តង។ លើសពីនេះពលករក្នុងវិស័យទាំងនោះដែលមានសមត្ថភាពខ្លាំង និងប្រលងជាប់ការ

សាកល្បងសមត្ថភាពភាសាជប៉ុនថែមទៀតនោះ នឹងត្រូវបានគេអនុញ្ញាតឲ្យនាំយកសមាជិកគ្រួសារ ព្រមទាំងអាចទទួលបានសញ្ជាតិអចិន្ត្រៃយ៍ផងដែរ។

អ្នកនាំពាក្យរដ្ឋាភិបាលជប៉ុន Yoshihide Suga បានប្រាប់អ្នកសារព័ត៌មាននៅថ្ងៃសុក្រទី១២ ខែតុលាថា សេចក្តីព្រាងច្បាប់នេះនឹងត្រូវបញ្ជូនទៅកាន់រដ្ឋសភាក្នុងពេលឆាប់ៗនេះ ហើយអាចនឹងចូលជាធរមាន នាខែមេសាឆ្នាំ២០១៩ខាងមុខ។ ទន្ទឹមនឹងនេះលោក Suga បានបញ្ជាក់ទៀតថា ជប៉ុននឹងមិនពឹងផ្អែកខ្លាំងជ្រុលទៅលើជនអន្តោប្រវេសន៍បរទេសនោះឡើយ។ ហើយលោកបានសង្កត់ធ្ងន់ថា គោលនយោបាយអន្តោប្រវេសន៍របស់ជប៉ុននឹងមិនត្រូវផ្លាស់ប្តូរនោះទេ។ ការបកស្រាយរបស់លោកបែបនេះគឺធ្វើឡើងដើម្បីឆ្លើយតបនឹងសំណួរដែលថា គម្រោងទាក់ទាញពលករបរទេសថ្មីនេះ អាចជាការផ្លាស់ប្តូរយ៉ាងគំហុកក្នុងគោលនយោបាយអន្តោប្រវេសន៍ជប៉ុន និងអាចឆ្ពោះទៅរកការទទួលយកចំនួនពលករបរទេសច្រើនសន្ធឹកសន្ធាប់ផងនោះ។ ទាក់ទិននឹងរឿងនេះរដ្ឋាភិបាលពុំទាន់បានកំណត់តួលេខច្បាស់លាស់ចំពោះចំនួនពលករបរទេសក្នុងសំណើថ្មីនេះនៅឡើយទេ ប៉ុន្តែសារព័ត៌មានក្នុងស្រុកបានបង្ហើបថា រដ្ឋាភិបាលត្រៀមទទួលយក ពលករបរទេសច្រើនជាង៥០ម៉ឺននាក់ឲ្យមកធ្វើការក្នុងប្រទេសជប៉ុន គិតត្រឹមឆ្នាំ២០២៥។

យ៉ាងណាមិញរដ្ឋាភិបាលលោក ស៊ីនហ្សូ អាបេ បានអះអាងថា កំណែទម្រង់ថ្មីនេះពុំបានធ្វើឡើង ក្នុងគោលបំណងរុះរើគោលនយោបាយអន្តោប្រវេសន៍របស់ជប៉ុនដែលមានទាំងស្រុងឡើយ។ ចំណែកការទទួលយកជនអន្តោប្រវេសន៍ទ្រង់ទ្រាយធំក៏នឹងមិនអាចកើតឡើងនោះដែរ។ កន្លងមក ក្រុមអ្នកជំនួញធ្លាប់បានបញ្ចុះបញ្ចូលរដ្ឋាភិបាលជប៉ុនឲ្យមានការបន្ធូរបន្ថយការរឹតត្បិតក្នុងច្បាប់អន្តោប្រវេសន៍ធ្វើឲ្យក្រុមហ៊ុនពិបាកស្វែងរកពលករ។ ជប៉ុនជាទីកន្លែងដែលនិកម្មភាព (គ្មានការងារធ្វើ) ទាបត្រឹមតែ២,៥ភាគរយ ខណៈកន្លែងការងារមានច្រើនជាងចំនួនពលករដែលស្វែងរកការងារធ្វើទៀត។ បើពិតទៅជប៉ុនមានទំនៀមទម្លាប់ប្រុងប្រយ័ត្នខ្ពស់ពេលទទួលយកពលករគ្មានជំនាញពីបរទេស ហើយបច្ចុប្បន្ន ប្រទេសកោះអាស៊ីបូព៌ាមួយនេះក៏បានកំណត់ចំនួនសម្រាប់ផ្តល់សញ្ជាតិដល់បុគ្គល ដែលមានជំនាញខ្ពស់ថែមទៀតផង។ ច្បាប់នេះត្រូវបានអនុគ្រោះដល់ជនជាតិអាមេរិកខាងត្បូង ដែលមានដើមកំណើតជប៉ុនតែមួយប៉ុណ្ណោះ។

យោងតាមទិន្នន័យរបស់រដ្ឋាភិបាលជប៉ុន ពលករបរទេសប្រមាណ១,២៨លាននាក់បានធ្វើការក្នុងប្រទេសជប៉ុន ក្នុងឆ្នាំ២០១៧ ដែលចំនួននេះគឺច្រើនជាង២ដង បើធៀបនឹងចំនួនពលករបរទេសកាលពីមួយទសវត្សន៍មុន។ យ៉ាងណាមិញពលករច្រើនជាង៤៥ម៉ឺននាក់ ជាប្តី/ប្រពន្ធរបស់ពលរដ្ឋជប៉ុន, ជនជាតិកូរ៉េដែលតាំងទីជាយូរមកហើយក្នុងប្រទេសជប៉ុន ឬក៏ជនបរទេសដែលមានដើមកំណើតជប៉ុន ជាជាងពលករដែលមកកាន់ប្រទេសជប៉ុនដើម្បីស្វែងរកការងារធ្វើ។ ទិន្នន័យដដែលបានបង្ហាញថា ជនបរទេសប្រមាណ៣០ម៉ឺននាក់ផ្សេងទៀតជាសិស្សឬនិស្សិត ដែលត្រូវបានគេអនុញ្ញាឲ្យធ្វើការងារក្រៅម៉ោងអំឡុងពេលសិស្សារបស់ពួកគេ។ ប៉ុន្តែពួកគេនឹងត្រូវត្រឡប់ទៅកាន់មាតុប្រទេសវិញនាពេលក្រោយទៀត។ គិតត្រឹមចុងឆ្នាំ២០១៧កន្លងទៅ ជប៉ុនមានពលករជំនាញពីបរទេសតិចជាង ២៤ម៉ឺននាក់ និងអ្នកហាត់ការពីបរទេសប្រមាណ២៥ម៉ឺននាក់ប៉ុណ្ណោះក្នុងប្រទេស។ ជាមួយគ្នានេះក្រុងតូក្យូក៏មានកិច្ចព្រមព្រៀងទ្វេភាគីដែលទទួលយកចំនួនពលករជាផ្នែកគិលានុបដ្ឋាយិកា និងថែទាំក្នុងចំនួនកំណត់ច្បាស់លាស់មួយពីប្រទេសខ្លះនៅទ្វីបអាស៊ីផងដែរ៕

## នារីម្នាក់ស្គាល់រសជាតិហើយ! ចូលគេងនៅម៉ោង៣ភ្លឺ និងក្រោកម៉ោង ៦ និង ៣០ នាទី បន្តធ្វើការរហូត នេះហើយជីវិតពលករស្រុកគេ!!

http://www.cen.com.kh/archives/ October 16, 2018

មនុស្សភាគច្រើនតែងគិតថា ធ្វើការជាពលករចំណាកស្រុកនៅប្រទេសមានសេដ្ឋកិច្ចជឿនលឿន គឺមានភាពងាយស្រួលណាស់ និងអាចរកបានប្រាក់ចំណូលខ្ពស់ទៀតផង ។ ប៉ុន្តែ ជាតុពិតនោះ គឺពួកគេលំបាកណាស់

ព្រោះមានរឿងរ៉ាវជាច្រើន ដែលពួកគេមួយចំនួនត្រូវបានរំលោភបំពានដោយថៅកែរបស់ពួកគេ ដូចជាពេលវេលាសម្រាកជាដើម ។ ជាក់ស្តែង នារីជាពលករជនជាតិហ្វីលីពីនម្នាក់ បានចែករំលែកនូវអ្វីដែលនាងកំពុងជួបប្រទះជាមួយការងាររបស់នាង ។ យោងតាម Kami នាងបានចូលគេងនៅម៉ោង ៣ ព្រឹក ហើយបន្ទាប់មក នាងត្រូវក្រោកពីដំណេកមុនម៉ោង ៦ និង ៣០ នាទី ព្រឹក ព្រោះតែថៅកែរបស់នាងនឹងមានភ្ញៀវមួយចំនួន ។ ពិតមែនហើយ អ្នកទាំងអស់គ្នាប្រាកដណាស់នឹងគិតថា ស្ថានភាពបែបនេះគួរឲ្យព្រួយបារម្ភណាស់ ព្រោះថា វានឹងប៉ះពាល់ដល់សុខភាពរបស់អ្នកពុំខានឡើយ ប្រសិនបើអ្នកតែងតែកំពុងជួបប្រទះស្ថានភាពបែបនេះដូចជារូបនាង ។ ដើម្បីធ្វើឲ្យអារម្មណ៍ធូរស្រាលបន្តិច នាងបានថតរូប selfie ទុកមួយចំនួន និងរូបបែបលក្ខណៈសប្បាយលេងសើចខ្លះៗ ដើម្បីបង្ហោះឲ្យបងប្អូនបានឃើញ ។ នាងបាននិយាយនៅក្នុងចុងបញ្ចប់នៃការផុសថា នាងមានមោទនភាពយ៉ាងខ្លាំងចំពោះមិត្តភក្តិជិតស្និទ្ធដែលជាពលករជនជាតិហ្វីលីពីនរបស់ដែលបានជួយថតបង្ហោះ និងក៏សូមអរគុណអ្នកទាំងអស់គ្នា ដែលបានអានរឿងរ៉ាវរបស់នាង ។ **តើអ្នកយល់ឃើញយ៉ាងណាដែរ អំពីស្ថានភាពរបស់នាង!? ដោយៈ ឧត្តម ប្រភព៖** nobledrift

## *ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨*

## នគរបាលកម្ពុជាចំនួន៣០រូប ទទួលការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពជំនាញស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យា

http://akp.gov.kh/kh/archives/ AKP ភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

អគ្គស្នងការដ្ឋាននគរបាលជាតិ បានបើកវគ្គបណ្តុះបណ្តាលជំនាញស៊ើបអង្កេតបទល្មើស បច្ចេកវិទ្យាដល់មន្ត្រីនគរបាលជាតិចំនួន៣០រូបដើម្បីពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងការរីកចម្រើននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

ឯកឧត្តម នាយឧត្តមសេនីយ៍ ឆៃ ស៊ីណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ បានមានប្រសាសន៍ ថា ការប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យាគឺមានកត្តាជាច្រើនដែលគួបផ្សំទើប អាចធ្វើការ តស៊ូបាន ហើយកត្តាសំខាន់ចម្បងបំផុតគឺធនធានមនុស្ស។ ក្នុងវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យា នាព្រឹកថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៨នេះ ឯកឧត្តម នាយឧត្តមសេនីយ៍ ឆៃ ស៊ីណារិទ្ធ បានបញ្ជាក់ថា បើទោះបីជាកម្ពុជាមានឧបករណ៍បច្ចេកវិទ្យាទំនើបយ៉ាងណាក៏ដោយ តែបើធនធានមនុស្សរបស់ យើងមិនមានសមត្ថភាពគ្រប់គ្រាន់ប្រើប្រាស់ទេ។ ឯកឧត្តមបានបន្តថា "យើងមិនអាចនឹង ធ្វើឱ្យបច្ចេកវិទ្យាទាំងអស់នោះឆ្លើយតប និងអាចប្រើប្រាស់សម្រាប់តស៊ូប្រយុទ្ធប្រឆាំង លើបទ ល្មើសបច្ចេកវិទ្យាបានទេ ប៉ុន្តែផ្ទុយទៅវិញបើយើងមានសមត្ថភាព តែយើងគ្មានឧបករណ៍បច្ចេកទេសក៏វាមិនអាចធ្វើទៅបាននោះដែរ"។ ឯកឧត្តម នាយឧត្តមសេនីយ៍បានបន្តទៀតថា ទន្ទឹមនឹងការវិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាទំនើបជឿនលឿន មន្ត្រីនគរបាលកម្ពុជា ក៏ត្រូវតែចាំបាច់ មានសមត្ថភាពគ្រប់គ្រាន់នូវវិធានច្បាប់ ដើម្បីជាមូលដ្ឋាននៃការអនុវត្តកិច្ចការជំនាញ។ ទន្ទឹមនេះ ក៏មានរឿងជាច្រើនដែលចំណុចខ្លះ យើងឃើញថាការប្រព្រឹត្តខ្លះរំលោភបំពានទៅដល់សិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ប៉ុន្តែដល់វិធានច្បាប់របស់យើងនៅមិនទាន់មានគ្រប់គ្រាន់ ដែលជាហេតុធ្វើឱ្យសមត្ថកិច្ចរបស់យើងលំបាកក្នុងការប្រតិបត្តិការ។

ឯកឧត្តមបានលើកឡើងថា កត្តាធនធានមនុស្សនេះ គឺជាកត្តាចាំបាច់ណាស់ ដែលកងកម្លាំងនគរបាលជាតិកំពុងតែខិតខំប្រឹងប្រែងធ្វើយ៉ាងណាកសាងមូលដ្ឋានច្បាប់ លើការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យានេះសម្រាប់ទុកជាមូលដ្ឋានក្នុងការអនុវត្ត និងបង្ក្រាបនូវ បទល្មើសនានា។ ជាមួយគ្នានេះ តាមការកត់សម្គាល់ឃើញថាពួកឧក្រិដ្ឋជនបច្ចេកវិទ្យា គឺ កាន់តែមានការវិវឌ្ឍឥតឈប់ឈរ ដើម្បីរកគ្រប់វិធីធ្វើយ៉ាងណាសំដៅប្រព្រឹត្តបទល្មើសនៅ ក្នុងពិភពលោករបស់យើងទាំងមូល គឺបានមើលឃើញថា មានដូចជាបទល្មើសអនឡាញ ល្បែងស៊ីសង, ឆបោក, ជួញដូរគ្រឿងញៀន ក៏ដូចជាជួញដូរមនុស្ស ស្ត្រី និងកុមារ ដែលចាំបាច់ត្រូវតែយកចិត្ត ទុកដាក់ ដោយមិន

អាចធ្វេសប្រហែសបានឡើយ។ ឯកឧត្តម នាយឧត្តមសេនីយ៍បានបន្ថែមថា ចំពោះប្រទេសកម្ពុជាក៏ជាប្រទេសមួយ សម្រាប់គោលដៅមួយដែលពួកឧក្រិដ្ឋជនទាំងនេះធ្លាប់បានប្រព្រឹត្ត ហើយកម្លាំងនគរបាល កម្ពុជាក៏បានបង្ក្រាបជាបន្តបន្ទាប់ផងដែរ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យានេះ មាន រយៈពេលពីរសប្តាហ៍ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ដោយមានមន្ត្រីនគ របាលជាសិក្ខាកាមមកពីនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា២៥រូប និងមកពីនាយកដ្ឋាន ស៊ើបការខាងក្រៅ និងបច្ចេកទេស ៥រូប សរុបចំនួន ៣០រូប ៕

*ដោយ ចាន់ សុជីវង្ស*

## ឃាត់ខ្លួនជនសង្ស័យប្រុស-ស្រី២នាក់ពាក់ព័ន្ធករណីនាំមនុស្សឆ្លងដែនទៅប្រទេសចិនដោយខុសច្បាប់

http://ppd-news.net/ Posted By: admin *October 17, 2018*

ខេត្តត្បូងឃ្មុំ ៖ កម្លាំងជំនាញការិយាយប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយ អធិការដ្ឋានស្រុកត្បូងឃ្មុំ និងប៉ុស្តិ៍នគរបាល រដ្ឋបាលដីពោទី២ កាលពីល្ងាចថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ម្សិលមិញ បានចុះស្រាវជ្រាវស៊ើបអង្កេតឈានដល់ឃាត់ខ្លួនជនសង្ស័យចំនួន២នាក់ ១/ឈ្មោះ ឆេង ពៅ ភេទស្រី អាយុ៤៥ និងម្នាក់ទៀតឈ្មោះ ខន កុយ ភេទប្រុស អាយុ២៤ឆ្នាំ តាមបញ្ជារបស់លោកព្រះរាជអាជ្ញារង ប៉ុក តារា ពាក់ព័ន្ធនឹងករណីនាំមនុស្សយកទៅលក់នៅប្រទេសចិន។ បច្ចុប្បន្នកំលាំងជំនាញការិយាល័យប្រឆាំងការជួញដូមនុស្ស និងការពារអនីតិជន នៃស្នងការរដ្ឋាននគរបាល ខេត្តត្បូងឃ្មុំ កសាងសំណុំរឿងចាត់ ការតាមនីតិវិធីច្បាប់៕ ដោយ ៖ ជឹម ទូច

## *ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨*

## របាយការណ៍ «ឥដ្ឋឈាម»៖ ពលរដ្ឋជាច្រើនគ្រួសារធ្លាក់ចូល ទៅក្នុងទាសភាពសម័យទំនើបនៃឧស្សាហកម្មឡឥដ្ឋ

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 17 October 2018 20:02 ICT

**ភ្នំពេញៈ** ភាពរីកចម្រើនខ្លាំង នៃវិស័យសំណង់របស់ប្រទេសកម្ពុជា បានជំរុញឲ្យប្រជាពលរដ្ឋក្រីក្រជាច្រើន គ្រួសារធ្លាក់ចូលទៅក្នុងទាសភាពសម័យទំនើប នៅក្នុងឧស្សាហកម្មឡឥដ្ឋតាមរយៈការចងដោយបំណុល។ នេះបើយោងតាមរបាយការណ៍មួយ របស់ក្រុមអ្នកស្រាវជ្រាវ ពីសាកលវិទ្យាល័យ Royal Holloway ក្នុងទីក្រុងឡុងដ៍។

ការស្រាវជ្រាវដែលមានចំណងជើងថា «ឥដ្ឋឈាម» ដែលចេញកាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៨ បន្ទាប់ពីតម្លៃឥដ្ឋក្នុងប្រទេសកម្ពុជា បានឡើងថ្លៃយ៉ាងខ្លាំង នៅក្នុងរយៈកាលមួយឆ្នាំចុងក្រោយនេះ ដោយសារតែតម្រូវការកើនឡើង ពីការអភិវឌ្ឍទីក្រុងព្រះសីហនុនិងភ្នំពេញ។ វិស័យសំណង់របស់កម្ពុជា បានរីកចម្រើនយ៉ាងខ្លាំង រួមមានដូចជាការសាងសង់ផ្សារទំនើបថ្មីៗ អចលនទ្រព្យលំនៅឋាន សណ្ឋាគារ អគារការិយាល័យ រោងចក្រ និងខុនដូ ហើយនេះ ធ្វើឲ្យមានតម្រូវការខ្ពស់ក្នុងការឲ្យមានការផលិតឥដ្ឋច្រើន។ ឧស្សាហកម្មនេះ បានរុញមនុស្សពេញវ័យ និងកុមារ ចូលទៅក្នុងកម្លាំងការងារសំខាន់នៅក្នុងការផលិតឥដ្ឋ និងធ្លាក់ជាប់ផុងក្នុងបំណុលផងដែរ។ ក្រុមអ្នកស្រាវជ្រាវបានថ្លែងថា៖ «ពលរដ្ឋរាប់ម៉ឺនគ្រួសារ ដែលជាប់បំណុលគេក្នុងប្រទេសកម្ពុជា ត្រូវទៅធ្វើការងារដុតឥដ្ឋ ធ្វើឥដ្ឋ លើកឥដ្ឋក្នុងស្ថានភាពគ្រោះថ្នាក់ ដើម្បីបំពេញតម្រូវការឥដ្ឋក្នុងរាជធានីភ្នំពេញ...។ ម្ចាស់ឡឥដ្ឋសងបំណុលរបស់គ្រួសារទាំងនោះ និងផ្តល់កម្ចី ហើយជាថ្នូរមកវិញកម្មករនិងគ្រួសាររបស់ពួកគេត្រូវបានបង្ខំឲ្យចូលទៅក្នុងរណ្តៅបំណុលជាមួយម្ចាស់ឡឥដ្ឋរហូតដល់សងបំណុលរួច»។

ប៉ុន្តែ លោក ឈាង ស៊ុយហ៊ាង ប្រធានសមាគមឡឥដ្ឋចំនួនពីរ ដែលតំណាងឲ្យរោងសិប្បកម្មផលិតឥដ្ឋជាង ១០០ ក្នុងខេត្តកណ្តាល នៅថ្ងៃទី ១៧ ខែតុលា បានបដិសេធថា មិនមានពលកម្មកុមារ នៅក្នុងរោងចក្រផលិតឥដ្ឋនោះទេ។ លោកអះអាងថា មិនមានផលប៉ះពាល់អវិជ្ជមាន ឬគ្រោះថ្នាក់ទៅលើកម្មករឥដ្ឋនោះទេ ដោយសារអាជ្ញាធរនិងអង្គការក្នុងស្រុកបានជួយទប់ស្កាត់កុមារពីការធ្វើការងារនៅឡឥដ្ឋ។ លោកបានថ្លែងថា៖ «ឥឡូវនេះមិនមានផលប៉ះពាល់ទៅលើពួកគេទេ ដៃឬជើងរបស់ពួកគេ មិនធ្លាក់ចូលទៅក្នុងម៉ាស៊ីន ហើយដៃឬជើងរបស់ពួកគេមិនត្រូវបានកាត់ដាច់ដូចមុនទេ ដោយសារយើងប្រើម៉ាស៊ីន ហើយមិនមានពលកម្មកុមារ នៅក្នុងឧស្សាហកម្មឥដ្ឋ ហើយយើងមិនអនុញ្ញាតឲ្យអនីតិជនធ្វើការ ដោយសារអង្គការបានពង្រឹង»។ ទោះជាយ៉ាងណា លោកបានទទួលស្គាល់ថា រាល់គ្រួសារកម្មករឥដ្ឋបានខ្ចីប្រាក់ពីម្ចាស់ឡឥដ្ឋ ហើយឲ្យពួកគេធ្វើការរហូតដល់សងបំណុលអស់ ឬម្ចាស់ឡឥដ្ឋ ចេញសងបំណុលធនាគារ និងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជំនួស ដោយសារបំណុលជាមួយម្ចាស់ឡឥដ្ឋមិនមានការប្រាក់។ លោកបានថ្លែងបន្តថា៖ «អ្នករាល់គ្នាជំពាក់បំណុលនៅក្នុងរោងចក្រឥដ្ឋ ហើយគ្រាន់តែថាជាបំណុលតិចឬច្រើនដោយសារពួកគេខ្ចីលុយពីធនាគារបន្ទាប់ពីពួកគេរកស៊ីខាត។ ពួកគេខ្ចីពីយើងដើម្បីសងធនាគារ ដោយសារយើងមិនមានការប្រាក់ ហេតុដូច្នេះ ពួកគេត្រូវតែធ្វើការសងបំណុល...។ លុយនេះគឺដូចចងពួកគេមិនឲ្យទៅធ្វើការនៅរោងចក្រឥដ្ឋដទៃទៀត»។

ស្ត្រីម្នាក់ដែលត្រូវបានបង្ហាញអត្តសញ្ញាណត្រឹមតែឈ្មោះ អាចរិយា នៅក្នុងរបាយការណ៍នេះ ដើម្បីការពារអត្តសញ្ញាណរបស់នាង បានថ្លែងថា«បំណុលរបស់ខ្ញុំបន្តកើនឡើងដោយសារឥឡូវនេះ ខ្ញុំមានប្តីនិងកូន...។ នាពេលអនាគតកូនរបស់ខ្ញុំ នឹងធ្វើការងារនេះដែរ»។

កាលពីសប្តាហ៍មុន ក្រសួងការងារ បានចេញសេចក្តីថ្លែងការណ៍មួយព្រមានចំពោះការប្រើប្រាស់ពលកម្មកុមារនៅក្នុងឧស្សាហកម្មឡឥដ្ឋនិងទម្រង់កេងប្រវ័ញ្ចដទៃៗទៀត ជាមួយនឹងការចងដោយបំណុល។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ មិនអាចទាក់ទងសុំអត្ថាធិប្បាយបានទេ៕ PS

## ស្ត្រីស៊ីឈ្នួលពពោះ នៅតែត្រូវបន្តជាប់ឃុំមុនកាត់ទោស

https://www.postkhmer.com/ គង់ មេត្តា | Publication date 17 October 2018 14:27 ICT

**ភ្នំពេញ៖** ណារីកំពុងដេកនៅលើគ្រែជិតទារិកាទើបនឹងកើតដែលនាងបានស៊ីឈ្នួលពពោះ។ នាងស្លៀកសារុង ពាក់អាវដៃវែង និងពាក់មួកគឺជាសម្លៀកបំពាក់ដែលស្ត្រីកម្ពុជាទើបឆ្លងទន្លេរួចតែងតែស្លៀកពាក់។ នាងដេកនៅក្នុងបន្ទប់មួយជាមួយនឹងស្ត្រីជាច្រើនដែលទើបឆ្លងទន្លេរួចនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកកាលពីដើមខែតុលា ឆ្នាំ ២០១៨ នេះ។ ប៉ុន្តែមានតែ ណារី ម្នាក់ប៉ុណ្ណោះដែលត្រូវបានឆ្មាំពន្ធនាគារអង្គុយយាមនៅមុខបន្ទប់របស់នាង។ ណារី ដែលមានកូន ៣ នាក់រួចទៅហើយនោះមិនបានឆ្លងទន្លេតាមធម្មតាទេ។ ណារី គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីចំនួន ៣២ នាក់ដែលកាលពីដំបូងត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលក្នុងនាមជាជនរងគ្រោះ ប៉ុន្តែនៅទីបំផុតនាងត្រូវបានចោទប្រកាន់ និងឃុំខ្លួនមុនការជំនុំជម្រះដោយចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ កាលពីខែកក្កដា ក្រោមការចោទប្រកាន់ពីបទប៉ុនប៉ងលក់ ទិញ ឬដោះដូរមនុស្សសម្រាប់ការផ្ទេរឆ្លងព្រំដែន និង ប្រព្រឹត្តជាអន្តរការីរវាងឪពុក ម្តាយសុំកូន និងស្ត្រីដែលមានផ្ទៃពោះតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌដែលអន្តរការីរវាងឪពុកម្តាយសុំកូន និងស្ត្រីមានផ្ទៃពោះអាចប្រឈមមុខនឹងការជាប់ពន្ធនាគារ ពី ១ ទៅ ៦ ខែ។

ប៉ុន្តែឥឡូវនេះស្ត្រីទាំង ៣២ នាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ១៦ ឧសភា ជាមន្ទីរពេទ្យនគរបាលដែលអាចប្រឈមនឹងទោសជាប់ពន្ធនាគារ ២០ ឆ្នាំ។ ណារី ជាកម្មការិនីកាត់ដេរនៅជាយរាជធានីភ្នំពេញ នាងបានដឹងអំពីការស៊ីឈ្នួលពពោះជំនួសតាមរយៈកម្មការិនីកាត់ដេរដូចគ្នាដែលធ្វើការនៅក្នុងរោងចក្រជាមួយនាងធ្លាប់បានស៊ីឈ្នួលពពោះជំនួស ហើយពួកគេរកប្រាក់បានគ្រប់គ្រាន់ ដើម្បីទិញដី និងផ្ទះ។ ណារី បាននិយាយថាកាលនៅធ្វើជា

កម្មករពេងចក្រ នាងអាចរកប្រាក់បានប្រមាណតែ ១២០ ដុល្លារប៉ុណ្ណោះក្នុង ១ ខែ ខណៈដែលប្តីរបស់នាងជាអ្នករត់ម៉ូតូឌុប។ នាងត្រូវបានគេសន្យាថានឹងឲ្យប្រាក់ចំនួន ៩០០០ ដុល្លារអាមេរិក សម្រាប់ការស៊ីឈ្នួលពពោះបង្កើតកូនឲ្យគេបានម្នាក់។ នាងនិយាយថា៖ «ត្រឹមពេលឥឡូវនេះខ្ញុំទទួលបានប្រាក់ប្រមាណ ២ ០០០ ដុល្លារហើយក្នុង ១ ខែៗពួកគេឲ្យប្រាក់ខ្ញុំ ៣០០ ដុល្លារ។ ដោយសារខ្ញុំក្រ ខ្ញុំបានជំពាក់ប្រាក់បងប្អូនទើបខ្ញុំស៊ីឈ្នួលពពោះ។ យើងអត់មានដីរស់នៅ ខ្ញុំចង់មានដីផ្ទាល់ខ្លួនសង់ផ្ទះ»។

លោក ជុំ ប្រសិទ្ធ ប្តីរបស់ ណារី ដែលជាអ្នករត់ម៉ូតូឌុប ឥឡូវនេះត្រូវមើលថែកូនផង និងត្រូវរត់ម៉ូតូឌុបរកប្រាក់ផ្គត់ផ្គង់គ្រួសារតែម្នាក់ឯងចាប់តាំងពី ណារី ត្រូវបានសមត្ថកិច្ចចាប់ឃុំខ្លួន។ លោក ប្រសិទ្ធ ឲ្យដឹងថា ណារី បាននិយាយជាមួយលោកនៅមុនពេលសម្រេចចិត្តស៊ីឈ្នួលពពោះ។ «នាងបានប្រាប់ខ្ញុំអំពីអ្នកស៊ីឈ្នួលពពោះ ខ្ញុំបានប្រាប់នាងឲ្យប្រុងប្រយ័ត្ន ប៉ុន្តែដោយសារយើងក្រីក្រខ្លាំង យើងចង់បានលុយទិញដី ...។ យើងឃើញគេធ្វើវាបានលុយច្រើនទិញដី និងធ្វើផ្ទះថ្មី។ ជាអ្នករត់ម៉ូតូឌុប ខ្ញុំមិនអាចរកលុយបានច្រើនទេ បច្ចុប្បន្នគេមិនសូវចូលចិត្តជិះម៉ូតូឌុប។ ខ្ញុំជំពាក់បងស្រី ២៥០០ ដុល្លារអាមេរិក»។

ស្ត្រីម្នាក់ទៀតឈ្មោះ លីន ដែលក៏មានសាច់រឿងស្រដៀងគ្នានឹងអ្នកស្រី ណារី ផងដែរដោយប្រឈមមុខនឹងបញ្ហាជីវភាពគ្រួសារយ៉ាងលំបាក នាងបានធ្វើដំណើរពីខេត្តមករាជធានីភ្នំពេញ ដើម្បីស៊ីឈ្នួលពពោះ បន្ទាប់ពីអ្នកនៅក្នុងភូមិរបស់នាងបានផ្តល់យោបល់ដល់នាង។ ប៉ុន្តែរហូតមកដល់ពេលនេះនាងទើបតែទទួលបានប្រាក់ ៥០០ ដុល្លារប៉ុណ្ណោះ។ លីន និយាយថា៖ «អ្នកជិតខាងបានប្រាប់ខ្ញុំឲ្យស៊ីឈ្នួលពពោះ ដើម្បីឲ្យខ្ញុំអាចទទួលបានប្រាក់ ៩០០០ ដុល្លារ។ ខ្ញុំបានប្រាប់ប្តីរបស់ខ្ញុំ គាត់មិនចង់ឲ្យខ្ញុំពពោះទេ ប៉ុន្តែខ្ញុំត្រូវការប្រាក់ដើម្បីសង់ផ្ទះមួយនៅដាច់ដោយឡែក ពីម្តាយរបស់ខ្ញុំ ហើយយើងមិនបានគិតល្អិតល្អន់អំពីបញ្ហានេះ»។ លីន បន្តថា៖ «ឥឡូវនេះខ្ញុំចង់ត្រឡប់ទៅផ្ទះវិញ។ ខ្ញុំនឹកប្តីរបស់ខ្ញុំ និងកូនស្រីរបស់ខ្ញុំ។ គាត់បានដឹងថាខ្ញុំត្រូវបានចាប់ខ្លួន ហើយគាត់បានមកសួរសុខទុក្ខខ្ញុំម្តង»។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដែលត្រូវបានសម្ភាស កាលពីខែកញ្ញាថ្លែងថា ករណីនេះនៅតែបន្តកើតឡើង។ «ពួកគេសំណាងដែលកូននៅក្នុងផ្ទៃរបស់ពួកគេនៅឡើយ បើសូម្បីពួកគេជាឧក្រិដ្ឋជន ពួកគេមិនត្រូវបានដាក់នៅក្នុងកន្លែងលំបាក ដោយសារយើងចង់ថែទាំទារកដែលជាជនរងគ្រោះនៅក្នុងផ្ទៃរបស់ពួកគេ»។

ស្ត្រីស៊ីឈ្នួលពពោះមួយចំនួន និងប្តីរបស់ពួកគេដែលភ្នំពេញប៉ុស្តិ៍សម្ភាស បាននិយាយថា ពួកគេចង់ចិញ្ចឹមកូនដែលពួកគេបានពពោះនោះ ដោយសារពួកគេបារម្ភថា ពួកគេនឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ២០ឆ្នាំ ប្រសិនបើពួកគេមានបំណងនាំយកកូនទាំងនោះទៅឲ្យឪពុកម្តាយដែលចង់បានកូននោះដែលភាគច្រើនជាជនជាតិចិន។

ណារី បានថ្លែងថា៖ «ខ្ញុំគិតថាវានឹងពិបាក ប៉ុន្តែខ្ញុំត្រូវតែមើលថែកូននេះ បើមិនដូច្នោះទេច្បាប់នឹងចោទប្រកាន់យើង។ នៅពេលកូនស្រីរបស់ខ្ញុំធំឡើង យើងមិនអាចលាក់នាងបានទេ ដោយសារនៅក្នុងភូមិរបស់ខ្ញុំដែលខ្ញុំរស់នៅ គេគ្រប់គ្នាដឹងថា ខ្ញុំស៊ីឈ្នួលពពោះ»។

លីន ក៏និយាយដែរថា៖ «ខ្ញុំនឹងមិនឲ្យកូននេះទៅនរណានោះទេ ខ្ញុំនឹងចិញ្ចឹមកូននេះដោយខ្លួនឯង មិនថាពួកគេឲ្យលុយខ្ញុំប៉ុន្មាននោះទេ។ ខ្ញុំមិនមែនមានន័យថា ខ្ញុំមានលុយគ្រប់គ្រាន់ដើម្បីចិញ្ចឹមកូននោះទេ ប៉ុន្តែប្រសិនបើយើងឲ្យកូននេះទៅអ្នកដទៃ ខ្ញុំអាចត្រូវបានគេចោទប្រកាន់ទៅតាមច្បាប់ និងជាប់ពន្ធនាគារ ២០ ឆ្នាំ»។

ប្តីរបស់ ណារី បានថ្លែងថា៖ «យើងមិនប្រាប់កូនស្រីរបស់យើង យើងស្រឡាញ់នាងដូចកូនយើង។ ខ្ញុំនិយាយមិនចេញទេ។ វាប្រាកដជាលំបាកសម្រាប់យើងហើយ ដូច្នេះយើងត្រូវខំធ្វើការទ្វេដង។ មិនថាលំបាកយ៉ាងណាទេ យើងត្រូវតែតស៊ូ។ ខ្ញុំភ័យខ្លាចថា នៅពេលយើងចិញ្ចឹមនាងធំឡើងពួកគេមកយកនាងវិញ»។

ប្ដីអាយុ ៣៦ ឆ្នាំម្នាក់ទៀតឈ្មោះ ជុំជួន ដែលក៏ជាអ្នករត់ម៉ូតូឌុបហើយប្រពន្ធរបស់គាត់ដែលជាកម្មកររោងចក្របានស៊ីឈ្នួលពពោះបាន ៤ ខែបាននិយាយថាលោកនឹងចិញ្ចឹមកូននេះ។ លោកថ្លែងថា៖ «ខ្ញុំនឹងមិនប្រាប់កូននេះអំពីប្រវត្តិរបស់នាងទេ ហើយប្រសិនបើយើងមិនប្រាប់គេ គ្មាននរណាម្នាក់ដឹងទេ មិនមែនរាល់កូនទាំងអស់សុទ្ធតែមានមុខមាត់ដូចឪពុកម្ដាយរបស់ពួកគេនោះទេ។ ខ្ញុំមិនចង់ឲ្យកូនដឹងទេ ដោយសារខ្ញុំមិនចង់ឲ្យកូនឈឺចាប់ វាមិនមែនជារឿងល្អសម្រាប់ក្មេងនោះទេ»។

លោកស្រី ប៊ុនអេង បានថ្លែងថា រដ្ឋាភិបាលព្យាយាមធ្វើឲ្យស្ត្រីទាំងអស់នោះអាចមានសិទ្ធិចិញ្ចឹមកូនដោយខ្លួនឯង។ «យើងត្រូវបង្រៀនសង្គមឲ្យទទួលយកថា ស្ត្រីជាម្ដាយនៃកូននោះមិនត្រូវរំឭកអំពីបញ្ហាដទៃ។ ប៉ះពាល់ ឬមិនប៉ះពាល់ វាអាស្រ័យទៅលើអ្នកខ្លួនឯង កូនប្រាកដជាប៉ះពាល់អារម្មណ៍។ ប៉ុន្តែអ្វីដែលសំខាន់ ពួកគេរស់នៅជាមួយម្ដាយរបស់ពួកគេ ហេតុអ្វីអ្នកលំបាកខ្លាំង?»។

លោក Rodrigo Montero ទីប្រឹក្សាផ្នែកយេនឌ័រនៅអង្គការ UNDP បានឆ្លើយតាមអ៊ីមែលថា រដ្ឋាភិបាលកំពុងអនុវត្តទៅតាមច្បាប់ជាតិ និងអន្តរជាតិ។ លោកថ្លែងថា៖ «រដ្ឋាភិបាលគួរអនុវត្តដោយគិតអំពីអត្ថប្រយោជន៍របស់កូនជាធំ។ នោះមានន័យថាស្ត្រីទាំងនេះមិនអាចត្រូវបានបង្ខំឲ្យមានកូន ប្រសិនបើវាមិនមែនជាអត្ថប្រយោជន៍កូនជាធំ។ ក្មេងទាំងអស់មានសិទ្ធិទទួលបានការស្រឡាញ់ និងទទួលបានការថែទាំសមស្រប និងការផ្គត់ផ្គង់សម្រាប់ការអភិវឌ្ឍរបស់ពួកគេ»។

លោកស្រី ប៊ុនអេង បានថ្លែងកាលពីថ្ងៃទី ១ ខែតុលាថា កូនស្ត្រីស៊ីឈ្នួលពពោះចំនួន ៩ នាក់បានកើតរួចហើយ ហើយសំបុត្រកំណើតត្រូវបានធ្វើដោយគ្រួសាររបស់ស្ត្រីស៊ីឈ្នួលពពោះ។ លោកស្រីបញ្ជាក់ថា ស្ត្រីទាំងនោះគឺជាម្ដាយរបស់កូនទាំងនោះនៅក្នុងសំបុត្រកំណើត។

ទោះយ៉ាងណាសាច់ញាតិម្នាក់ក្នុងចំណោមសាច់ញាតិរបស់ស្ត្រីស៊ីឈ្នួលពពោះបានអះអាងថា ពួកគេមិនទាន់បានធ្វើសំបុត្រកំណើតសម្រាប់កូននោះនៅឡើយទេ។

អ្នកនាំពាក្យក្រសួងកិច្ចការនារីលោក ប៊ុន ពុទ្ធបូរី បានថ្លែងតាមទូរស័ព្ទថា ក្រសួងមិនអាចផ្ដល់ជំនួយណាមួយដល់ស្ត្រីទាំងនោះទេ។ លោកបន្តថា៖ «ជាមួយករណីចាប់ខ្លួននេះ យើងពិតជាអាណិត ប៉ុន្តែយើងមិនបានផ្ដល់ជំនួយណាមួយទេ ប៉ុន្តែយើងមានដៃគូរបស់យើងដែលឧបត្ថម្ភពួកគេ។ និយាយឲ្យត្រង់ទៅ វាពិតជាសំណួរលំបាកឆ្លើយ.ហើយយើងអត់មានច្បាប់អំពីវា។ យើងបានជួបប្រជុំអន្តរក្រសួងនៅពេលករណីនេះកើតឡើងដើម្បីការពារអត្ថប្រយោជន៍កូន។ យើងចង់ពិនិត្យឲ្យច្បាស់ថា ស្ត្រីទាំងនោះពិតជាជនរងគ្រោះនៃការចាញ់បោកគេ ឬដើម្បីលុយ»។ ស្ត្រីស៊ីឈ្នួលពពោះ និងប្ដីរបស់ពួកគេនិយាយថា ពួកគេចង់ជួបជុំគ្រួសារវិញ។

លោក ជុំ ជួន បានថ្លែងថា៖ «ខ្ញុំពិបាកចិត្តណាស់ដែលឃើញប្រពន្ធរបស់ខ្ញុំរស់នៅទីនោះ (កន្លែងឃុំខ្លួន) ដោយមិនមានសេរីភាព។ ខ្ញុំចង់ឃើញនាងមានសេរីភាពនាពេលឆាប់ៗ។ នាងប្រាប់ខ្ញុំថា នាងដេកមិនលក់ដោយសារនាងគិតច្រើន។ នាងថាវាចង្អៀត និងមានមនុស្សច្រើននៅទីនោះ ហើយកូនយំ វាថ្លង់ណាស់»៕ PS

## *ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨*

## ក្រសួងនឹងស៊ើបអង្កេត អំពីទាសភាព នៅតាមសិប្បកម្មឡឥដ្ឋ

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 18 October 2018 | 19:44 ICT

**ភ្នំពេញៈ** ក្រសួងការងារនឹងចុះទៅធ្វើការស៊ើបអង្កេតទៅលើករណីទាសភាពសម័យទំនើបនៅក្នុងសិប្បកម្មឡឥដ្ឋ តាមរយៈការចងដោយបំណុលដែលបានផ្សាយដោយក្រុមអ្នកស្រាវជ្រាវពីសាកលវិទ្យាល័យ Royal Holloway ក្នុងទីក្រុងឡុងដ៍កាលពីថ្ងៃអង្គារ។ នេះជាការបញ្ជាក់របស់លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ទាប់ពីមានរបាយការណ៍មួយ របស់ក្រុមអ្នកស្រាវជ្រាវពីសាកលវិទ្យាល័យ Royal

Holloway ក្នុងទីក្រុងឡុងដ៍ ដែលមានចំណងជើងថា «ឥដ្ឋឈាម» ដោយបានបង្ហាញថាភាពរីកចម្រើនខ្លាំងនៃវិស័យសំណង់របស់ប្រទេសកម្ពុជាបានជំរុញឲ្យពលរដ្ឋក្រីក្រជាច្រើនគ្រួសារធ្លាក់ចូលទៅក្នុងទាសភាពសម័យទំនើបក្នុងសិប្បកម្មឡឥដ្ឋតាមរយៈការចងដោយបំណុល។ លោក អ៊ិត សំហេង ប្រាប់អ្នកសារព័ត៌មាន បន្ទាប់ពីសិក្ខាសាលាថ្នាក់ជាតិមួយ ស្ដីពីការរៀបចំកម្មវិធីការងារ សមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នៅសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់កាលពីថ្ងៃទី១៨ ខែតុលានេះថា ក្រសួងការងារ នឹងស៊ើបអង្កេតទៅលើទីតាំងនិងករណីដែលក្រុមអ្នកស្រាវជ្រាវពីសាកលវិទ្យាល័យ Royal Holloway ក្នុងទីក្រុងឡុងដ៍បានលើកឡើង។ ប៉ុន្តែលោកមិនបានឲ្យដឹងពេលវេលាច្បាស់លាស់ណាមួយដែលក្រសួងការងារនឹងចុះទៅស៊ើបអង្កេតរឿងនេះនោះទេ។ លោកបញ្ជាក់ថា៖«រឿងនេះយើងនឹងធ្វើការស៊ើបអង្កេតហើយថ្មីៗនេះក្រសួងបានចេញសេចក្ដីជូនដំណឹងមួយហាមប្រាមដាច់ខាតក្នុងករណីនេះ។ ក្រសួងនឹងធ្វើការស៊ើបអង្កេតនូវព័ត៌មានដែលបានលើកឡើងនោះ។ កន្លងមក យើងក៏មិនបានដឹងថាមានករណីនេះកើតឡើងទេ ហើយតាមរយៈព័ត៌មាននេះ យើងនឹងចុះទៅបញ្ជាក់ដល់គោលដៅហើយបើមានមែនយើងនឹងចាត់ការទៅតាមច្បាប់»។

ការស្រាវជ្រាវនោះ បានលើកឡើងថា ដោយសារតែវិស័យសំណង់របស់កម្ពុជាបានរីកចម្រើនយ៉ាងខ្លាំង រួមមានដូចជាការសាងសង់ផ្សារទំនើបថ្មីៗអចលនទ្រព្យលំនៅឋាន សណ្ឋាគារ អគារការិយាល័យ រោងចក្រ និងខុនដូ ហើយនេះធ្វើឲ្យមានតម្រូវការខ្ពស់ក្នុងការឲ្យមានការផលិតឥដ្ឋច្រើន ហើយធ្វើឲ្យតម្រូវការឥដ្ឋនេះបានរុញមនុស្សពេញវ័យ និងកុមារចូលទៅក្នុងកម្លាំងការងារសំខាន់នៅក្នុងការផលិតឥដ្ឋនិងធ្លាក់ជាប់ផុងក្នុងបំណុលផងដែរ។ កាលពីសប្ដាហ៍មុន ក្រសួងការងារបានចេញសេចក្ដីថ្លែងការណ៍មួយព្រមានផាកពិន័យ និងចាត់វិធានការផ្លូវច្បាប់តឹងរ៉ឹងចំពោះការប្រើប្រាស់ពលកម្មកុមារនៅក្នុងឧស្សាហកម្មឡឥដ្ឋនិងទម្រង់កេងប្រវ័ញ្ចដទៃៗទៀតជាមួយនឹងការចងដោយបំណុល។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្ស អាដហុក បានថ្លែងថា នេះគឺជាភារកិច្ចរបស់ក្រសួងការងារដែលត្រូវទទួលខុសត្រូវ ហើយក្រសួងត្រូវស៊ើបអង្កេតតាំងពីយូរមកហើយ បន្ទាប់ពីសង្គមស៊ីវិលបានធ្វើរបាយការណ៍ជាបន្តបន្ទាប់អំពីបញ្ហានៅឡឥដ្ឋដែលបានបង្កគ្រោះថ្នាក់ដល់កុមារនិងកម្មករ។ លោកបានបញ្ជាក់ថា៖ «ការដែលក្រសួងការងារចាប់ផ្ដើមធ្វើនេះ វាហាក់ដូចជាគាត់ទើបតែភ្ញាក់ពីដេក ហើយយើងគិតថាវាគួរឲ្យសោកស្ដាយកន្លង បើរាជរដ្ឋាភិបាលនិងក្រសួងយកចិត្តទុកដាក់តាំងពីដើមមកពលរដ្ឋកម្ពុជាអាចនឹងមិនមានភាពរងគ្រោះដោយសារតែរឿងនេះ»។ លោកបន្ថែមថា ពេលក្រសួងចុះស៊ើបអង្កេតត្រូវឲ្យមានតម្លាភាពដែលពលរដ្ឋអាចជឿទុកចិត្តបាន ហើយត្រូវមានយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីជួយទប់ស្កាត់នូវបញ្ហាទាំងអស់ដែលបានកើតមាននៅតាមឡឥដ្ឋ៕

## សមត្ថកិច្ចច្រកព្រំដែននៅស្រុកអូរជ្រៅបើកដៃឲ្យមេខ្យល់នាំពលករឆ្លងដែនទៅថៃខុសច្បាប់

https://www.rfa.org/khmer/news/ ដោយ ម៉ៅ សុជានី 2018-10-18

ប្រជាពលរដ្ឋ និងមន្ត្រីសង្គមស៊ីវិលនៅខេត្តបន្ទាយមានជ័យអះអាងថា ក្រោយពីរួចបុណ្យភ្ជុំបិណ្ឌមក សមត្ថកិច្ចច្រកព្រំដែនសប្បាយនឹងប្រព្រឹត្តអំពើពុករលួយដោយបើកដៃឲ្យក្រុមមេខ្យល់ នាំពលករខ្មែរឆ្លងដែនទៅធ្វើការនៅប្រទេសថៃតាមច្រករបៀងដែលខ្លួនប្រចាំការខុសច្បាប់។ ប៉ុន្តែប្រធានច្រករបៀងតំបន់៥ ក្នុងស្រុកអូរជ្រៅ បានបដិសេធចំពោះការចោទប្រកាន់នេះ។

ពលរដ្ឋម្នាក់រស់នៅក្រុងប៉ោយប៉ែត លោក អ៊ុក ថាប់បារាំង ឲ្យដឹងនៅថ្ងៃទី១៧ ខែតុលា ថា មេខ្យល់ដឹកពលករតាមរថយន្តមកពីខេត្តឆ្ងាយខ្លះ និងក្នុងខេត្តបន្ទាយមានជ័យខ្លះ រួចយកទៅទម្លាក់ចោលនៅតំបន់ព្រៃព្រំដែន ហើយពេលមានឱកាសនឹងបញ្ជូនពលករឆ្លងដែនទៅថៃ តាមច្រករបៀងព្រំដែនតំបន់៥ និងច្រកក្លឹបថ្មក្នុងស្រុកអូរ

ជ្រៅ តែម្តង។ លោកបន្ថែមទៀតថា ក្នុងពេលឆ្លងដែនម្តងៗពលករម្នាក់ត្រូវចំណាយលុយឲ្យមេខ្យល់ប្រមាណ ៣ ពាន់បាត ឬប្រហែល៣៨ម៉ឺនរៀល(៣៨០,០០០)៖ «តាមដែលខ្ញុំសង្កេតមើល គេនាំចូលម្តង៤ឡានឯណោះ និងមានពលករប្រហែល៥០នាក់ចំពោះនៅពេលថ្ងៃ ប៉ុន្តែពលរដ្ឋនៅព្រំដែននោះបានប្រាប់ខ្ញុំថា គេច្រើននាំពលករឆ្លងដែននៅពេលរសៀល ដែលមានរាប់រយនាក់ក្នុងមួយថ្ងៃ។ និយាយរួមទៅគេនាំពលករឆ្លងដែនតាមច្រករបៀងដូចគេហែកបិនអីចឹងសព្វថ្ងៃនេះ»។ ពលរដ្ឋ និងសង្គមស៊ីវិលខេត្តបន្ទាយមានជ័យព្រួយបារម្ភថា ករណីពលករឆ្លងដែនតាមច្រករបៀងខុសច្បាប់នេះ ប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ហើយអាចត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកច្រវាក់ទៀតផង។

មេបញ្ជាការទាហានវរការពារព្រំដែនលេខ៥០៣ និងប្រធានច្រកព្រំដែនតំបន់ប្រាំ លោក យូន ជឿន មានប្រសាសន៍ថា នៅច្រកព្រំដែនដែលលោកប្រចាំស្ងប់ស្ងាត់ល្អ ហើយមិនមានការលួចនាំពលករឆ្លងដែនខុសច្បាប់ដូចការចោទប្រកាន់របស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលនោះឡើយ៖ «អត់មានទេបង មានតែប្រជាពលរដ្ឋគាត់ទៅផ្សារថៃមួយសប្តាហ៍បើកម្តងនៅថ្ងៃសុក្រ ហើយនិងពលរដ្ឋដែលទៅធ្វើការប្រទេសថៃទៅព្រឹក ហើយវិលមកកម្ពុជាវិញពេលរសៀល ជាធម្មតាមិនមានអ្វីខុសប្រក្រតីទេ»។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា អះអាងថា ចាប់ពីរួចបុណ្យភ្ជុំបិណ្ឌមកពលករបាននាំគ្នាសម្រុកចេញទៅប្រទេសថៃតាមច្រករបៀងក្នុងស្រុកអូរជ្រៅ យ៉ាងច្រើនកុះករ។ មន្ត្រីសង្គមស៊ីវិលរូបនេះបន្ថែមទៀតថា ពលករឆ្លងដែនទៅបានដោយសារតែត្រូវរ៉ូវគ្នាជាមួយមន្ត្រីច្រកព្រំដែននៅក្នុងស្រុកនេះ ហើយពួកគេនៅពេលចូលដល់ទឹកដីថៃ ត្រូវប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ហើយអាចនឹងត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកទៀតផង៖ «បើសិននៅច្រកដែលសមត្ថកិច្ចប្រចាំហើយមានគេនាំពលករឆ្លងដែនបាន ដូច្នេះគាត់ក៏ជាជនផ្សំគំនិតដែរ។ កម្ពុជាយើងក៏ជាប្រទេសមានអធិបតេយ្យភាពដែរមិនគួរណាទៅលួចលាក់នាំពលករឆ្លងដែនទេ គួរតែចេញមុខ ព្រោះរដ្ឋាភិបាលបានបើកឲ្យធ្វើលិខិតឆ្លងដែន ដើម្បីឲ្យពលករទៅធ្វើការស្របច្បាប់ហើយ ដូច្នេះទង្វើរបស់មន្ត្រីព្រំដែននេះគឺជាអំពើសុខច្បាប់ហើយ»។ លោក ស៊ុំ ច័ន្ទគា កត់សំគាល់ទៀតថា ការឆ្លងដែននេះដោយសារតែជីវភាពរបស់ពួកគេក្រីក្រ ហើយនៅស្រុកកំណើតគ្មានការងារធ្វើ ទើបបានជាពួកគេហ៊ានឆ្លងដែនប្រថុយនឹងគ្រោះថ្នាក់បែបនេះ។ សព្វថ្ងៃពលករខ្មែរធ្វើការនៅប្រទេសថៃទាំងស្របច្បាប់ និងទៅដោយខុសច្បាប់សរុបមានជាង១លាននាក់។ ប៉ុន្តែនៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌកន្លងទៅនេះ មិនសូវមានពលករត្រឡប់មកលែងស្រុកកំណើតទេ ដោយសារថៅកែមិនឲ្យច្បាប់ឈប់ ហើយពលករដែលទៅលេងស្រុកកំណើតភាគច្រើនពួកគេឆ្លងដែនតាមច្រករបៀងខុសច្បាប់៕

## អាជ្ញាធរថៃចុះបង្រ្កាបត្រួតចាប់ពលករខុសច្បាប់ទាំងព្រឹកពលករខ្លះមិនទាន់ងើបពីដេកផង

https://www.facebook.com/ ទឹកចិត្តពលករឆ្លងដែន 2018-10-18

កាលនៅថ្ងៃទី១៨ -១០-២០១៨ នៅវេលាម៉ោង៦ ពេលព្រឹកអាជ្ញាធរថៃបានចុះបង្រ្កាបត្រួតចាប់ពលករខុសច្បាប់ ទាំងព្រឹកពលករខ្លះមិនទាន់ងើបពីដេកផង ស្រាប់តែអាជ្ញាធរថៃមានទាំងទាហ៊ាននិងតាំរួតបានចុះមកត្រួតតាមកន្លែងស្នាក់នៅពលករខ្មែរ និងពលករឡាវ និងពលករភូមា.ទាំងព្រឹក..យោងតាមរាយការរបស់អាជ្ញាធរថៃបានឲ្យដឹងថា..ក្នុងការចុះត្រួតចាប់លើកនេះកាន់តែត្រួតចាប់ខ្លាំងជាងមុន គោលបំណងរបស់អាជ្ញាធរថៃគឺ ត្រួតចាប់ពលករខុសច្បាប់ និងត្រួតចាប់ថ្នាំញៀននៅតាមកន្លែងធ្វើការពលករបរទេស..អាជ្ញាធរថៃបាននិយាយទៀតថា កន្លែងដែលអាជ្ញាធរថៃបានចុះត្រួតចាប់នៅក្នុងខេត្តសមុទ្រប្រាកាណ មាន៥៤ កន្លែង ក្នុងនោះមាន.បាងភ្លី.បាងកែវ.បាងសៅថង.បាងបរ.នៅមានជាច្រើនកន្លែងទៀតដែលអាជ្ញាធរថៃត្រូវចុះទៅត្រួតចាប់.. ក្នុងការចុះត្រួតពលករខុស

ច្បាប់លើកនេះមានពលករទាំងអស់ចំនួន៩៥៤នាក់ ក្នុងនោះមានពលករកម្ពុជាចំនួន១០៤នាក់.មានពលករភូមាចំនួន ៧០៦នាក់.និងពលករឡាវចំនួន១៣៥នាក់។ (អំពីខ្ញុំ ទឹកចិត្តពលករឆ្លងដែន)

## *ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨*

## ចាប់ខ្លួនស្ត្រីជាម្ដាយ ដែលយកកូនស្រីបង្កើត៣នាក់ ទៅលក់នៅប្រទេសចិន

http://www.cen.com.kh/ October 23, 2018

ក្រចេះ ៖ ស្ត្រីម្នាក់ ជាមេខ្លោងជួញដូរមនុស្ស និងយកកូនស្រីបង្កើតរបស់ខ្លួន៣នាក់ ទៅលក់នៅប្រទេសចិន ត្រូវបាននគរបាលឃាត់ខ្លួន និងបញ្ជូនខ្លួនទៅកាន់សាលាដំបូងខេត្តក្រចេះ នៅរសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ។ បន្ទាប់ពីចាប់ខ្លួនស្ត្រីជាម្ដាយរួចហើយ កូនស្រីបង្កើតរបស់ខ្លួន៣នាក់ បានចេញមុខមកបកអាក្រាត នូវទង្វើរបស់ម្ដាយ ដែលចិត្តតិរច្ឆាន លក់កូនស្រី។

នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ បានឲ្យដឹងថា ស្ត្រីរូបនេះឈ្មោះ ឌី ចាន់ធី អាយុ៥៦ឆ្នាំ មានទីលំនៅមិនពិតប្រាកដ និងត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តក្រចេះ ក្រោមការបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ លន់ សុផាត ស្នងការនគរបាលខេត្តចាប់ខ្លួនបាននៅខេត្តរតនគិរី កាលពីថ្ងៃទី១៨ ខែតុលា បន្ទាប់ពីមានការចុះស្រាវជ្រាវ និងរកឃើញថាមានជាប់សង្ស័យជាមេខ្លោងជួញដូរមនុស្ស ឆ្លងទៅប្រទេសចិន។

លោកស្រី នៅ រតនា ស្នងការរងទទួលការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជន នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ បានឲ្យដឹងបន្ថែមថា នគរបាលជំនាញបានចាប់ខ្លួនស្ត្រីសង្ស័យខាងលើ ទៅតាមពាក្យបណ្ដឹងរបស់ក្រុមគ្រួសារក្មេងស្រីរងគ្រោះ ចំនួន៣នាក់ រស់នៅភូមិថ្មល់កើត ឃុំស្វាយជ្រះ ស្រុកស្នួល ដែលបានប្ដឹងពីបទជួញដូរមនុស្ស ក្នុងរូបភាពបោកបញ្ឆោតឲ្យទៅយកប្ដី នៅប្រទេសចិនដោយខុសច្បាប់។ ស្ត្រីរូបនេះក្រៅពីជាប់សង្ស័យពី បទជួញដូរមនុស្សឆ្លងដែន ក្នុងនោះក៏មានជាប់ពាក់ព័ន្ធនឹងបទក្លែងឯកសារមួយករណីទៀត។ ឆ្លងតាមការស្រាវជ្រាវពីកម្លាំងនគរបានជំនាញ សហការជាមួយកម្លាំងនគរបាលនាយដ្ឋាន ក្រោមការណែនាំពីលោកឧត្តមសេនីយ៍ លន់ សុផាត ស្នងការនគរបាលខេត្ត ក្រោមការសម្របសម្រួលពីលោក កែវ សុជាតិ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត និងក្រោមការឧបត្ថមគាំទ្រពីអង្គការមេត្រីអន្តរជាតិហៅកាត់ថា I' M (អេម) បានធ្វើឲ្យនគរបាលបំបែកសំណុំរឿងជួញដូរមនុស្ស និងជួញដូរកូនស្រីបង្កើតខ្លួនឯង ទ្រង់ទ្រាយធំមួយករណីនេះបាន។ លោកស្រីស្នងការរង បានបញ្ជាក់ទៀតថា កាលពីអំឡុងប៉ុន្មានឆ្នាំមុន ស្ត្រីសង្ស័យរូបនេះធ្លាប់បាន ធ្វើសកម្មភាពលក់ព្រហ្មចារី កូនស្រីបង្កើតខ្លួនឯងម្នាក់ឈ្មោះ សុជា ស្រីនាង អាយុ១៤ឆ្នាំ នៅខេត្តបាត់ដំបង។ ក្រោយលក់ព្រហ្មចារីកូនស្រីបានមួយសប្ដាហ៍ ស្ត្រីរូបនេះបាននាំនាងទៅបម្រើបនស្រីមួយកន្លែងទៀត នៅស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយរូបគាត់ជាអ្នកហៅម៉ូយ និងជាអ្នកយកលុយដោយខ្លួនផ្ទាល់ ហើយក្នុង១ថ្ងៃៗ នាងត្រូវកំដរភ្ញៀវចាប់ពី៥ទៅ៦នាក់ ដែលបានចូលរួមភេទជាមួយនាង។ ក្រោយមក នាងបានរត់ចេញពីបន ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

បើតាមលោកស្រីស្នងការរង បានសម្រង់ចម្លើយនារី ជាកូនស្រីដែលរងគ្រោះទាំង៣នាក់នេះ ឲ្យដឹងទៀតថា ដោយសារតែអត់ទ្រាំនឹងការកៀបសង្កត់នេះមិនបាន នារីជាកូនបានរត់គេច ខ្លួនរសាត់អណ្ដែតរហូតបានទៅយកប្ដីនៅប្រទេសចិន មួយរយៈ។ ក្រោយពីស្ត្រីជាម្ដាយ បានដឹងថាកូនស្រីដែលគេចខ្លួន បានទៅយកប្ដីនៅប្រទេសចិន ស្ត្រីរូបនេះបានបោកបញ្ឆោត កូនស្រីរបស់ខ្លួនចំនួន២នាក់ទៀត ដោយម្នាក់មានអាយុ២៣ឆ្នាំ និងម្នាក់ទៀតមានអាយុ២០ឆ្នាំ ខណៈនាងនៅជាសិស្សនៅឡើយ ដោយគំរាមឲ្យនាងឈប់រៀន និងបានបញ្ឆោតនាង ក្លែងឯកសាររត់ការ តាមខ្សែបណ្ដាញឲ្យនាងទៅយកប្ដី នៅប្រទេសចិន ដោយខុសច្បាប់បន្តទៀត។

បើទោះបីជាកូនៗ ដែលបានទៅយកប្ដីនៅប្រទេសចិនដោយខុសច្បាប់ និងដោយអត់ទ្រាំនឹងទង្វើធ្វើបាបពីប្ដីជនជាតិចិនមិនបាន ពួកគេទាំង២នាក់បានរត់មកស្រុកខ្មែរវិញ តែត្រូវស្ត្រីជាម្ដាយរូបនេះបង្ខំ និងបោកបញ្ឆោតយកទៅលក់បន្ត។ រហូតជាលើកចុងក្រោយ ក្រោយពីនគរបាលជំនាញ បានចុះស្រាវជ្រាវលើបណ្ដឹងការជួញដូរមនុស្ស និងកន្លែងឯកសារឲ្យទៅយកប្ដី នៅក្រៅប្រទេសដោយខុសច្បាប់ ក៏បានឃាត់ខ្លួនស្ត្រីជាមេខ្លោងរូបនេះ មក

សាកសួរ ទើបមាននារីធ្លាប់រងគ្រោះទាំង៣នាក់ ដែលជាកូនបង្កើត ស្ម័គ្រចិត្តខ្លួនចូលមកបំភ្លឺជាមួយនគរបាល ដើម្បីបកអក្រាតរឿងម្ដាយលក់កូនស្រីនេះ៕ ដោយ ៖ បញ្ញាស័ក្តិ

## ស្ត្រីម្នាក់ត្រូវបានឃុំខ្លួន រឿងជួញដូរមនុស្ស និងកូនស្រីបង្កើត ៣ នាក់ទៅចិន

https://www.postkhmer.com/ វ៉ន ដារ៉ា Publication date 23 October 2018 19:05 ICT

**ក្រចេះ:** ស្ត្រីម្នាក់ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះចេញដីកាឃុំខ្លួននៅថ្ងៃទី២៣ខែតុលានេះពីបទជួញដូរមនុស្សឆ្លងដែនបន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនតាមបណ្ដឹងពីឪពុកម្ដាយជនរងគ្រោះ ដែលត្រូវជនសង្ស័យក្លែងឯកសារនាំយកកូនស្រីពួកគាត់ទៅលក់នៅចិន។ នេះបើតាមមន្ត្រីនគរបាលខេត្ត។

លោកស្រី នៅ រតនា ស្នងការរងទទួលបន្ទុកប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនខេត្តក្រចេះបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី២៣ខែតុលានេះថា ស្ត្រីជាជនសង្ស័យខាងលើ ឈ្មោះ ឌី ចាន់ធី អាយុ៥៦ ឆ្នាំ មានទីលំនៅមិនពិតប្រាកដត្រូវបានសាលាដំបូងខេត្តឃុំខ្លួន។ គាត់ធ្លាប់បានរកស៊ីត់ពន្ធមនុស្សឆ្លងដែនឲ្យទៅយកប្ដីនៅចិន និងធ្លាប់លក់កូនស្រីខ្លួនឯង៣នាក់ទៅចិន ហើយក៏ធ្លាប់ឱ្យកូនរកស៊ីផ្លូវភេទតាំងពីអាយុ១៤ឆ្នាំផងដែរនៅខេត្តបាត់ដំបង។ លោកស្រីបានបន្ថែមថា៖«ការឃាត់ខ្លួនជនសង្ស័យគឺបន្ទាប់ពីឪពុកម្ដាយជនរងគ្រោះ៣នាក់ផ្សេងទៀតនៅខេត្តក្រចេះដាក់ពាក្យបណ្ដឹងបន្ទាប់ពីជនរងគ្រោះម្នាក់បានបង្ហោះសារលើហ្វេសប៊ុកពីប្រទេសចិនឱ្យជួយពួកគេ»។ លោកស្រីស្នងការរងបានបន្តថា ជនសង្ស័យរូបនេះត្រូវបាននគរបាលឃាត់ខ្លួននៅស្រុកកូនមុំ ខេត្តរតនគិរី កាលពីថ្ងៃទី១៨ តុលា និងបញ្ជូនមកសាលាដំបូងខេត្តក្រចេះកាលពីថ្ងៃទី២២ ខែតុលាឆ្នាំនេះ ហើយត្រូវចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនតាមមាត្រាទី១១នៃច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទកាលពីម្សិលមិញ។ លោកស្រីថា៖«ឥឡូវចៅក្រមស៊ើបសួរបានចេញដីកាឲ្យឃុំខ្លួននៅពន្ធនាគារខេត្តក្រចេះ ហើយក្រោមបទចោទជួញដូរមនុស្សឆ្លងដែន»។

បើតាម លោកស្រី រតនា ក្រៅពីបញ្ឆោតកូនខ្លួនឯង៣នាក់ឲ្យរកស៊ីផ្លូវភេទនិងនាំយកទៅលក់នៅប្រទេសចិនជនសង្ស័យបានបោកស្រី៣នាក់ផ្សេងទៀតនៅស្រុកស្នួល ខេត្តក្រចេះ ក្នុងរូបភាពទៅយកប្ដីនៅចិន។ លោកស្រីស្នងការបន្តថា៖«យើងព្យាយាមសួរគាត់ពីចំនួនមនុស្ស ដែលគាត់នាំយកទៅលក់ តែគាត់ព្យាយាមមិនឆ្លើយនិងបដិសេធសំណួររបស់យើង។ យើងគ្រាន់តែដឹងថាក្រៅពីកូនស្រីគាត់៣នាក់ដែលចូលមកបំភ្លឺដល់សមត្ថកិច្ច...គឺមានអាណាព្យាបាលជនរងគ្រោះ៣នាក់ទៀតបានប្ដឹងជនសង្ស័យពីករណីនាំកូនគាត់ទៅលក់នៅប្រទេសចិននេះដែរ»។

ដោយផ្អែកលើចម្លើយក្មេងស្រីរងគ្រោះនៅស្នងការដ្ឋានខេត្ត លោកស្រីស្នងការរងបានឱ្យបញ្ជាក់ដែរថា ស្ត្រីសង្ស័យរូបនេះធ្លាប់បានលក់ព្រហ្មចារី កូនស្រីបង្កើតម្នាក់ឈ្មោះ ស.ន អាយុ ១៤ឆ្នាំ ទៅខេត្តបាត់ដំបងឲ្យបម្រើសេវាកម្មផ្លូវភេទ។ ក្រោយលក់ព្រហ្មចារីកូនស្រីបានមួយរយៈស្ត្រីរូបនេះបាននាំនាងទៅបម្រើនៅបនស្រីនៅកន្លែងផ្សេងទៀតក្នុងស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយរូបគាត់ជាអ្នកហៅម៉ូយនិងជាអ្នកយកលុយដោយខ្លួនផ្ទាល់ ហើយក្នុងមួយថ្ងៃៗឲ្យកូនស្រីកំដរភ្ញៀវរួមភេទចាប់ពី៥-៦នាក់។

លោកស្រី នៅ រតនា បានថ្លែងថា តាមចម្លើយ ក្រោយមកនាងបានរត់ចេញពីបនទៅធ្វើការនៅប្រទេសម៉ាឡេស៊ីរហូតបន្តដល់ប្រទេសចិនដោយសារមិនអាចទ្រាំនឹងការគាបសង្កត់ពីម្ដាយ ដែលបង្ខំឲ្យបម្រើសេវាកម្មផ្លូវភេទបាន។ ក្រោយពីស្ត្រីជាម្ដាយដឹងថាកូនស្រីដែលគេចខ្លួននោះបានទៅយកប្ដីនៅចិនស្ត្រីរូបនេះបានបោកបញ្ឆោតកូនស្រីបង្កើត២នាក់ទៀតដោយម្នាក់មានអាយុ២០ឆ្នាំ និងម្នាក់អាយុ២៣ឆ្នាំឲ្យទៅយកប្ដីនៅចិនខុសច្បាប់បន្តទៀតដោយក្លែងឯកសារជាមួយនឹងការគំរាមឱ្យឈប់រៀន ខណៈពួកគេនៅជាសិស្សនៅឡើយ។ បើទោះបីជាកូនស្រីទាំង២នាក់ បានរត់ត្រឡប់មកដល់កម្ពុជាវិញដោយសារអត់ទ្រាំការធ្វើបាបពីប្ដីជនជាតិចិនមិនបានក៏ដោយ តែត្រូវបានស្ត្រីជាម្ដាយរូបនេះបង្ខំនិងបោកបញ្ឆោតយកទៅលក់ឱ្យបុរសចិនម្ដងទៀតតែត្រូវលួចរត់មកវិញជាថ្មី។ នេះបើតាមលោកស្រី នៅ រតនា ដែលផ្អែកតាមចម្លើយជនរងគ្រោះ។ យ៉ាងណាក្ដីលោកស្រី នៅ រតនា ស្នងការរងខេត្តក្រចេះបានបញ្ជាក់ថា ករណីនារី៣នាក់ផ្សេងទៀតដែលឪពុកម្ដាយប្ដឹងឱ្យជួយនោះនៅមិនទាន់បានត្រឡប់មកវិញទេខណៈសមត្ថកិច្ចនិងអង្គការសង្គមស៊ីវិលកំពុងសហការជាមួយស្ថានទូតដើម្បីជួយពួកគេ៕

## ទីប្រឹក្សាទទួលបន្ទុកពលករអមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានជួយដោះស្រាយវិវាទបងប្អូនពលករនេសាទខ្មែរចំនួន១៨នាក់

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ October 20 at 12:22 PM

នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ក្រុមទីប្រឹក្សាទទួលបន្ទុកពលករអមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសហការជាមួយអាជ្ញាធរប្រឆាំងការជួញដូរមនុស្ស(TATIP) និងមូលនិធិលើកកម្ពស់និងបណ្តុះបណ្តាលគុណភាពជីវិតពលករ(LPN)។ បានចុះមកច្រកព្រំដែនអន្តរជាតិបានទ្បែម ខេត្តចន្ទបុរី ដើម្បីជួយដោះស្រាយវិវាទបងប្អូនពលករនេសាទខ្មែរចំនួន១៨នាក់ ដែលធ្វើការលើទូកនេសាទនៅខេត្តឈុនបុរី បន្ទាប់ពីទទួលបានព័ត៌មានថាត្រូវនិយោជកមិនបើកប្រាក់ឈ្នួលអោយ។

## ជប៉ុនកំពុងស្រេកឃ្លាន ពលករ

http://www.cen.com.kh/ October 24, 2018

ជប៉ុននឹងពិនិត្យទទួលយកជនអន្តោប្រវេសន៍មកពីទ្វីបអាស៊ី ចាប់ពីឆ្នាំ២០២០តទៅ ដើម្បីបង្កើនចំនួនពលករទ្វេដងប្រៀបនឹងបច្ចុប្បន្ននេះ សំដៅឆ្លើយតបនឹងកង្វះពលករយ៉ាងធ្ងន់ធ្ងរ។ តាមក្រសួងយុត្តិធម៌ជប៉ុន នៅឆ្នាំ២០១៧ ប្រទេសនេះទទួលយកមនុស្សតែ២០នាក់ ក្នុងចំណោមមនុស្សប្រមាណ ២០.០០០នាក់ ដែលដាក់ពាក្យសុំជ្រកកោនហើយអនុញ្ញាតឱ្យមនុស្ស៤៥នាក់រស់នៅលើមូលដ្ឋានមនុស្សធម៌។ គោលនយោបាយអន្តោប្រវេសន៍ដ៏តឹងតែង បានធ្វើឱ្យជប៉ុនក្លាយជាសង្គមមួយមានពលរដ្ឋចំណាស់បំផុតពិភពលោក។ ជនជាតិបរទេសប្រមាណតែ ១,៧ភាគរយ ប្រៀបនឹងចំនួនប្រជាជនជប៉ុន ក្នុងពេលដែលនៅកូរ៉េខាងត្បូងគឺ ៣,៤ភាគរយ ហើយនៅអាល្លឺម៉ង់ ប្រមាណ ១២ភាគរយ។

ក្រៅពីរឿងទទួលយកជនអន្តោប្រវេសន៍ ផែនការថ្មីរបស់នាយករដ្ឋមន្ត្រី Shinzo Abe អំពីការនាំចូលពលករពីប្រទេសក្រៅអាចមានចំនួនដល់ទៅ ៥សែននាក់ ។តាមការប៉ាន់ស្មាន ពលករបរទេសនឹងធ្វើ ឱ្យកើនឡើង៤០ភាគរយ ឬប្រមាណ៥២០.០០០នាក់ ដែលប្រៀបនឹងបច្ចុប្បន្នមានតែ១លាន៣សែននាក់ប៉ុណ្ណោះ។ជាការលើកទឹកចិត្តដល់ពលករបរទេសនោះ កម្មករដែលមានមុខជំនាញឯកទេសអាចនាំយកគ្រួសារមកនៅរយៈពេលវែង ក្នុងពេលដែលពលករសាមញ្ញ ឬសមត្ថភាពជំនាញទាប អាចមកបានតែម្នាក់ឯងហើយរស់នៅជប៉ុនមិនលើសពី៥ឆ្នាំ។

អ្នកគាំទ្រគោលនយោបាយថ្មីនេះលើកឡើងថា ជប៉ុនមិនអាចរារែកចិត្តក្នុងការទទួលយកពលករបរទេសនោះឡើយព្រោះតែកម្លាំងពលកម្មនៅប្រទេសកំពុងថមថយចុះ ធ្វើឱ្យឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ខឿនសេដ្ឋកិច្ចជាតិ។ តាមការអង្កេតរបស់ការិយាល័យពាណិជ្ជកម្មនិងឧស្សាហកម្មជប៉ុនប្រកាសកាលពីខែមិថុនាឱ្យដឹងថា មានក្រុមហ៊ុនជប៉ុនចំនួន២ភាគ៣ដែលខ្វះពលកម្ម ហើយក្រុមហ៊ុនជប៉ុនដែលខ្វះពលកម្មបានកើនឡើង៤០ភាគរយគិតមកទល់ឆ្នាំហិរញ្ញវត្ថុ 2017-2018 ។

កម្ពុជាគួរចាប់យកឱកាសនេះ ដើម្បីបណ្តុះបណ្តាលជំនាញនិងភាសា ក៏ដូចជាត្រៀមខ្លួនរៀបចំលក្ខខណ្ឌសម្រាប់នាំចេញពលករ ចៀសវាងការនាំចេញពលករគ្មានជំនាញនាំឱ្យចំណូលពួកគេស្ថិតក្នុងកម្រិតទាប។ សូយន

## *ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨*

### កម្ពុជានឹងបញ្ជូន ពលករ៥ពាន់នាក់ ទៅបម្រើការ នៅប្រទេសគុយវ៉ែតជាលើកដំបូង នាឆ្នាំ២០១៩ខាងមុខ

https://www.dap-news.com/ ByID:114 Posted on 24 October 2018 | 17:11

ភ្នំពេញ៖លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងប្រាប់អ្នកសារព័ត៌មាន ក្រោយបញ្ចប់កិច្ចពិភាក្សាការងារជាមួយ លោកស្រីHend Subaih B ALSUBAIH រដ្ឋមន្ត្រីក្រសួងសង្គម

កិច្ច និងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុក កិច្ចការសេដ្ឋកិច្ចនៃប្រទេសគុយវ៉ែតថា កម្ពុជានឹងបញ្ជូនពលករ ចំនួន៥ពាន់នាក់ ទៅបម្រើការងារលើកដំបូង នៅប្រទេសគុយវ៉ែត នៅឆ្នាំ២០១៩ខាងមុខ។

យោងតាមបណ្តាញ ទំនាក់ទំនងសង្គមហ្វេសប៊ុក របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ក្នុងកិច្ចពិភាក្សាការងារ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ប្រមុខក្រសួងការងាររបស់កម្ពុជា និងគុយវ៉ែតបានព្រមព្រៀងគ្នាជំរុញកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែជិតស្និទ្ធថែមទៀត លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយវិនិយោគិនគុយវ៉ែត ក៏មានបំណងចង់ស្វែងរកឱកាស វិនិយោគនៅកម្ពុជាផងដែរ។ លោករដ្ឋមន្ត្រីថ្លែងយ៉ាងដូច្នេះថា «កម្ពុជានឹងរៀបចំកម្លាំងពលកម្មរបស់ខ្លួន ដែលបានជ្រើសរើសគ្រប់លក្ខខណ្ឌចំនួន ៥ពាន់នាក់ ជាលើកដំបូង ទៅបម្រើការងារនៅប្រទេសគុយវ៉ែត ហើយកម្លាំងពលកម្មនេះ ជាកម្លាំងពលកម្មគ្រប់ផ្នែក ទាំងផ្នែកសេវាកម្ម ឧស្សាហកម្ម និងកសិកម្ម»។ លោករដ្ឋមន្ត្រី បានបន្តថា ប្រសិនបើស្ថានភាព នៅប្រទេសគុយវ៉ែតល្អប្រសើរស្របទៅនឹងអ្វីដែលពលករកម្ពុជា ទទួលយកបាន មានលក្ខខណ្ឌការងារល្អ ប្រាក់ឈ្នួលសមរម្យនោះ រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញ ឱ្យមានការបញ្ជូននេះឱ្យបានកាន់តែច្រើន។

ចំពោះលក្ខខណ្ឌជ្រើសរើសពលករ ទៅបម្រើការងារនៅប្រទេស ក្នុងតំបន់មជ្ឈិមបូព៌ាមួយនេះ លោករដ្ឋមន្ត្រីក៏បានបញ្ជាក់ដែរថា ត្រូវមានការ បណ្តុះបណ្តាលជាមុន ដើម្បីឱ្យស្គាល់ពីស្ថានភាពប្រទេស ទទួលស្គាល់ពីវប្បធម៌ និងជំនាញការងារ ពិសេសលក្ខខណ្ឌក្នុងការរស់នៅទីនោះផងដែរ។ លោកបានសង្កត់ធ្ងន់ថា ទាំងនេះគឺស្របទៅនឹងគោលនយោបាយ «បើកចំហទៅកាន់តំបន់មជ្ឈិមបូព៌ា» របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី៕

## រដ្ឋមន្ត្រីក្រសួងការងារ អំពាវនាវឲ្យពលករកម្ពុជា ធ្វើការដោយខុសច្បាប់នៅកូរ៉េ ត្រឡប់មកវិញ

http://wmc.org.kh/ ថ្ងៃពុធ ទី២៤ ខែតុលា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ បានអំពាវនាវឲ្យពលករកម្ពុជា ដែលកំពុងធ្វើការងារដោយខុសច្បាប់នៅប្រទេសកូរ៉េ ត្រឡប់មកវិញ ដើម្បីបំពេញឯកសារ។ ការអំពាវនាវនេះ ធ្វើឡើង ខណៈប្រទេសកូរ៉េខាងត្បូង បានប្រកាសទុកពេលឲ្យ ៦ខែ សម្រាប់ពលករបរទេស ដែលកំពុងធ្វើនៅប្រទេសនេះដោយខុសច្បាប់ចាកចេញ។ កូរ៉េព្រមានថា បើមិនព្រមចាកចេញ ហើយត្រូវចាប់បាន នឹងត្រូវជាប់ឈ្មោះក្នុងបញ្ជីខ្មៅ ហាមវិលទៅកាន់ប្រទេសនេះរយៈពេល ១០ឆ្នាំ។ កូរ៉េត្បូង ដែលជាប្រទេសមួយមានពលករខ្មែរទៅធ្វើការយ៉ាងច្រើននោះ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ ប្រទេសនេះបានប្រកាសឲ្យពលករបរទេស ដែលកំពុងធ្វើការដោយខុសច្បាប់ទាំងអស់ ចាកចេញឲ្យអស់ពីប្រទេសរបស់ខ្លួន ក្នុងរយៈពេល ៦ខែ ចាប់ពីផ្តើមពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។ ទាក់ទិនរឿងនេះ លោករដ្ឋមន្ត្រីក្រសួងការងារ ទទួលស្គាល់ថា ពលករកម្ពុជាប្រទេសកូរ៉េខាងត្បូង ថ្វីត្បិតតែស្ទើរតែ១០០ភាគរយ ដែលជាពលករស្របច្បាប់ក៏ពិតមែន ក៏ប៉ុន្តែក៏អាចនឹងមានពលករកម្ពុជា មួយចំនួន បាននឹងកំពុងស្នាក់នៅ ហើយធ្វើការដោយខុសច្បាប់ដែរ។ ក៏ប៉ុន្តែលោកប៉ាន់ប្រមាណថា ពលករកម្ពុជាខុសច្បាប់ អាចនឹងមានចំនួនតិចតួចតែប៉ុណ្ណោះ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអំពាវនាវដល់ពលករកម្ពុជាទាំងអស់ ដែលកំពុងស្នាក់នៅនិងធ្វើការដោយខុសច្បាប់ ឲ្យវិលមកកម្ពុជាវិញ មុនពេលប្រទេសកូរ៉េចាត់វិធានការលើពលករបរទេសខុសច្បាប់។ លោកបញ្ជាក់ថា ក្រោយពីមកកម្ពុជា ពលករខុសច្បាប់ទាំងអស់អាចរៀបចំឯកសារជាថ្មីត្រឡប់ទៅវិញដោយស្របច្បាប់ ៖«យើងគឺភាគច្រើនគឺនៅទីនោះ ស្ទើរតែ១០០%គឺស្របច្បាប់ ហើយខ្ញុំគិតថា អ្នកដែលមិនស្របច្បាប់ប្រហែលជាមាន ប៉ុន្តែតិចតួចណាស់ ហើយយើងក៏អំពាវនាវពីនេះទៅដែរ បើបងប្អូនណារស់នៅ

ដោយមិនស្របច្បាប់ហ្នឹង គឺសុំឲ្យរៀបចំខ្លួនធ្វើឲ្យវាស្រប់ច្បាប់ តាមរយៈការចាក់ចេញមកសិន ហើយចាំយើងប្រឡងត្រឡប់ទៅវិញ»។

យោងតាមសេចក្តីប្រកាសរបស់ប្រទេសកូរ៉េកាលថ្ងៃទី០១ ខែតុលា ប្រាប់ថា ក្រសួងយុត្តិធម៌ នៃសាធារណៈរដ្ឋកូរ៉េខាងត្បូង បានចាប់ផ្តើមពង្រឹងវិធានការប្រឆាំង នឹងពលករបរទេសទាំងអស់ ដែលកំពុងធ្វើការងារដោយខុសច្បាប់នៅក្នុងវិស័យឧស្សាហកម្មនានា ដូចជាការងារសំណង់ ឬកន្លែងកម្សាន្តសម្រាប់មនុស្សពេញវ័យ ក៏ដូចជាកន្លែងម៉ាស្សា ដែលជាការជ្រៀតចូលកនៅក្នុងទីផ្សារការងារក្នុងស្រុក និងជាក្តីព្រួយបារម្ភចំពោះវប្បធម៌កូរ៉េផងដែរ។

ប្រទេសកូរ៉េ បានបញ្ជាក់ថា ខ្លួនទុករយៈពេល ៦ខែ សម្រាប់ការចាកចេញដោយស្ម័គ្រចិត្ត គ្រប់ជនបរទេសទាំងអស់ មិនថា កំពុងស្នាក់នៅ ឬកំពុងធ្វើការឡើយ ឲ្យតែខុសច្បាប់ ។ រយៈពេលកំណត់នេះ គឺចាប់ផ្តើមពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។ ប្រទេសកូរ៉េ សង្កត់ធ្ងន់ថា ក្រោយពីផុតរយៈពេលនេះ ខ្លួននឹងចាត់វិធានការតឹងរ៉ឹងបំផុត ដោយចុះត្រួតពិនិត្យគ្រប់កន្លែង ហើយបើចាប់បានថា ជាពលករបរទេសខុសច្បាប់ បុគ្គលនោះ នឹងត្រូវបញ្ជូនចេញពីប្រទេសកូរ៉េភ្លាមៗ ហើយជាប់ឈ្មោះក្នុងបញ្ជីខ្មៅ នឹងហាមការចូលដាន់ដីកូរ៉េខាងត្បូងរយៈពេល ១០ឆ្នាំ ដោយមិនគិត ពីរយៈពេលដែលបានធ្វើការនៅប្រទេសនេះឡើយ។

បន្ថែមពីនេះ សេចក្តីប្រកាសបានបញ្ជាក់ទៀតថា យុទ្ធនាការណ៍បោសសម្អាតជនបរទេសខុសច្បាប់នេះ គឺជា "គោលនយោបាយមួយជំហានឈ្នះ" ។ គោលនយោបាយមួយជំហានឈ្នះនេះ នឹងត្រូវអនុវត្តដូចគ្នាចំពោះជនបរទេសទាំអស់ រួមទាំងនិស្សិតបរទេស ក៏ដូចជា សមាជិកគ្រួសារ នៃជនអន្តោប្រវេសន៍ ដែលបានរៀបអាពាហ៍ពិពាហ៍ ជាមួយជនបរទេសដែលធ្វើការដោយខុសច្បាប់ នៅក្នុងវិស័យឧស្សាហកម្មដែលបានរៀបរាប់ខាងលើ។

សូមជម្រាបថា បើគិតមកដល់ឆ្នាំ២០១៨នេះ ប្រជាពលរដ្ឋកម្ពុជា ដែលបានចាកចេញពីប្រទេសទៅធ្វើជាពលករនៅប្រទេសកូរ៉េខាងត្បូងអាចមានចំនួនជិត ៦មឺននាក់ ដែលកំពុងបំពេញការងារក្នុងវិស័យសំខាន់ៗមួយចំនួន មានដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសំណង់៕

## ដំណឹងល្អ! ស្ថានទូតខ្មែរប្រចាំកូរ៉េខាងត្បូង នឹងចុះផ្តល់សេវាពន្យាសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ ជូនពលករខ្មែរ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨

http://api.tnaot.com/ ថ្ងៃពុធ ទី២៤ ខែតុលា ឆ្នាំ២០១៨

(សេអ៊ូល, កូរ៉េខាងត្បូង)៖ ដំណឹងល្អ! ស្ថានទូតខ្មែរប្រចាំកូរ៉េខាងត្បូង នឹងចុះផ្តល់សេវាពន្យាសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ ជូនពលករខ្មែរ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨។

ប្រភព៖ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកំពុងរស់នៅ សិក្សា និងធ្វើការ នៅសាធារណរដ្ឋកូរ៉េឱ្យបានជ្រាបថា ក្នុងគោលបំណងចូលរួមកាត់បន្ថយចំណាយ និងពេលវេលារបស់បងប្អូន ព្រមទាំងដើម្បីអនុវត្តយន្តការបង្វិលសេវាឱ្យកៀកជិតប្រជាពលរដ្ឋខ្មែរកាន់តែទូលំទូលាយ ស្ថានឯកអគ្គរាជទូតកម្ពុជា បានសហការជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេសទីក្រុងអ៊ីនធន់ នឹងចុះផ្តល់សេវាពន្យាសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ ប្រឹក្សាយោបល់ផ្នែកច្បាប់ការងារ និងផ្សព្វផ្សាយកម្មវិធីវិលត្រឡប់វិញក្រោយចប់អាណត្តិការងារ នៅថ្ងៃអាទិត្យទី២៨ ខែតុលា ឆ្នាំ២០១៨។

គួរបញ្ជាក់ដែរថា គិតត្រឹមខែតុលា ក្នុងឆ្នាំ២០១៨ ស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ បានរៀបចំកម្មវិធីចុះពន្យាសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ និងប្រឹក្សាយោបល់លើច្បាប់ការងារ នៅនឹងកន្លែងជូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សា នៅទីក្រុងនានា នៃសាធារណរដ្ឋកូរ៉េ បានចំនួន ៧លើក ស្មើនឹងជាង១៣០០ លិខិតឆ្លងដែន ដោយពុំចាំបាច់ឱ្យប្រជាពលរដ្ឋ ពិបាកចំណាយថវិកា និងពេលវេលា ធ្វើដំណើរមកបន្តនៅទីក្រុងសេអ៊ូល៕

# រដ្ឋមន្ត្រីការងារប្រទេសគូវ៉ែត ប្តេជ្ញាធានាសុវត្ថិភាពដល់ពលករកម្ពុជា

http://bayontv.com.kh/ 25/10/2018

ភ្នំពេញ ៖ លោកជំទាវ ហ៊ីន អាល់ សាប៊ី (HE. Mrs. Hind Al-Sabeeh) រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ និងជា រដ្ឋមន្ត្រីសេដ្ឋកិច្ច នៃរដ្ឋគូវ៉ែត បានជម្រាបជូនសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៥ ខែតុលា នេះថា ប្រទេសគុវ៉ែត នឹងធានា ដល់សុវត្ថិភាពពលពលករកម្ពុជាដែលនឹងទៅបំរើការងារ និងស្នាក់នៅក្នុងប្រទេសគូវ៉ែតនៅក្នុងឆ្នាំ ២០១៩ នេះ ដោយខាងរដ្ឋាភិបាលប្រទេសគុយវ៉ែត នឹងផ្តល់លក្ខណៈល្អដល់ ពលករកម្ពុជា ក៏ដូចជាពលករមកពីប្រទេសផ្សេងៗទៀត អោយទទួលបានអត្តប្រយោជន៍ស្មើរៗ គ្នា ។ លោកជំទាវ បន្តថា ក្នុងតំណើរទស្សនកិច្ចរបស់លោកជំទាវនៅពេលនេះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការដែលមានស្រាប់រវាងប្រទេសទាំងពីរ អោយកាន់តែល្អប្រសើរថែមទៀត។ មួយវិញទៀត គឺ ដើម្បីមកធ្វើការជាមួយសមភាគីកម្ពុជា គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការចុះកិច្ចព្រមព្រៀងបញ្ជូនពលករទៅបំរើការងារនៅក្នុងប្រទេសគុវ៉ែត ដោយក្នុងនោះ ភាគីទាំងពីរបានឯកភាពគ្នាក្នុងបញ្ជូនពលកររបស់ខ្លួនចំនួន ៥ពាន់នាក់ ទៅបម្រើការងារលើកដំបូងនៅប្រទេសគុយវ៉ែតនៅក្នុងឆ្នាំ២០១៩ ខាងមុខនេះ ។ លោកជំទាវ បានស្នើរដល់សម្តេចប្រធានរដ្ឋសភាជួយគាំទ្រចំពោះកិច្ចព្រមព្រៀង និងអនុស្សារណៈផ្សេងៗនៃប្រទេសប្រទេសទាំងពីរ និងការបញ្ជូនពលករទៅបំរើការនៅក្នុងប្រទេសគុវ៉ែតផងដែរ។

ជាការឆ្លើយតប សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា បានសម្តែងការស្វាគមន៍ចំពោះលោកជំទាវ កជំទាវ ហ៊ីន អាល់ សាប៊ី (HE. Mrs. Hind Al-Sabeeh) រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ និងជារដ្ឋមន្ត្រីសេដ្ឋកិច្ច នៃរដ្ឋគូវ៉ែត ក្នុងដំណើរទស្សនកិច្ចរបស់លោកជំទាវនៅក្នុងប្រទេសកម្ពុជា ដែលនេះ សបញ្ជាក់ថាជាកាលានុវត្តថ្មីមួយទៀតនៃប្រទេសទាំងពីរក្នុងការរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការអោយកាន់តែរឹងមាំបន្ថែមទៀត ។ សម្តេច ប្រធានរដ្ឋសភា ក៏បានវាយតម្លៃខ្ពស់ចំពោះជំនួបទ្វេភាគីរវាងលោកជំទាវរដ្ឋមន្ត្រី និង ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលបានលទ្ធផលជាផ្លែផ្កា ដោយក្នុងនោះសម្តេចបានស្នើរដល់ភាគីទាំងពីរបន្តធ្វើកិច្ចសហប្រតិបត្តិការអោយកាន់តែល្អថែមមួយកម្រិតទៀត។

បើតាមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម អ៊ិត សំហេង បញ្ជាក់ថា កម្ពុជានឹងរៀបចំកម្លាំងពលកម្មរបស់ខ្លួន ដែលបានជ្រើសរើសគ្រប់លក្ខខណ្ឌចំនួន ៥ពាន់នាក់ ជាលើកដំបូង ទៅបម្រើការងារនៅប្រទេសគុយវ៉ែត ហើយកម្លាំងពលកម្មនេះ ជាកម្លាំងពលកម្មគ្រប់ផ្នែក ទាំងផ្នែកសេវាកម្ម ឧស្សាហកម្ម និងកសិកម្ម៕

## ពលរដ្ឋរស់នៅតំបន់ជាប់ព្រំដែនទទួលបានការផ្សព្វផ្សាយពីបទបញ្ញាត្តិព្រំដែន

http://cambodiapolice.com/ 7:13 pm 24 តុលា 2018 113

**ក្រចេះ៖** លោកវរសេនីយ៍ត្រី យុន ម៉ន នាយប៉ុស្តិ៍នគរបាលការពារព្រំដែនត្រពាំងស្រែ បានឲ្យដឹងថា ពលរដ្ឋខ្មែរ និងខ្មែរឥស្លាម ដែលរស់នៅតាមភូមិនានាក្នុងឃុំ២ធ្នូ ស្រុកស្នួល ក្បែរនិងបន្ទាត់ព្រំដែនកម្ពុជានិងវៀតណាមទទួលបានការផ្សព្វផ្សាយពីនគរបាលព្រំដែន ស្តីពីបទបញ្ញាតិព្រំដែន។ លោកវរសេនីយ៍ត្រី យុន ម៉ន បានឲ្យដឹងទៀតថា ការផ្សព្វផ្សាយបទបញ្ញាត្តិព្រំដែនពីនគរបាលការពារព្រំដែនជូនដល់ពលរដ្ឋឲ្យពួកគាត់យល់ដឹងពីការលួចឆ្លងដែនដោយខុសច្បាប់នេះ បានធ្វើឡើងនៅក្នុងវេទិការសាធារណៈមួយរវាងពលរដ្ឋនៅឃុំ២ធ្នូ ជាមួយនិងអាជ្ញាធរឃុំ។ ការផ្សព្វផ្សាយបទបញ្ញាតិព្រំដែននេះ គឺបានធ្វើឡើងទៅតាមទិសដៅនិងផែនការសកម្មភាពរបស់លោកឧត្តម

សេនីយ៍ទោ លន់ សុផាត ស្នងការនគរបាលខេត្ត ដែលជំរុញឲ្យនគរបាលព្រំដែនបន្តការចុះល្បាតតាមព្រំដែន និងការផ្សព្វផ្សាយបទបញ្ញត្តិព្រំដែនឲ្យពលរដ្ឋបានយល់ ដើម្បីកុំឲ្យពួកគាត់មានការលួចឆ្លងដែនដោយខុសច្បាប់៕

## ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨

## សង្គមស៊ីវិលព្រួយបារម្ភពីគម្រោងបញ្ជូនពលករខ្មែរ៥ពាន់នាក់ទៅប្រទេសគុយវ៉ែត

https://www.rfa.org/khmer/news/ 2018-10-25

សង្គមស៊ីវិល សម្តែងការព្រួយបារម្ភថា ពលករខ្មែររាប់ពាន់នាក់ ដែលរបបក្រុងភ្នំពេញគ្រោងបញ្ជូនទៅប្រទេសគុយវ៉ែត (Kuwait) អាចជួបប្រទះនឹងការរំលោភសិទ្ធិការងារ និងសិទ្ធិមនុស្សដោយសារតែប្រទេសនេះ មិនទាន់មានលក្ខខណ្ឌការងារល្អប្រសើរនៅឡើយ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្លែងថា កម្ពុជា នឹងរៀបចំ កម្លាំងពលកម្មរបស់ខ្លួន ដែលបានជ្រើសរើសគ្រប់លក្ខខណ្ឌចំនួន ៥ពាន់នាក់ ជាលើកដំបូងទៅ បម្រើការងារនៅប្រទេសគុយវ៉ែត ហើយកម្លាំងពលកម្មនេះ ជាកម្លាំងពលកម្មគ្រប់ ផ្នែកទាំងផ្នែក សេវាកម្ម ឧស្សាហកម្ម និងកសិកម្ម។ លោក អ៊ិត សំហេង បញ្ជាក់ដែរ ចំពោះលក្ខខណ្ឌជ្រើសរើសពលករទៅបម្រើការងារ ត្រូវមានការបណ្តុះបណ្តាលជាមុន ដើម្បីឱ្យស្គាល់ពីស្ថានភាពប្រទេស ស្គាល់ពីវប្បធម៌ និងជំនាញការងារ ពិសេសលក្ខខណ្ឌក្នុងការរស់នៅទីនោះ។

ព័ត៌មាននៃការបញ្ជូនពលករខ្មែរនេះ ធ្វើឡើងបន្ទាប់ពីលោក អ៊ិត សំហេង ជួបពិភាក្សាការងារជាមួយ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច នៃរដ្ឋគូវ៉ែត លោកស្រី ហែន សុបៃ អាល់សុបៃ (Hend Subaih B ALSUBAIH) កាលពីថ្ងៃទី២៤ ខែតុលា នេះ។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធការងារ និងសិទ្ធិមនុស្ស លោក ឌី ថេហូយ៉ា សម្តែងក្តីបារម្ភថា ពលករខ្មែរអាចប្រឈមបញ្ហាមួយចំនួនដោយសារប្រទេសគុយវ៉ែត ស្ថិតនៅក្នុងតំបន់មជ្ឈិមបូព៌ា ឆ្ងាយ និងមានលក្ខណៈប្រពៃណីវប្បធម៌សាសនាខុសគ្នាខ្លាំងពីកម្ពុជា។ ជាពិសេសប្រទេសតំបន់នោះ ភាគច្រើន មានរបៀប ដឹកនាំតាមបែបសង្គមនិយម ឬរាជនិយមផ្តាច់ការ និងមិនមានអង្គការសិទ្ធិមនុស្សនោះទេ។ម្យ៉ាងវិញទៀត លោកមិនទាន់ទុកចិត្តថា ប្រទេសនេះ អាចគោរពលក្ខខណ្ឌការងារ បានល្អ និងប្រាក់ខែសមរម្យនោះទេ ព្រោះកម្ពុជា ធ្លាប់មានបទពិសោធន៍អាក្រក់ម្តងហើយរឿងបញ្ជូនពលករទៅប្រទេសបង់ក្លាដេស និងប្រទេសនេប៉ាល់ ដែលមិនបានផ្តល់ប្រាក់ខែតាមការ សន្យា និងបង្ខំអោយធ្វើការលើសកំណត់ជាដើម៖ «រឿងចំណាកស្រុកគឺជាជម្រើសរបស់ពលរដ្ឋ មិនមែនរឿងអាក្រក់ទេ តែរឿងអាក្រក់ គឺថា តើការបញ្ជូននោះ មានប្រព័ន្ធការពារល្អប៉ុណ្ណា ហើយប្រទេសដែលបញ្ជូនទៅជាប្រទេសគោរពសិទ្ធិមនុស្ស គោរពសិទ្ធិការងារឬអត់? ជាពិសេសនៅតំបន់មជ្ឈិមបូព៌ានេះគឺពិបាកមែនទែន អ៊ីចឹងជាយោបល់ខ្ញុំ គឺខ្ញុំមិនលើកទឹកចិត្ត អោយរដ្ឋាភិបាលបញ្ជូនពលករទៅធ្វើការម្ដុំនោះទេ រដ្ឋាភិបាល គួរតែបង្កើតជម្រើសការងារនៅក្នុងស្រុក តែបើសិនមិនមានជម្រើសការងារ ក្នុងស្រុកទេ គួរតែបញ្ជូនពលករទៅប្រទេសណាដែលមានលក្ខខណ្ឌការងារល្អ និងមានការគោរពសិទ្ធិមនុស្សជាដើម ដូចជាប្រទេសជប៉ុន ប្រទេសកូរ៉េជាដើម។ លោក ឌី ថេហូយ៉ា យល់ថា ដើម្បីធានាឲ្យមានយន្តការការពារពលករខ្មែរបានត្រឹមត្រូវ និងជៀសវាង រឿងហេតុរំលោភសិទ្ធិពលករ និងការកេងប្រវ័ញ្ចកម្លាំងពលករជាដើមនោះ គឺរបបទីក្រុងភ្នំពេញ គួរតែផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល ចូលរួមពិនិត្យតាមដានក្នុងដំណើរការជ្រើសរើសពលករ ដំណើរការបញ្ជូន និងទៅដល់ប្រទេសទទួលហើយរដ្ឋគួរតែមានលេខទូរស័ព្ទជួយសង្គ្រោះពលករ ពេលមានបញ្ហាជាដើម។

កម្ពុជាមានពលករចំណាកស្រុកជាង ១លាន ១៥សែននាក់ កំពុងធ្វើការទាំងស្របច្បាប់ និងមិនស្របច្បាប់ នៅប្រទេសចំនួន៥ ក្នុងនោះមាន ថៃ កូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន និងសិង្ហបុរី ហើយពួកគេបានផ្ញើថវិកាមកជូនក្រុមគ្រួសារវិញប្រមាណជិត ២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ៕

## *ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨*

## ពលរដ្ឋខ្មែរ៣នាក់ត្រូវក្រុមទាហានថៃចាប់ឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៨ ម៉ោង ១៤:៥១ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមទាហានថៃបានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ៣នាក់ដោយធ្វើដំណើរឆ្លងដែនខុសច្បាប់កាលពីវេលាម៉ោង ៦ និង៥៦នាទីយប់ ថ្ងៃទី២៨ តុលា ២០១៨ ដែលស្ថិតនៅក្នុងយាមការលេខ (V.A.001.882) ខណៈពលរដ្ឋខ្មែរទាំង៣រូបនេះមានគោលបំណងរុករកកាប់ឈើគ្រញូងនៅក្នុងទឹកដីថៃ ។ ហេតុការណ៍នេះកើតឡើងស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

ពលរដ្ឋខ្មែរ៣នាក់ដែលក្រុមទាហានថៃធ្វើការឃាត់ខ្លួនខាងលើរួមមាន ១-ឈ្មោះ ង៉ែត ព្រឹម ភេទប្រុស អាយុ៤៣ឆ្នាំ រស់នៅភូមិស្រែជា ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ២-ឈ្មោះ ហ៊ុន ពាន ភេទប្រុស អាយុ៤៤ឆ្នាំ រស់នៅភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុក ស្ទឹងសែន ខេត្តកំពងធំ និង៣-ឈ្មោះ សម រ៉ា ភេទប្រុស អាយុ២២ឆ្នាំ រស់នៅភូមិអំពួច ឃុំផ្ទះរ៉ុង ស្រុកក្រវ៉ាញ ខេត្តពោធិសាត់។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំ ដែលថៃហៅថា(ឆងសាងាំ)បានឱ្យដឹងថា ពលរដ្ឋខ្មែរទាំង៣នាក់នេះ ត្រូវបានក្រុមទាហានថៃចាប់បញ្ជូនខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជានៅវេលាម៉ោង២១យប់ក្នុងថ្ងៃដដែលក្រោយពីបានទទួលពលរដ្ឋខ្មែរទាំង៣រូបពីក្រុមទាហានថៃ ខណៈនោះសមត្ថកិច្ចបានធ្វើការសាកសួរនាំនឹងយោងទៅលើចម្លើយ គឺពួកគេមានគោលបំណងឆ្លងដែនចូលទៅក្នុងទឹកដីថៃរុករកកាប់ឈើគ្រញូងតែចូលបានជម្រៅប្រមាណ១គីឡូម៉ែត្រត្រូវបានទាហានថៃឃាត់ខ្លួនបានតែម្តង។ មន្ត្រីដដែលបានបញ្ជាក់ថា នៅថ្ងៃទី២៧ តុលា ២០១៨នេះ មានពលរដ្ឋខ្មែរម្នាក់បានឆ្លងដែនដោយខុសច្បាប់ឈ្មោះឈឹន ឆោម ភេទប្រុស អាយុ៣៧ឆ្នាំ មានគោលបំណងរកការងារធ្វើត្រូវបានទាហានថៃឃាត់ខ្លួនផងដែរនាំយកមកប្រគល់ឱ្យកម្ពុជាវិញ តែទោះជាបែបណាសមត្ថកិច្ចនៅមាត់ច្រកទ្វារអន្តរជាតជាំឱ្យពលរដ្ឋធ្វើកិច្ចសន្យាមិនឱ្យឆ្លងដែរខុសច្បាប់តទៅទៀត នឹងឱ្យវិលត្រឡប់ទៅលំនៅឋានវិញក្នុងថ្ងៃដដែលនោះ៕

## តើអ្វីដែលពលករខ្មែរត្រូវទទួលបាននៅពេលដែលចប់អាណត្តិហើយត្រឡប់ទៅវិញដោយស្ម័គ្រចិត្ត?

http://www.rasmeinews.com/ October 29, 2018, 3:57 PM ដោយៈរ៉ាម៉ន

ភ្នំពេញ៖ តើអ្វីដែលពលករត្រូវទទួលបាននៅពេលដែលចប់អាណត្តិ ហើយត្រឡប់ទៅវិញដោយស្ម័គ្រចិត្ត (Happy Return)? ទាំងនេះមាននៅក្នុងបទបង្ហាញរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស (HRD)។ ជាក់ស្តែងកាលពីរសៀលថ្ងៃអាទិត្យ ទី២៨ ខែតុលា នេះ ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េសហការជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេសប្រចាំទីក្រុងអ៊ីនធន់ ដើម្បីផ្តល់សេវាកម្មពន្យាសុពលភាពលិខិតឆ្លងដែនជូនដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងប្រកបការងារ រស់នៅ និងសិក្សានៅប្រទេសកូរ៉េ។ ពិធីនេះដោយមានការអញ្ជើញចូលរួមពីលោកឡុង ឌីម៉ង់ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េ។ ក្នុងកម្មវិធីនេះក៏មានធ្វើបទបង្ហាញពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ជូនដល់ពលករពីអត្ថប្រយោជន៍ដែលពួកគាត់ត្រូវទទួលបានក្នុងអំឡុងធ្វើការ និងក្រោយពេលពួកគាត់ចប់អាណត្តិហើយត្រឡប់ទៅ

ប្រទេសខ្មែរវិញដោយស្ម័គ្រចិត្តដោយ(មិនបន្តធ្វើជាពលករខុសច្បាប់)។

ក្នុងពិធីនោះដែរ លោកឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េបានសំណេះសំណាល សាកសួរសុខទុក្ខ និងផ្តល់ជាអនុសាសន៍ ការលើកទឹកចិត្ត តស៊ូអត់ធ្មត់នឹងការងារ ក៏ដូចជាត្រូវថែរក្សាសុខភាព និងសន្សំលុយកាក់ឱ្យបានគង់វង្ស។ស្ថានទូតក៏បើកឱ្យមានជាវេទិកាសាធារណៈ (ពលករលើកឡើងជាសំណួរ ចម្ងល់ ឬបញ្ហាប្រឈមផ្សេងៗ រីឯមន្ត្រីជំនាញរបស់ស្ថានទូតជាអ្នកឆ្លើយ និងដោះស្រាយចម្ងល់) ផងដែរ៕

## សមត្ថកិច្ចអាចនឹងដោះលែងស្ត្រីពពោះជំនួសក្រោយពួកគាត់ធានាចិញ្ចឹមទារក

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 29/10/2018

រាជធានីភ្នំពេញ ៖ សមត្ថកិច្ចអាចនឹងដោះលែងស្ត្រីពពោះជំនួស៣២នាក់ឲ្យនៅក្រៅឃុំ បន្ទាប់ពីស្ត្រីទាំងនោះបានធានាមានការ ថានឹងចិញ្ចឹមទារកដែលពួកគេបានពពោះជំនួស ដោយមិនបញ្ជូនទារកទាំងនោះទៅក្រៅប្រទេសនោះឡើយ ។

តាមសារព័ត៌មានក្នុងស្រុកបានចុះផ្សាយថា ក្រុមគ្រួសារស្ត្រីស៊ីឈ្នួលពពោះជំនួសបានទទូចឲ្យតុលាការនិងស្ថាប័នពាក់ព័ន្ធទាំងអស់ជួយអន្តរាគមន៍ដោះលែងស្ត្រីទាំងនោះឲ្យមានសេរីភាពវិញ ដោយពួកគេអះអាងថា ពួកគេមិនបានដឹងការពពោះជំនួសជាអំពើខុសច្បាប់ ហើយសន្យាថានឹងមិនបញ្ជូនទារកទាំងអស់នោះទៅឲ្យជនបរទេសដែលជួលពួកគេនោះទេ។

សូមជម្រាបថា កាលពីខែមិថុនា ឆ្នាំ២០១៨ អាជ្ញាធរក្រុងភ្នំពេញបានឃាត់ខ្លួនស្ត្រីពពោះជំនួស៣២នាក់ និងមនុស្ស៥នាក់ទៀតជាមេខ្យល់ ក្នុងនោះមានជនជាតិចិនម្នាក់ផងដែរ ក្រោយពីបានស្រាវជ្រាវរកឃើញថា ស្ត្រីទាំងនោះបានស៊ីឈ្នួលពពោះ ។ បន្ទាប់ពីការ ឃាត់ខ្លួនស្ត្រីទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមួយក្នុងទីក្រុងភ្នំពេញដោយមានការការពារពីមន្ត្រីមណ្ឌលកែប្រែ២ (ម២). ស្ត្រីជាង១០នាក់បានសម្រាលកូន ហើយអ្នកខ្លះសម្រាលបានកូនភ្លោះថែមទៀត ។

តាមសារព័ត៌មានក្នុងស្រុកមួយបានដកស្រង់សំដីលោកស្រី ជូ ប៊ុនអេង អនុប្រធាន អចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រឆាំងការជួញដូរមនុស្សនិងអនីតិជនមេធាវីការពារឲ្យស្ត្រីទាំង៣២នាក់កំពុងរៀបចំឯកសារដាក់ទៅតុលាការដើម្បីពិចារណាឲ្យបន្ធូរបន្ថយទោស ក៏ដូចជាដោះលែងក្រៅឃុំបណ្តោះអាសន្នផងដែរ ហើយអ្នកស្រីសង្ឃឹមថាតុលាការនឹងពិចារណាលើចំនុចទាំងនេះ ៕

## ឃាត់ខ្លួនចំនួន៤នាក់ដែលបម្រុងឆ្លងដែនខុសច្បាប់ទៅក្នុងទឹកដីថៃ

http://www.rasmeinews.com/ October 29, 2018, 8:26 AM

*ដោយបាយ័ន/បាត់ដំបង:* ប្រជាពលរដ្ឋចំនួន៤នាក់ត្រូវបានសមត្ថកិច្ចនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨២៣បានឃាត់ខ្លួនបន្ទាប់ពីប្រជាពលរដ្ឋទាំង៤នាក់បម្រុងនាំគ្នាដើរចូលឆ្លងដែនខុសច្បាប់ទៅទឹកដីថៃ។ ហេតុការណ៍ឃាត់ខ្លួននេះបានកើតឡើងស្ថិតនៅប៉ុស្តិ៍នគរបាលច្រកត៌៤០០ក្នុងភូមិសាស្រ្ត ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបងកាលពីវេលាម៉ោង១៣និង៤០នាទី ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ ។ សមត្ថកិច្ចប្រចាំច្រកតំបន់៤០០ បានបញ្ជាក់ថា កម្លាំងបានដើរល្បាតក៏ជួបប្រជាពលរដ្ឋចំនួន៤នាក់ដើរបម្រុងឆ្លងដែនខុសច្បាប់ក៏បានឃាត់ខ្លួនយកមកប៉ុស្តិ៍ដើម្បីសាកសួរនិងធ្វើកំណត់ហេតុ។ សមត្ថកិច្ចបានបន្តថា ប្រជាពលរដ្ឋទាំង០៤ដែលត្រូវបានឃាត់ខ្លួនគឺ មានទី១-ឈ្មោះ ម៉ៅ សុលី ភេទប្រុស អាយុ២៤ឆ្នាំ មានទីលំនៅ នៅភូមិអូរប្រាបឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។ ទី២-ឈ្មោះ ឯក លួន ភេទប្រុសអាយុ៣១ឆ្នាំ មានទីលំនៅនៅភូមិឆករកា ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់

ដំបង។ ទី៣-ឈ្មោះ អ៊ិន ភី ភេទប្រុស អាយុ៣២ឆ្នាំ មានទីលំនៅ នៅភូមិធករកា ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។ និងទី៤-ឈ្មោះ យាន វុន ភេទប្រុស អាយុ២៩ឆ្នាំ មានទីលំនៅ នៅភូមិធករកា ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។

ក្រោយពីឃាត់ខ្លួននិងធ្វើកំណត់ហេតុសាកសួររួច ប្រជាពលរដ្ឋទាំង៤នាក់ ត្រូវបានសមត្ថកិច្ចប្រចាំច្រកបានធ្វើការអប់រំណែនាំមិនអោយធ្វើការឆ្លងដែនខុសច្បាប់។ដូច្នេះហើយបានឱ្យធ្វើកិច្ចសន្យាបញ្ឈប់និងបញ្ជូនទៅទីលំនៅស្ថានវិញ។S/

## ពលរដ្ឋរិះគន់លោកឧត្តមសេនីយ៍ទោ ប៉ែន វយ មេបញ្ជាការកងពលតូចលេខ៤២ ថានៅពីក្រោយមេឈ្មួញឈើប្រណិតឆ្លងដែនឈ្មោះ ឈឿងស័ក្ក និងឈ្មោះ ដុះ

http://chnchannel.com/chnnewws/ ថ្ងៃទី 29 ខែ តុលា ឆ្នាំ 2018

**ឧត្តរមានជ័យ៖** មេឈ្មួញឈើប្រណិតឆ្លងដែនផ្តាច់មុខឈ្មោះ ឈឿង ស័ក្ក និងឈ្មោះ ដុះ ជានាទាហ៊ាននៅកងពលតូចលេខ៤២ និងអាងខ្នងលោកឧត្តមសេនីយ៍ទោ ប៉ែន វយ នៅពីក្រោយខ្នងចឹងសោះ បានពលករខ្មែររងគ្រោះដោយសារអាជ្ញាធរថៃចាប់ខ្លួន មិនស្រាកស្រាន។

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៨នេះ មានសេចក្តីរាយការណ៍មកថា មេឈ្មួញឈើប្រណិតឆ្លងដែនផ្តាច់មុខនៅតំបន់ទឹសទី៣ ឈ្មោះ *ឈឿង ស័ក្ក* និងឈ្មោះ ដុះ ជានាយទាហ៊ាននៅកងពលតូចលេខ៤២ របស់លោកឧត្តមសេនីយ៍ទោ *ប៉ែន វយ*។ ដោយមានការសង្ស័យថា មេបញ្ជាការកងពលតូចលេខ៤២ រូបនេះ ជាអ្នកនៅពីក្រោយខ្នងមេឈ្មួញ ឈើប្រណិតផ្តាច់មុខនៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ ទាំងពីនាក់ខាងលើនេះ។ ព្រោះមេឈ្មួញល្បីឈ្មោះ ទាំងពីនាក់ខាងលើ ឈ្មោះ *ឈឿង ស័ក្ក* និងឈ្មោះ *ដុះ* បានប្រព្រឹត្តបទល្មើសឈើឆ្លងដែនជាច្រើនឆ្នាំមកហើយ និងឈរជើងបាន នៅតំបន់ទឹសទី៣ នេះក៏ដោយសារតែការឃុបឃិតការបណ្តែតបណ្តោយ និងនៅពីក្រោយខ្នង ជាលោកឧត្តមសេនីយ៍ទោ *ប៉ែន វយ* ក្នុងនាមជាមេកើយ និងកូនចៅខ្លួន ដែលជាមូលហេតុធំបំផុតនៅពីក្រោយនៃការចាប់ខ្លួនពលករខ្មែរពីសំណាក់យោធាថៃ អត់ស្រាកស្រាន ដែលមិនអាចលុបបំបាត់បាន។

មានសេចក្តីរាយការណ៍ ពីសង្កាត់អូរស្មាច់ក្រុងសំរោងមកថា ឈ្មោះ *ដុះ* បានគាងគរពលករឆ្លងដែនកាប់ឈើស្រុកថៃ ចំណុចបង្គោលសីម៉ាលេខ១៣ រីឯឈ្មោះ *ឈឿងស័ក្ក* បានធ្វើសកម្មភាពដាក់ពលករឆ្លងដែន នៅចំណុចភ្នំបាក់ និងបានប្រម៉ូលទិញឈើប្រណិត ប្រភេទឈើធ្នង់ ឈើនាងនួន និងឈើក្រញូង នៅតំបន់ទឹសទី៣ទាំងមូលយ៉ាងអនាធិបតេយ្យ ដោយអាងអំណាចយោធា និងមានមេកើយនៅពីក្រោយខ្នងជួយជ្រោមជ្រែង ដើម្បីឱ្យសកម្មភាពបទល្មើសមេឈ្មួញទាំងពីខាងលើប្រកបទៅយ៉ាងរលូន ដោយគ្មានសមត្ថកិច្ចខេត្តឧត្តរមានជ័យណាម្នាក់ហ៊ានប៉ះពាល់បានឡើយ។

លោកឧត្តមសេនីយ៍ទោ *ប៉ែន វយ* មេបញ្ជាការកងពលតូចលេខ៤២ បានឱ្យដឹងតាមទូស័ព្ទថានៅថ្ងៃទី២៩ ខែតុលានេះថា ចំពោះសកម្មភាពប្រព្រឹត្តបទល្មើសឈើប្រណិតឆ្លងដែនមន្ត្រីយោធារបស់លោក លោកឈ្មោះ *ឈឿង ស័ក្ក* និងឈ្មោះ *ដុះ* ជាច្រើនឆ្នាំមកនេះ លោកពិតជាដឹង លោកឧត្តមសេនីយ៍ទោ *ប៉ែន វយ* បានបញ្ជាក់ថា បើឃើញវាប្រព្រឹត្តមិច ក៏មិនសហការជាមួយសមត្ថកិច្ចអាជ្ញាធរចាប់ទៅ ហើយឱ្យដឹងថាម៉ាស្រុកខ្មែរមានតែពីនាក់នឹងទេ បើមានតែពួកវាពីនាក់នឹងទេចាប់វាទៅ។BRT

## កូនត្រូវគេលួចចាប់យកបាត់ ៣ឆ្នាំក្រោយជួបក្មេងសុំទានស្រែកហៅថាម៉ែ ម៉ែ តែនាងមិនទទួលស្គាល់ ចុងក្រោយព្រោះ...!

http://www.cen.com.kh/archives/ October 30, 2018

ម្ដាយលើលោកនេះ តែងទុកកូនជាក្ដីសង្ឃឹម ជាគោលដៅនៃជីវិត ។ នារីចិនម្នាក់ឈ្មោះ DIEM ក្រោយពេលរៀបការក៏បង្កើតបានកូនប្រុសម្នាក់ ។ គ្រួសារតូចរបស់នាងពិតជាសុភមង្គលណាស់ ប៉ុន្តែឆាកជីវិតពិតជាពុំខ្វះរឿងស្មានពុំដល់ទេ ។ ពេលកូនប្រុសអាយុបាន ៦ឆ្នាំ ថ្ងៃមួយពួកគេ នាំគ្នាដើរលេង ក៏ស្រាប់តែកូនប្រុសសម្លាញ់ត្រូវគេលួចចាប់យកទៅបាត់ ។ ពួកគេពិតជារន្ធត់ចិត្ត ដើររកសព្វកន្លែង តែពុំឃើញសោះ ។ ៣ឆ្នាំកន្លងផុត ថ្ងៃមួយនាង DIEM កំពុងដើរតាមផ្លូវក៏ឮស្នូរហៅថា "ម៉ែៗ" ។ នាងងាកមកក្រោយ ក៏ឃើញក្មេងសុំទានម្នាក់ ស្លៀកពាក់រយ៉េរយ៉ៃ ខ្លួនប្រាណប្រឡាក់ប្រឡូសសុទ្ធតែដី ហើយស្រែកហៅ... ម៉ែៗ មិនដាច់ពីមាត់ ។ ៣ឆ្នាំហើយមែន តែនាងដឹងច្បាស់ថា វាគឺជាកូនរបស់នាង ប៉ុន្តែ... ។ នាងសម្រេចចិត្តឆ្លើយតបយ៉ាងខ្លី ៖ "ឃើ! មកពីណាហ្នឹង ខ្ញុំពុំមែនជាម្ដាយរបស់ឯងទេ!" ហើយក៏ដើរចេញយ៉ាងលឿន ។ ឃើញបែបនេះ ក្មេងសុំទានរូបនោះ ស្រែកយំយ៉ាងខ្លាំងៗថា ៖ ម៉ែ ! ហេតុអ្វីម៉ែមិនស្គាល់កូនអីចឹង! ម៉ែ ម៉ែ... ។

១០ថ្ងៃក្រោយ ប៉ូលិសក្រសោបបានក្រុមជួញដូរក្មេង១ក្រុមធំ ហើយរំដោះបានក្មេងៗជាច្រើន ដែលត្រូវពួកវាចាប់មកឲ្យដើរសុំទានចិញ្ចឹមក្រុមវា ។ ក្នុងនោះក៏មានកូននាង DIEM ផងដែរ ។ ពេលនោះឯងទើបរឿងពិតត្រូវបានទម្លាយចេញគឺនាង DIEM ពិតជាដឹងថា ក្មេងថ្ងៃនោះជាកូនរបស់នាង តែនាងសម្រេចចិត្តសងសឹកពួកឧក្រិដ្ឋជនដែលពុំមែនធ្វើបាបតែកូននាងម្នាក់នោះទេ ។ មានម្ដាយ ឪពុកច្រើននាក់ទៀត ក៏រងការឈឺចាប់ដូចនាងដែរ ។ ដូច្នេះនាងសម្រេចចិត្តធ្វើមិនស្គាល់ តែនាងបានរត់ទៅរាយការណ៍ឲ្យប៉ូលិសរឿងរ៉ាវនេះក៏ដូចជាឃ្លាំមើលការពារកូននាង ។ ពិតណាស់! នាងជាម្ដាយអស្ចារ្យ ហើយពុំសម្រាប់តែកូនខ្លួនប៉ុណ្ណោះទេ ។ ការឈឺចាប់របស់នាងប្រាកដជាធំធេងណាស់ ទើបនាងមានគោលគំនិតចែករំលែកសម្រាលទុក្ខរបស់ម្ដាយដទៃទៀតដូចជារូបនាង ។ គួរឲ្យសរសើរមែន! បើអ្នកវិញ អ្នកនឹងធ្វើបែបណា? ចន្ទ្រា

### *ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨*

## នគរបាលកម្ពុជា-ថៃ នឹងបើកកិច្ចប្រជុំទ្វេភាគីតាមបណ្ដាខេត្តជាប់ព្រំដែនប្រទេសទាំងពីរ នៅដើមឆ្នាំក្រោយ បន្ទាប់ពីអាក់ខានមួយរយៈ

http://ppd-news.net **Posted By: admin** October 30, 2018

រាជធានីភ្នំពេញ ៖ អគ្គស្នងការនគរបាលជាតិនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន បានលើកឡើងថា នគរបាលជាតិកម្ពុជា និងនគរបាលភូមិន្ទថៃ គ្រោងនឹងបើកកិច្ចប្រជុំនគរបាលទ្វេភាគីតាមបណ្ដាខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ (កម្ពុជា-ថៃ) ខណៈដែលកិច្ចប្រជុំនេះត្រូវបានអាក់ខាននាពេលកន្លងមក ហើយភាគីទាំងពីរនឹងពិនិត្យលទ្ធភាពក្នុងការរៀបចំកិច្ចប្រជុំនេះនៅដើមឆ្នាំ២០១៩ ខាងមុខ ។

ការថ្លែងរបស់លោកឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ ធ្វើឡើងក្នុងជំនួបពិភាក្សាការងារជាមួយលោកបញ្ញយ៉ារ៉ាក់ ពុលថាប់ (PANYARAK POOLTHUP) ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨នេះ នាអគ្គស្នងការដ្ឋាននគរបាលជាតិ។ ក្នុងជំនួបនោះនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន មានប្រសាសន៍ថា វត្តមានរបស់លោក បញ្ញយ៉ារ៉ាក់ ពុលថាប់ (PANYARAK POOLTHUP) ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា នាពេលនេះ គឺជាការលើកទឹកចិត្តដល់នគរបាលជាតិកម្ពុជា ដែលពេលកន្លងមកនគរបាលជាតិកម្ពុជា និងនគរបាលភូមិន្ទថៃ

តែងតែបានសហការគ្នាយ៉ាងល្អក្នុងការទប់ស្កាត់បទល្មើសផ្សេងៗដូចជាៈ បទល្មើសភេរវកម្ម បទល្មើសគ្រឿងញៀន និងបទល្មើសឆ្លងដែនជាច្រើន ហើយជាពិសេសអាជ្ញាធរថៃក៏បានជួយគាំពារពាក់ព័ន្ធទៅនឹងពលករបរទេសដែលធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃផងដែរ ។

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ក៏បានបង្ហាញនូវគោលជំហរថា នឹងខិតខំប្រឹងប្រែងក្នុងការការពារសុវត្ថិភាព សុខសន្តិភាព ជូនដល់ភ្ញៀវទេសចរណ៍ និងវិនិយោគិនថៃ ក៏ដូចជាភ្ញៀវទេសចរណ៍ទាំងអស់ផងដែរ ហើយនៅពេលខាងមុខកម្ពុជាគ្រោងនឹងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំធំៗនានាដូចជាៈ កិច្ចក្រជុំអាយប៉ា (AIPA) នៅខេត្តសៀមរាប និងកិច្ចប្រជុំ អាស៊ានណាប៉ូល (Asenapol) នៅឆ្នាំ២០២០ ដែលទាំងនេះក៏ត្រូវការការសហការយ៉ាងល្អរវាងប្រតិភូថៃផងដែរ ។

ក្នុងជំនួបនោះដែរ លោក បញ្ញយ៉ារ៉ាក់ ពុលថាប់ (PANYARAK POOLTHUP) ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា បានកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងការបង្ការ និងបង្ក្រាបគ្រឿងញៀននាពេលកន្លងមក ហើយក៏បានបញ្ជូនតំណាងទៅធ្វើការនៅប្រទេសថៃ ដើម្បីទប់ស្កាត់នូវបញ្ហានេះផងដែរ ។ ជាពិសេសនគរបាលជាតិកម្ពុជា នៅពេលកន្លងមកបានការពារភ្ញៀវទេសចរណ៍ ក៏ដូចជាវិនិយោគិនថៃ ដែលកំពុងតែរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការការពារយ៉ាងជិតដល់និវេសនដ្ឋាន និងស្ថានទូតថៃ ប្រចាំនៅកម្ពុជាផងដែរ ។ លោក បញ្ញយ៉ារ៉ាក់ ពុលថាប់ (PANYARAK POOLTHUP) ក៏បានលើកឡើងអំពីកិច្ចសហប្រតិបត្តិការយ៉ាងល្អពាក់ព័ន្ធទៅនឹងការការពារព្រំដែនរវាងប្រទេសទាំងពីរនាពេលកន្លងមក ហើយឯកឧត្តម ក៏បានរំពឹងទុកថា នឹងបានជួបប្រជុំពាក់ព័ន្ធទៅនិងការងារព្រំដែននេះរវាងថៃនិងកម្ពុជា នៅពេលឆាប់ៗនេះផងដែរ ៕ *(អគ្គបទអគ្គស្នងការនគរបាលជាតិ)*

## ជប៉ុននឹងផ្តល់ ឱកាសការងារដល់យុវជនកម្ពុជា ជាមួយក្រុមហ៊ុនធំៗ នៅប្រទេសជប៉ុន

http://www.cen.com.kh/archives/ October 31, 2018

ភ្នំពេញៈ បច្ចុប្បន្នយុវជនកម្ពុជា មានសមត្ថភាព ដូចយុវជនដទៃទៀត នៅតាមបណ្តាលប្រទេសមួយចំនួនដែរដូច្នេះជប៉ុននឹងផ្តល់ ឱកាសការងារដល់យុវជនកម្ពុជា ជាមួយក្រុមហ៊ុនធំៗ នៅប្រទេសជប៉ុន។ នាទីស្តីការក្រសួង រសៀលថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុញ្ញាតឲ្យលោក Yohei Shibasaki នាយកប្រតិបត្តិនៃក្រុមហ៊ុន Fourth Valley Concierge ជាក្រុមហ៊ុនដ៏ធំមួយរបស់ជប៉ុនក្នុងការផ្តល់ ឱកាសការងារដល់យុវជន សិស្សនិស្សិតនៅតាមបណ្តាលប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីមានឪកាស ទៅធ្វើការនៅប្រទេសជប៉ុន។

លោកនាយកប្រតិបត្តិក្រុមហ៊ុន លើកឡើងថា គោលបំណងដែលរូបលោក និងក្រុមការងារចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោករដ្ឋមន្ត្រីនាពេលនេះ គឺដើម្បីសុំកិច្ចគាំទ្រពីខាងក្រសួងការងារ និងបណ្តុះបណ្តលវិជ្ជាជីវៈ ដើម្បីបើកការិយាល័យក្រុមហ៊ុននៅកម្ពុជា ក្នុងការបណ្តុះបណ្តាលយុវជនកម្ពុជា មុននឹងបញ្ជូនទៅបម្រើការងារនៅប្រទេសជប៉ុន។ លោកនាយកប្រតិបត្តិក្រុមហ៊ុន លើកឡើងថា ក្រុមហ៊ុនរបស់លោកមានបទពិសោធន៍១០ឆ្នាំមកហើយ នៅតំបន់អាស៊ីអាគ្នេយ៍ គឺទទួលបានជោគជ័យជាខ្លាំង ។ លោកថា បច្ចុប្បន្ននេះយុវជន

កម្ពុជា ក៏មានសមត្ថភាព ដូចយុវជនដទៃទៀត នៅតាមបណ្តាលប្រទេសមួយចំនួនដែរ ដែលទទួលបានឱកាសទៅធ្វើការនៅប្រទេសជប៉ុន។

ឆ្លើយតបទៅនឹងគោលបំណងនេះលោកមរដ្ឋមន្រ្តី រីករាយស្វាគមន៍ និងគាំទ្រចំពោះសំណើនេះ ដោយលោករដ្ឋមន្រ្តីស្នើដល់ក្រុមហ៊ុន ត្រូវរៀបចំឯកសារតាមនីតិវិធី ដែលតម្រូវទៅតាមច្បាប់ជាមុនសិន។ លោករដ្ឋមន្រ្តីមានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជារីករាយ និងស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការ ជាមួយរដ្ឋាភិបាលជប៉ុន ដែលមកដល់ពេលនេះកម្ពុជា មានក្រុមហ៊ុនសហគ្រាសជាច្រើន របស់ជប៉ុន ចូលមកវិនិ យោគនៅកម្ពុជា។ រីឯខាងផ្នែកវិស័យការងារវិញ កម្ពុជាក៏បានបញ្ជូនកម្មសិក្សាការីទៅធ្វើការនៅជប៉ុនក៏ច្រើនដែរ មកដល់ពេលនេះកម្មសិក្សាការីកម្ពុជា មានប្រហែលជាង៨ពាន់នាក់ កំពុងធ្វើកម្មសិក្សានៅទីនោះ ដែលនៅជប៉ុនមានកម្លាំងពលកម្មច្រើន ទាក់ទងទៅនឹងឧស្សាហកម្ម កសិកម្ម សេវាកម្ម និងថែទាំមនុស្សចាស់ជាដើម។

បើតាមការបញ្ជាក់ពីលោក ងុយ រិទ្ធ នាយករងខុទ្ទកាល័យលោករដ្ឋមន្រ្តីបានឲ្យដឹងថា ក្រុមហ៊ុននេះ នឹងរៀបចំដំណើរការផ្តល់ វគ្គបណ្តុះបណ្តាលដល់និស្សិតវ័យក្មេង ទទួលបានឱកាស ទៅធ្វើការនៅជប៉ុន ជាមួយនឹងក្រុមហ៊ុនល្បីៗដូចជាក្រុមហ៊ុនSONY ក្រុមហ៊ុនPANASONIC ក្រុមហ៊ុនHONDA និង ក្រុមហ៊ុនTOYOTAជាដើម។ ក្រុមហ៊ុននេះបានផ្តល់ ឱកាសទៅដល់ប្រទេសជាច្រើននៅក្នុងតំបន់ ហើយបច្ចុប្បន្នក្រុមហ៊ុននេះ បានពង្រីកខ្លួនមកដល់ប្រទេសកម្ពុជាដែរហើយ។ លោក ងុយ រិទ្ធ បញ្ជាក់ថា យុវជន និស្សិតកម្ពុជា នឹងទទួលបាននូវ ឱកាសចេញទៅធ្វើការនៅជប៉ុន ជាមួយក្រុមហ៊ុនធំៗ រយៈពេលពី៥ទៅ១០ឆ្នាំ។ នេះជា ឱកាសដែលយើងមិនធ្លាប់មានពីមុន ដែលពីមុនកម្ពុជាបញ្ជូនត្រឹមជាសិក្ខាកាម ឬជាអ្នកហាត់ការទេ មិនទាន់បានទទួលទិដ្ឋការការងារនៅឡើយទេ ប៉ុន្តែក្រុមហ៊ុននេះផ្តល់ ឱកាសឲ្យយុវជនកម្ពុជាទទួលបាននូវទិដ្ឋការការងារតែម្តង ធ្វើការបានរហូតពី៥ទៅ១០ឆ្នាំឯណោះ។ ពេលដែលយុវជនកម្ពុជាបានទៅធ្វើការជាមួយក្រុមហ៊ុនល្បីៗ ពួកគេនឹងមានសមត្ថភាពកាន់តែខ្ពស់ ខណៈបានវិលត្រឡប់មកបម្រើការងារឲ្យក្រុមហ៊ុនជប៉ុន នៅក្នុងប្រទេសជាតិវិញ ដែលជាប្រភពធនធានមនុស្ស ដ៏សំខាន់ចាំបាច់ ឆ្លើយតបទៅនឹងគោលនយោបាយ របស់រដ្ឋាភិបាលកម្ពុជា៕ ដោយៈបញ្ញាស័ក្តិ

## បុរសខ្មែរម្នាក់ស្លាប់ក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ថៃ

https://khmer.voanews.com 31 តុលា 2018 អូន ឆេងប៉ រ

ភ្នំពេញ៖ រដ្ឋាភិបាលថៃបានបញ្ជាក់ទទួលស្គាល់ថា បុរសសញ្ជាតិកម្ពុជាមួយរូប បានស្ថិតក្នុងចំណោមអ្នកជាប់ឃុំពីរនាក់ដែលត្រូវបានគេប្រទះឃើញថា បានស្លាប់បាត់បង់ជីវិត ក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍មួយកន្លែងក្នុងទីក្រុងបាងកក ប្រទេសថៃ កាលពីសប្តាហ៍មុន។ អាជ្ញាធរថៃបានបញ្ជាក់ថា ខ្លួនកំពុងតែស៊ើបអង្កេតមូលហេតុនៃការស្លាប់របស់អ្នកទាំងពីរ។

អ្នកស្រី Busadee Santipitak អ្នកនាំពាក្យក្រសួងការបរទេសថៃ បានប្រាប់VOAថា ជនជាតិខ្មែរមួយរូបដែលត្រូវបានកំណត់អត្តសញ្ញាណត្រឹមថាឈ្មោះ សាឃី (Sakhi) អាយុ៥៥ឆ្នាំ និងជនជាតិវៀតណាមមួយរូបឈ្មោះ Robat វ័យ៧៧ឆ្នាំ ត្រូវបានគេរកឃើញបានដេកស្លាប់ ខណៈដែលពួកគេកំពុងជាប់ឃុំក្នុង មន្ទីរឃុំឃាំងធំនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងខណ្ឌ ធុងមហាមេឃ(Thung Mahamek) កណ្តាលទីក្រុងបាងកកតែម្តង។ មន្ត្រីអ្នកនាំពាក្យរដ្ឋាភិបាលថៃរូបនេះបានប្រាប់VOAយ៉ាងដូច្នេះថា៖ «ពួកគេបានទទួលមរណភាពខណៈដែលកំពុង

លង់លក់ក្នុងជំណោក ដោយមិនមានស្លាកបួសស្នាមអ្វីឡើយ។ មូលហេតុដែលបានបណ្តាលឱ្យពួកគេស្លាប់ កំពុងត្រូវបានគេស៊ើបអង្កេតហើយ។ សាកសពរបស់ពួកគាត់ត្រូវបានបញ្ជូនទៅរក្សាទុកដើម្បីធ្វើកោសល្យវិច័យនៅមន្ទីរពេទ្យជូឡាឡុងកន ប្រទេសថៃ»។

របបសឹកដែលកំពុងគ្រប់គ្រងប្រទេសថៃ បានបើកយុទ្ធនាការថ្មីមួយទៀត ដើម្បីតាមចាប់ប្រមូលជនបរទេសដែលស្នាក់នៅធ្វើការក្នុងប្រទេសខ្លួន ដោយមិនមានលិខិតស្នាមគ្រប់គ្រាន់ រួមទាំងជនភៀសខ្លួន និងកុមារតូចៗផង នៅបន្ទាប់ពីការចូលកាន់តំណែងក្នុងខែតុលានេះ របស់លោក ស៊ូរាចិត្រ ហាក់ផាន់ (Surachet Hakphan) ជាអគ្គនាយកអន្តោប្រវេសន៍ថ្មីរបស់ប្រទេស។ ខណៈដែល នីតិវិធីដែលតម្រូវឱ្យអ្នកជាប់ឃុំ បង់ប្រាក់ជានានៅក្រៅឃុំ ប្រមាណ ១៥០០ ដុល្លារ ត្រូវបានគេលុបចោល ការចាត់វិធានការបង្រ្កាបលើជនបរទេសថ្មីមួយទៀតនេះ នឹងបង្កើនបន្ទុកដល់មន្ទីរឃុំឃាំងអន្តោប្រវេសន៍ដែលមានលក្ខណៈចង្អៀតណែនរួចជាស្រេចទៅហើយ។ នេះបើយោងតាមលោក ហ្វីល រ៉ូប៊ឺតសុន (Phil Robertson) នាយករងផ្នែកតំបន់អាស៊ី នៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch។

លោក Phil Robertson បានប្រាប់VOA តាមសារអេឡិចត្រូនិចក្នុងន័យដើមយ៉ាងដូច្នេះថា៖ «សួនភ្លូ-IDC ជាគ្រឹះស្ថានចាស់មួយកន្លែង ដែលមានលក្ខណៈចង្អៀតណែនក្នុងសភាពមិនគួរឱ្យជឿ និងកង្វះអនាម័យជាទីបំផុត ហើយទីតាំងនេះ ពុំមានលទ្ធភាពគ្រប់គ្រាន់នោះទេ ក្នុងការផ្តល់អាហារូបត្ថម្ភប្រកបដោយជីវជាតិ និងសេវាថែទាំសុខភាពក្នុងកម្រិតស្តង់ដា»។ អ្នកឃ្លាំមើលសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅទីក្រុងបាងកករូបនេះ បានប្រាប់VOA ជាបន្តថា៖ «ជាមួយនឹងស្ថានភាពដែលឃើញថាអាក្រក់ប៉ុណ្ណា បូករួមផ្សំនឹងការកើនឡើងយ៉ាងគំហុកភ្លាមៗនៃជនដែលត្រូវបានជាប់ឃុំ ក្នុងការប្រមូលចាប់ជនអន្តោប្រវេសន៍នេះ វាសមហេតុផលក្នុងការរំពឹងថា នឹងមានមនុស្សជាច្រើនផ្សេងទៀត នឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរនៅទីតាំងមួយនេះ»។

VOAមិនអាចទាក់ទងស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងបាងកក បូករួមទាំងបណ្តាអ្នកនាំពាក្យនៅក្រសួងការបរទេសនិងក្រសួងការងារ ដើម្បីស្នើសុំការបំភ្លឺបានទេ នៅថ្ងៃអង្គារនេះ ដោយខ្សែទូរស័ព្ទដែលផ្តល់ជូនទាំងអម្បាលមាណ បានរោទិ៍តែពុំមានអ្នកទទួលឆ្លងឆ្លើយ។

គួរបញ្ជាក់ផងដែរថា យុទ្ធនាការបង្ក្រាបថ្មីមួយទៀតទៅលើជនអន្តោប្រវេសន៍រស់នៅខុះឯកសារនេះ ធ្វើឡើងនៅចំពេលដែលប្រទេសកំពុងត្រៀមខ្លួនរៀបចំដំណើរឈានទៅរកការបោះឆ្នោតសកលមួយនៅដើមឆ្នាំ២០១៩ខាងមុខ ជាការបោះឆ្នោតលើកដំបូង ក្នុងរយៈពេលជាង៤ឆ្នាំចុងក្រោយ ចាប់តាំងពីក្រុមទាហានបានដណ្តើមកាន់កាប់អំណាចរដ្ឋបាលស៊ីវិល ក្នុងរដ្ឋប្រហារឆ្នាំ២០១៤មក។ នៅក្រោយរដ្ឋប្រហារភ្លាមៗកាលពីឆ្នាំ២០១៤ របបសឹកថៃបានចាត់វិធានការបណ្តេញពលកររស់នៅធ្វើការមិនស្របច្បាប់ចេញពីក្នុងប្រទេសខ្លួន ដែលគ្រានោះ ជនជាតិកម្ពុជាប្រមាណ២២ម៉ឺននាក់ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកស្រុកវិញ។ របាយការណ៍របស់រដ្ឋាភិបាលថៃបានបញ្ជាក់ថា មានប្រជាជនកម្ពុជាប្រមាណ១,៥លាននាក់ កំពុងធ្វើការក្នុងប្រទេសថៃ។

បណ្តាញសារព័ត៌មាននានា បានដកស្រង់សម្តីលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ ដែលបានថ្លែងកាលពីខែឧសភាកន្លងទៅថា នៅក្រោយពីការចាត់វិធានការរបស់រដ្ឋាភិបាលខ្មែរ ក្នុងការចុះបញ្ជីផ្តល់ភាពស្របច្បាប់ដល់ពលរដ្ឋខ្លួន ធ្វើការក្នុងប្រទេសថៃ មានពលរដ្ឋខ្មែរប្រមាណតែ៨ម៉ឺននាក់ផ្សេងទៀតតែប៉ុណ្ណោះ ដែលមិនទាន់បានចុះបញ្ជីការធ្វើការស្របច្បាប់ក្នុងប្រទេសដែលនៅក្បែរខាងមួយនេះ៕

# អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ៣នាក់អោយវិលត្រលប់មកស្រុកកំណើតវិញ

http://www.rasmeinews.com/ October 31, 2018, 9:41 AM

**ដោយ : បាយ័ន/ឧត្តរមានជ័យ** :អាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន៣នាក់ អោយវិលត្រលប់មកស្រុកកំណើតវិញ ត្រូវបានអាជ្ញាធរថៃធ្វើការដោះលែងចេញពីពន្ធនាគារអោយមានសេរីភាព ហើយអោយវិលត្រលប់មកកាន់ស្រុកកំណើតវិញបន្ទាប់ពីពួកគេទាំង៣នាក់បានឆ្លងដែនដោយខុសច្បាប់កាប់ឈើគ្រញូងក្នុងទឹកដីថៃរួចមក។ ពិធីប្រគល់និងទទួលប្រជាពលរដ្ឋខ្មែរទាំង៣នាក់នេះ បានធ្វើឡើងកាលពីវេលាម៉ោង១៣និង២០នាទី ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ តាមច្រកអន្តរជាតិជាំស្រងាំ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថា ប្រជាពលរដ្ឋខ្មែរដែលត្រូវបានភាគីថៃបញ្ជូនមកស្រុកកំណើតគឺមានឈ្មោះ ផ្លោក វ៉ាត ភេទប្រុស អាយុ១៥ឆ្នាំ រស់នៅភូមិឫស្សី ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ,ទី២.ឈ្មោះ សាក់ បាន ភេទប្រុស អាយុ ១៦ ឆ្នាំរស់នៅភូមិឫស្សី ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ,និងទី៣.ឈ្មោះ សំ នី ភេទប្រុស អាយុ១៥ឆ្នាំរស់នៅភូមិតាផាំ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានបន្តថា អ្នកទាំង៣ត្រូវបានភាគីថៃចាប់ខ្លួនកាល ពីថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៨កន្លងទៅនេះ ពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងក្នុងទឹកដីថៃ ដោយចូលតាមច្រកតាថាវ ហើយត្រូវបានភាគីថៃយកទៅដាក់ពន្ធនាគារនៅខេត្តអូរប៊ុន ប្រទេសថៃ។

ក្រោយពីទទួលពីភាគិថៃរួចមក ភាគីកម្ពុជាបានធ្វើការអប់រំ ណែនាំ និងធ្វើកិច្ចសន្យាបញ្ឈប់ការឆ្លងដែនខុសច្បាប់ រួចឲ្យវិលត្រលប់ទៅកាន់លំនៅដ្ឋាន ដើម្បីជួបជុំក្រុមគ្រួសារវិញ៕B/

---